ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការសិក្សាស្តីពីការអភិវឌ្ឍន៍វិសាលភាពកសិកម្ម
# នៅក្នុងអាងស្ទឹងព្រែកត្នោត ក្នុងព្រះរាជាណាចក្រកម្ពុជា

## របាយការណ៍បញ្ចប់
### ក្បាលទី ១
### សង្ខេប

ខែ សីហា ឆ្នាំ ២០០៨

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ (JICA)

NIPPON KOEI CO., LTD.




Location Map of Study and Target Areas

# PRESENT LAND USE MAP
## of Target Area




Note : prepared in 2005

| Land Use Category | Area [Ha] | % |
|---|---|---|
| Paddy Field | 42,780 | 40.7 |
| Upland Field | 820 | 0.8 |
| Forest | 2,120 | 2.0 |
| Shrub & Grass Land | 50,390 | 47.9 |
| Industrial Area | 650 | 0.6 |
| Settlement Area | 6,460 | 6.1 |
| Barren Land | 1,040 | 1.0 |
| Others | 140 | 0.1 |
| Water Surface | 800 | 0.8 |
| Total | **105,200** | **100** |

# ZONNING MAP FOR TARGET AREA




PROPOSED IRRIGATION CANAL LAYOUT
in Zone-1 and Zone-2 Areas
ZONE-1
ZONE-2
North Main Canal
South Main Canal
Ta Hor Canal
Ou Krang Ambel Pond
Tuol Samn Ang Check Gate
Andong Sla Intake Gate
Wat Kruoch Intake Gate
Roleang Chrey Regulator
Phum Roung Check Gate (SMHR-2)
Preak Thnot River Basin
Target Area
LEGEND
Cross Drain
Proposed Check Structure
Proposed Turnout
Turnout to be closed
Proposed Sec. & Sub Sec. Canals
Main Canal
Existing Secondary & Tertiary Canals
Stream
National Road
Secondary Road
Open Water surface
Target Area
2 0 2 Kilometers

# ការសិក្សា
# ស្តីពី
# ការអភិវឌ្ឍន៍វិសាលភាពកសិកម្ម នៅក្នុងអាងស្ទឹងព្រែកត្នោត
# ក្នុង
# ព្រះរាជាណាចក្រកម្ពុជា
# របាយការណ៍បញ្ចប់
# សង្ខេប

**ក្បាលទី ២ ផែនការមេ**

## ជំពូកទី ១: សេចក្តីផ្តើម

### (១) ការផ្តល់សិទ្ធ: (១.១)

ផែនការមេនេះ គឺជាផ្នែកមួយរបស់របាយការណ៍ពង្រៀងចុងក្រោយ ដែលត្រូវបានរៀបចំឡើងអនុលោមតាម ទំហំការងារនៃការសិក្សា ដែលបានឯកភាពដោយ ក្រសួងធនធានទឹក និងឧតុនិយម នៃព្រះរាជាណាចក្រកម្ពុជា ជាមួយ និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥។ របាយការណ៍បង្ហាញពីលទ្ធផលរបស់ **ផែនការមេ** សំរាប់ក្នុងតំបន់គោលដៅ ដែលបានអនុវត្តន៍តាំងតែពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ រហូតដល់ចុងខែ កុម្ភៈ ឆ្នាំ ២០០៧។

### (២) ធាតុបន្សំនៃរបាយការណ៍ពង្រៀងចុងក្រោយ: (១.២)

**របាយការណ៍រួមមាន ០៧ ក្បាល ដូចខាងក្រោម:**

| | |
|---|---|
| ក្បាល ទី ០១ | ស្តីពីបាយការណ៍សង្ខេប |
| ក្បាល ទី ០២ | ស្តីពីផែនការមេ |
| ក្បាល ទី ០៣ | ស្តីពីការសិក្សាសមិទ្ធិនៃគំរោងជួសជុលបន្ទាន់ |
| ក្បាល ទី ០៤ | ស្តីពីគំរោងគំរូ |
| ក្បាល ទី ០៥ | ស្តីពីឧតុនិយម និងជលសាស្ត្រ និងការពង្រឹងសមត្ថភាពគ្រប់គ្រងបរិស្ថាន |
| ក្បាល ទី ០៦ | មាតិការបស់ផែនការមេ |
| ក្បាល ទី ០៧ | មាតិកាស្តីពីការសិក្សាសមិទ្ធិនៃ គំរោងជួសជុលបន្ទាន់ |

### (៣) ប្រវត្តិសង្ខេបនៃការសិក្សា: (១.៣)

ដោយសារប្រព័ន្ធធារាសាស្ត្រនៅមានកំរិត នៅក្នុងអាងស្ទឹងព្រែកត្នោតធ្វើឱ្យការប្រកបរបរកសិកម្មពឹងផ្អែកទាំងស្រុងលើទឹកភ្លៀងដែលមានមិនទៀងទាត់។ កត្តានេះបានធ្វើឱ្យផលិតផលដំណាំមានកំរិតទាប និងមិនមានស្ថេរភាព ដែល ធ្វើឱ្យកសិករមួយចំនួនពុំមានស្បៀងគ្រប់គ្រាន់សំរាប់ការហូបចុកប្រចាំគ្រួសាររបស់ខ្លួន។ ក្នុងន័យនេះ រាជរដ្ឋាភិបាល កម្ពុជា បានសំណូមពរទៅរាជរដ្ឋាភិបាលជប៉ុនឱ្យផ្តល់ជំនួយបច្ចេកទេសសំរាប់ការសិក្សាស្តីពីការអភិវឌ្ឍន៍វិសាលភាព កសិកម្មនៅអាងស្ទឹងព្រែកត្នោត ក្នុងគោលបំណងកែលំអផលិតភាពកសិកម្ម។ ឆ្លើយតបទៅនឹងសំណូមពរនេះ រាជរដ្ឋា ភិបាលជប៉ុន បានបញ្ជូនក្រុមសិក្សារៀបចំមកកម្ពុជានៅខែ មករា ឆ្នាំ ២០០៥ ហើយបានឯកភាពលើទំហំការងារនៃការ សិក្សាដែលបានពិពណ៌នាខាងលើ។

### (៤) គោលបំណងនៃការសិក្សា: (១.៣.២)

- រៀបចំប្លង់មេស្តីពីការអភិវឌ្ឍន៍វិសាលភាពកសិកម្ម ក្នុងគោលបំណងកែលំអផលិតភាពកសិកម្មនៅក្នុងអាង ស្ទឹងព្រែកត្នោត។
- អនុវត្តន៍ការសិក្សាសមិទ្ធិ ស្តីពីការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកដែលមានស្រាប់ ដែល មានភាពបន្ទាន់ និងមានអាទិភាពខ្ពស់សំរាប់ការកែលំអការដាំដុះស្រូវ។
- រៀបចំផែនការជូនដំណឹង និងព្យាករណ៍ទឹកជំនន់។
- ផ្ទេរបច្ចេកវិជ្ជាដល់មន្ត្រីសមភាគីតាមរយះការបណ្តុះបណ្តាលរៀនផងធ្វើផងនៅក្នុងរយះពេលនៃការសិក្សា។

## (៥) តំបន់គោលដៅ និងតំបន់សិក្សា: (១.៤)

**តំបន់គោលដៅ** នៃផែនការប្លង់មេ នឹងគ្របដណ្តប់លើផ្ទៃដីកសិកម្មភាគច្រើន ដែលជាដីធ្វើស្រែស្ថិតនៅក្នុងអាង ស្ទឹងព្រែកត្នោត។ តំបន់នេះស្ថិតនៅក្នុងស្រុកច្បារមន ហើយលាតសន្ធឹងពីទ្វារទឹករលាំងជ្រៃឆ្ពោះទៅកាន់ផ្លូវជាតិលេខ ៣ ដែលស្ថិតនៅក្នុងតំបន់មួយចំនួននៃស្រុកសំរោងទង និងស្រុកគងពិសី នៅក្នុងខេត្តកំពង់ស្ពឺ និងស្ថិតនៅក្នុងតំបន់មួយចំនួន នៃស្រុកអង្គស្នួល និងស្រុកកណ្តាលស្ទឹង ក្នុងខេត្តកណ្តាល។

**តំបន់សិក្សា** រួមមានផ្នែកខ្សែទឹកខាងលើ និងផ្នែកខ្សែទឹកខាងក្រោមនៃអាងស្ទឹងព្រែកត្នោត គឺក្នុងន័យប្រមូល ទិន្នន័យជលសាស្ត្រដែលចាំបាច់សំរាប់ការវិភាគ។

## (៦) ការផ្ទេរបច្ចេកវិជ្ជា: (១.៦)

មុនពេលចាប់ដំណើការនៃការសិក្សា ក្រុមសិក្សានៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានបញ្ជូនផែនការផ្ទេរ បច្ចេកវិជ្ជា មកក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៥។ ស្របជាមួយនិងផែនការនេះ ការផ្ទេរបច្ចេកវិជ្ជា ត្រូវបានអនុវត្តន៍ឡើងតាមរយះការបណ្តុះបណ្តាលរៀនផងធ្វើផង។

## (៧) កិច្ចប្រជុំនៃគណៈកម្មាធិការដឹកនាំគំរោង: (១.៧)

ក្នុងរយះពេលនៃការសិក្សា កិច្ចប្រជុំនៃគណៈកម្មាធិការដឹកនាំគំរោង ត្រូវបានរៀបចំឡើង ចំនួន ០៦ លើក ដើម្បី ពិភាក្សាលើរបាយការណ៍ដែលបានរៀបចំដោយក្រុមសិក្សាជប៉ុននៅសាលប្រជុំរបស់ក្រសួងធនធានទឹក និងឧតុនិយម។

| កិច្ចប្រជុំនៃគណៈកម្មាធិការដឹកនាំគំរោង | របាយការណ៍បានដាក់ | កាលបរិច្ឆេទនៃការប្រជុំ |
|---|---|---|
| ១ | របាយការណ៍បឋម | ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៥ |
| ២ | របាយការណ៍វឌ្ឍនៈភាព (១) | ថ្ងៃទី ២២ ខែ កុម្ភះ ឆ្នាំ ២០០៦ |
| ៣ | របាយការណ៍ជំហានដំបូង (១) | ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦ |
| ៤ | របាយការណ៍វឌ្ឍនៈភាព (២) | ថ្ងៃទី ២២ ខែ កុម្ភះ ឆ្នាំ ២០០៧ |
| ៥ | របាយការណ៍ជំហានដំបូង (២) | ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ |
| ៦ | របាយការណ៍វឌ្ឍនៈភាព (៣) | ថ្ងៃទី ២០ ខែ កុម្ភះ ឆ្នាំ ២០០៧ |

កិច្ចប្រជុំនេះ បានចូលរួមដោយមន្ត្រីនៃក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ តំណាងស្ថានទូត ជប៉ុនប្រចាំនៅកម្ពុជា, តំណាងការិយាល័យនៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំនៅកម្ពុជា ក៏បានមកចូលរួម នៅក្នុងកិច្ចប្រជុំនេះផងដែរ។ បន្ទាប់ពីការពិភាក្សាលើរបាយការណ៍ជាមួយអ្នកចូលរួម របាយការណ៍នេះ ត្រូវបានឯកភាព និង ទទួលយកដោយគណៈកម្មាធិការខាងលើ។

# ជំពូកទី ២: ប្រវត្តិសង្ខេប:

## (៨) គោលនយោបាយអភិវឌ្ឍន៍ជាតិ: (២.២)

**<u>គោលនយោបាយអភិវឌ្ឍន៍ជាតិនាពេលបច្ចុប្បន្ន</u>**

- យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន, ការងារ, សមធម៌ និងប្រសិទ្ធិភាព។
- យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥។
- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រាំឆ្នាំលើកទី ២ ២០០១-២០០៥។
- ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ២០០៦-២០១០។

**បញ្ហារួមដែលពាក់ព័ន្ធនិងការសិក្សា**

ការអភិវឌ្ឍន៍វិស័យកសិកម្ម ត្រូវបានផ្តល់អាទិភាពខ្ពស់ដើម្បីធានាដល់ការកាត់បន្ថយភាពក្រីក្រ និងកំណើន សេដ្ឋកិច្ច។

### (៩) គោលនយោបាយអភិវឌ្ឍន៍តាមវិស័យៈ (២.៣)

**គោលនយោបាយអភិវឌ្ឍន៍តាមវិស័យនាពេលបច្ចុប្បន្ន**

- ផែនការអភិវឌ្ឍន៍កសិកម្មសំរាប់រយះពេលវែង, មធ្យម និងខ្លី ២០០១-២០១០។
- កម្មវិធីសកម្មភាពសំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ២០០១-២០១០។
- ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រសំរាប់វិស័យទឹក ២០០៦-២០១០។
- ផែនការស្តារ និងអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយមសំរាប់រយះពេលប្រាំឆ្នាំ ២០០១-២០០៥។
- គោលនយោបាយស្តីពីនិរន្តរភាពនៃការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ។

**បញ្ហារួមដែលពាក់ព័ន្ធនិងការសិក្សា**

តំរូវការនៃការកែលំអផលិតភាពកសិកម្ម និងការពង្រីកផ្ទៃដីស្រោចស្រពតាមរយះការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ។

## ជំពូកទី ៣: ការវិភាគឧតុនិយម និងជលសាស្ត្រនៅក្នុងតំបន់សិក្សាៈ

### (១០) លក្ខខណ្ឌឧតុនិយម និងជលសាស្ត្រៈ (៣.១)

អាកាសធាតុនៃតំបន់សិក្សា ទទួលរងនូវរបបមូសុងត្រូពិក ដែលបង្កើតឱ្យមានរដូវវស្សា (ចាប់ផ្តើមពីខែ ឧសភា រហូតដល់ខែ វិច្ឆិកា) និងរដូវប្រាំង ( ចាប់ផ្តើមពីខែ ធ្នូ រហូតដល់ខែ មេសា)។ បំរែបំរួលសីតុណ្ហភាពមធ្យមប្រចាំរដូវ មានតិចតួច គឺប្រែប្រួលពី ២៦.១ អង្សារ នៅក្នុងខែ ធ្នូ និង៣០.៥ អង្សារនៅក្នុងខែ មេសា។ សំណើមបរិយាកាសប្រែ ប្រួលពី ៦៦% ទៅ ៧៧% នៅក្នុងខែ កុម្ភៈ ហើយ ៨០% ទៅ ៩០% នៅក្នុងខែ កញ្ញា និងខែតុលា។ រដូវវស្សា ត្រូវការទឹក ៩០%នៃបរិមាណទឹកភ្លៀងប្រចាំឆ្នាំ។ បរិមាណទឹកភ្លៀងមធ្យមប្រចាំឆ្នាំ នៅក្នុងអាងស្ទឹងព្រែកត្នោត ត្រូវបានប៉ាន់ស្មានមានចំនួន ១,២២៥ មម។ នៅឆ្នាំ ២០០៥ នេះ មានស្ថានីយ៍វាស់កំពស់ទឹកចំនួន ៣ កន្លែង គឺ ស្ថានីយ៍ពាមខ្លី, ស្ថានីយ៍ធ្នួសលួង និងស្ថានីយ៍នៅទ្វារទឹករលាំងជ្រៃ។ រយះពេលនៃទិន្នន័យគ្រប់គ្រាន់ គឺប្រែប្រួលពី រយះពេល ៥ ឆ្នាំ ទៅរយះពេល ៩ ឆ្នាំ ទៅតាមស្ថានីយ៍។

### (១១) លក្ខខណ្ឌរបស់ស្ទឹងព្រែកត្នោត (៣.២.១ និង ៣.២.៤)

ស្ទឹងព្រែកត្នោត មានអនុអាងស្ទឹង ចំនួន ១១ និងមានផ្ទៃរងទឹកភ្លៀងចំនួន ៥, ០៩៧ គម$^{២}$ ហើយហូរចាក់ទៅ ទន្លេបាសាក់។ ចំណោតរបស់ស្ទឹងមានប្រមាណជា ១/២,៧២០ សំរាប់ខ្សែទឹកខាងលើ និង ១/៥,១០០ សំរាប់ខ្សែទឹក ខាងក្រោម។ សមត្ថភាពការហូរប្រែប្រួលពី ១,៣០០ ម$^{៣}$/វិនាទី ទៅ ១,៥០០ ម$^{៣}$/វិនាទី សំរាប់ខ្សែទឹកខាងលើ និង ៣០០ ម$^{៣}$/វិនាទី ទៅ ៨០០ ម$^{៣}$/វិនាទី សំរាប់ខ្សែទឹកខាងក្រោមដោយសមាមាត្រទៅនឹងចំណោតស្ទឹង។ យោងតាម ឆ្នាំបិទបើកទ្វារទឹករលាំងជ្រៃ ដែលមានបទពិសោធន៍ចំនួន ៣០ ឆ្នាំ បានអោយដឹងថា ទឹកជំនន់ធំបំផុត គឺក្នុងឆ្នាំ ១៩៩១ និងធារទឹកមានប្រមាណ ១,៣៦៩ ម$^{៣}$/វិនាទី។ម្យ៉ាងទៀត តាមលទ្ធផលនៃការសិក្សាឋានលេខាសំរាប់ស្ទឹងព្រែកត្នោត បង្ហាញថា សមត្ថភាពការហូរប្រែប្រួលពី ១,៣០០ ម$^{៣}$/វិនាទី ទៅ ១,៥០០ ម$^{៣}$/វិនាទី សំរាប់ខ្សែទឹកខាងលើដែលបាន រៀបរាប់កន្លងមក ហើយមានបរិមាណប្រហាក់ប្រហែលទៅនឹងការអង្កេតរបស់ឆ្នាំទ្វារទឹក។ ជាមួយនិងការរកឃើញនេះ ទឹកជំនន់ខ្ពស់បំផុតដែលកើតឡើង នឹងអាចត្រូវបានប្រើប្រាស់ជាធារទឹកគ្រោងសំរាប់ទ្វារទឹកលាំងជ្រៃ សំរាប់ធានាការ

ដោះទឹក។ ផ្តើមចេញពីទស្សនៈអភិរក្សស្តីពីលក្ខខ័ណ្ឌការងារកែលំអស្ទឹងនៅផ្នែកខ្សែទឹកខាងលើនៃទីតាំងសំណង់បង្វែរទឹក ធារទឹកគ្រោងត្រូវស្ថិតក្នុងចន្លោះ ១,៣០០ ម$^{៣}$/វិនាទី ទៅ ១,៥០០ ម$^{៣}$/វិនាទី ឬ ចន្លោះពី ១,៤០០ ម$^{៣}$/វិនាទី ទៅ ១,៦០០ ម$^{៣}$/វិនាទី នឹងមិនមានការបង្កើនសមត្ថភាពនាំធារទឹកស្ទឹងសំរាប់ផ្នែកខ្សែទឹកដូចបានរៀបរាប់ខាងលើ។

### (១២) ការវិភាគលំហូរទាបៈ (៣.៥.១)

ធារទឹកដែលអាចធានាបានសំរាប់រយះពេល ៥ ថ្ងៃ នៅត្រង់ចំណុចទ្វារទឹករលាំងជ្រៃ ត្រូវបានគេគណនាប៉ាន់ស្មានសំរាប់ការអភិវឌ្ឍន៍ការស្រោចស្រព បានផ្តើមគិតពីចំណុចពាមខ្ញីសមាមាត្រនិងផ្ទៃរងទឹកភ្លៀង ដោយប្រើប្រាស់ទិន្នន័យ លំហូរទឹកភ្លៀង។ ធារទឹកដែលអាចធានាបានចំនួន ៨០% និង៥០% ត្រង់ទ្វារទឹករលាំងជ្រៃ ត្រូវបានប៉ាន់ស្មានស្មានដូច ខាងក្រោមនេះៈ

**ធារទឹកដែលអាចធានាបាននៅត្រង់ទ្វារទឹករលាំងជ្រៃ**

| ធានាបាន | រដូវប្រាំង | រដូវប្រាំង |
|---|---|---|
| 80 % | 2.8 m$^3$/sec – 51.9 m$^3$/sec | 9.8 m$^3$/sec – 384.4 m$^3$/sec |
| 50 % | 2.9 m$^3$/sec – 51.9 m$^3$/sec | 20.8 m$^3$/sec – 537.7 m$^3$/sec |

## ជំពូកទី ៤: តំបន់គោលដៅៈ

### (១៣) ការងាររដ្ឋបាល និងប្រជាជនៈ (៤.២)

តំបន់គោលដៅ គឺពាក់ព័ន្ធដល់ខេត្តចំនួន ២, ស្រុកចំនួន ៥, ឃុំចំនួន ៤២ និងភូមិចំនួន ៧៣០។ នៅក្នុងខេត្តកំពង់ស្ពឺ មានស្រុកច្បារមន និងផ្នែកខ្លះនៃស្រុកសំរោងទង និងគងពិសីត្រូវស្ថិតនៅក្នុងតំបន់គោលដៅ។ នៅក្នុងខេត្តកណ្តាល មាន ស្រុកកណ្តាលស្ទឹង និងផ្នែកខ្លះនៃស្រុកអង្គស្នួល ត្រូវស្ថិតនៅក្នុងតំបន់គោលដៅផងដែរ។

យោងតាមមូលដ្ឋានទិន្នន័យឃុំរបស់កម្មវិធីសិលា ឆ្នាំ ២០០៤ ចំនួនប្រជាជននៅក្នុងតំបន់គោលដៅមានចំនួន ៣៤០,៧៨៤ នាក់ ក្នុងនោះប្រជាជនចំនួន ២៤៣,៩៤៤ នាក់ នៅក្នុងខេត្តកំពង់ស្ពឺ និងប្រជាជនចំនួន ៩៦,៨៤០ នាក់ នៅក្នុងខេត្តកណ្តាល។

### (១៤) លក្ខខំណ្ឌធម្មជាតិៈ (៤.៣)

កំរិតកំពស់ដីធម្មជាតិធៀបនឹងទឹកសមុទ្រ នៅក្នុងតំបន់គោលដៅប្រែប្រួលពីកំពស់ ២០ម ទៅ ៧០ម ដែលមានជំរាលទេរពីទិសខាងលិចទៅទិសខាងកើត។ តំបន់គោលដៅត្រូវបានចែកចេញជាពីរផ្នែក គឺផ្នែកខាងជើង និងផ្នែកខាងត្បូងតាមទិសលំហូរនៃស្ទឹងព្រែកត្នោតពីលិចទៅកើត។ ប្រភេទដីនៅក្នុងតំបន់គោលដៅ ជាប្រភេទដីដែលមានទំហំមធ្យម នៅស្រទាប់ផ្នែកខាងលើ ហើយស្រទាប់ដីនៅផ្នែកខាងក្រោមមានទំហំម៉ត់ល្អ។ ៩០% នៃតំបន់គោលដៅ ត្រូវចាត់ទុកជាដី ដែលមានអំណោយផលល្អដល់ការងារដាំដុះ។

### (១៥) ការសិក្សាសេដ្ឋកិច្ចសង្គមៈ (៤.៥)

យោងតាមការវិភាគតុល្យភាពស្បៀងដែលបានធ្វើឡើងដោយក្រុមសិក្សា បានបង្ហាញឱ្យឃើញថា មានប្រជាជន ប្រមាណ ៣៨% ពុំមានដីស្រែគ្រប់គ្រាន់សំរាប់បំពេញតំរូវការនៃការហូបចុកនៅក្នុងឃុំនៃតំបន់គោលដៅ។ ក្នុងចំណោម ចំនួនគ្រួសារគំរូដែលបានជ្រើសរើសសំរាប់យកមកវិភាគ មានចំនួនគ្រួសារប្រមាណ ៨០% ស្ថិតនៅក្រោមបន្ទាត់នៃភាព ក្រីក្រ (ចំណូលជាមធ្យមប្រចាំថ្ងៃក្នុងម្នាក់មានចំនួន ០,៤៦ ដុល្លារអាមេរិក)។ លទ្ធផលនៃការអង្កេតសេដ្ឋកិច្ច-សង្គម បង្ហាញឱ្យឃើញថា ពុំមានបញ្ហាភេទធ្ងន់ធ្ងរកើតមានឡើងនៅក្នុងតំបន់គោលដៅក្នុងពេលធ្វើអង្កេតគ្រួសារគំរូ។

### (១៦) ការកាន់កាប់ដី និងសិទ្ធគ្រប់គ្រងដីៈ (៤.៧.១)

**តួលេខនៃសិទ្ធគ្រប់គ្រងដី និងការកាន់កាប់ដីនៅក្នុងឃុំនៃតំបន់គោលដៅ**

| សន្ទស្សន៍ | តួលេខ |
|---|---|
| ចំនួនគ្រួសារសរុប | 62,100 |
| ចំនួនគ្រួសារដែលប្រកបរបរកសិកម្ម (ចំនួនគ្រួសារដែលដាំដំណាំ) | 55,847 |
| ចំនួនគ្រួសារដែលមិនប្រកបរបរកសិកម្ម (ចំនួនគ្រួសារដែលមិនដាំដំណាំ)<br>ចំនួនគ្រួសារដែលគ្មានដី | 6,253 [1/] |
| ចំនួនផ្ទៃដីស្រែសរុបនៅក្នុងឃុំនៃគំរោង | 39,688 ha |
| ទំហំផ្ទៃដីស្រែជាមធ្យមប្រចាំគ្រួសារកសិករ | 0.71 ha |
| ភាគរយនៃគ្រួសារកសិករដែលមានដីស្រែតិចជាង ១០ អារ | 4 % |
| ភាគរយនៃគ្រួសារកសិករដែលមានដីស្រែច្រើនជាង ៣ ហិកតា | 2 % |
| ភាគរយនៃគ្រួសារកសិករដែលគ្មានដីស្រែ | 10% |

*[១] ៤១% នៅក្នុងស្រុកច្បារមនត្រូវបានចាត់ចូលជាតំបន់ជាយក្រុង នៅក្នុងមូលដ្ឋានទិន្នន័យនៃកម្មវិធីសិលា*

*ប្រភពព័ត៌មាន: ការអង្កេតថ្នាក់ឃុំស្តីពីដំណាំ និងការចិញ្ចឹមសត្វ ឆ្នាំ ២០០៣ របស់ក្រសួងកសិកម្ម និងមូលដ្ឋានទិន្នន័យរបស់កម្មវិធីសិលា ឆ្នាំ ២004*

## (១៧) ការប្រើប្រាស់ដីនាពេលបច្ចុប្បន្នៈ (៤.៧.២)

**ការប្រើប្រាស់ដីនាពេលបច្ចុប្បន្ននៃតំបន់គោលដៅ**

| ប្រភេទនៃការប្រើប្រាស់ដី | ផ្ទៃដី (ha) | % | ប្រភេទនៃការប្រើប្រាស់ដី | ផ្ទៃដី (ha) | % |
|---|---|---|---|---|---|
| ដីស្រែ [១] | 42,780 | 40.7 | ដីលំនៅដ្ឋាន និងឧស្សាហកម្ម | 7,110 | 6.8 |
| ដីដាំដំណាំ | 820 | 0.8 | ផ្សេងៗ | 1,180 | 1.1 |
| ដីព្រៃ | 2,120 | 2.0 | ផ្ទៃទឹក | 800 | 0.8 |
| ដីវាលស្មៅ និងគម្ពោតព្រៃ | 50,390 | 47.9 | សរុប | 105,200 | 100 |

*១: ផ្ទៃដីសរុប*

## (១៨) ការផលិតស្រូវៈ (៤.៧.៣)

ការផលិតស្រូវ គឺជាសកម្មភាពកសិកម្មដ៏មានសារៈសំខាន់បំផុតនៅក្នុងតំបន់គោលដៅ ហើយស្ទើរតែ ១០០% នៃគ្រួសារកសិករដាំដុះស្រូវវស្សា។ ដីស្រែនៅក្នុងតំបន់គោលដៅបែងចែកជា ៣ ប្រភេទ ដោយផ្អែកលើលក្ខខ័ណ្ឌនៃការ ផ្គត់ផ្គង់ទឹកស្រោចស្រពៈ ដីស្រែស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ, ដីស្រែស្រោចស្រពបន្ថែមដោយប្រព័ន្ធធារាសាស្ត្រ និង ដីស្រែស្រោចស្រពដោយទឹកភ្លៀង។ ទិន្នផលស្រូវ និងការផលិតស្រូវនៅក្នុងតំបន់គំរោងត្រូវបានប៉ាន់ស្មានដោយផ្អែក លើមូលដ្ឋាននៃទិន្នន័យស្ថិតិរបស់ក្រសួងកសិកម្ម និងមន្ទីរកសិកម្មខេត្ត ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោមនេះ

**ទិន្នផលស្រូវ និងការផលិតស្រូវនៅក្នុងឃុំនៃគំរោង**

| ឃុំ | ទិន្នផលស្រូវមធ្យម (ton/ha) | | | | |
|---|---|---|---|---|---|
| | ផ្ទៃដីដាំស្រូវ | | ផ្ទៃដីប្រមូលផលស្រូវ | | ផលិតផល |
| | ស្រូវវស្សា | ស្រូវប្រាំង | ស្រូវវស្សា | ស្រូវប្រាំង | (1000ton) |
| ឃុំនៅក្នុងខេត្តកំពង់ស្ពឺ [1/] | 1.4 | 2.4 | 1.7 | 2.6 | 38.0 |
| ឃុំនៅក្នុងខេត្តកណ្តាល [2/] | 1.8 | 2.8 | 1.9 | 2.8 | 17.2 |
| គ្រប់ឃុំនៃគំរោង [3/] | 1.6 | 2.4 | 1.7 | 2.4 | 62.7 |

*១: មធ្យមនៃឆ្នាំ ២០០៣-២០០៤, ២០០៤-២០០៥ ២: ២០០០-២០០១ ៣: ២០០៣-២០០៤*

## (១៩) តុល្យភាពស្បៀង: (៤.៧)

តុល្យភាពស្បៀងនៅក្នុងឃុំនៃគំរោង

| ឆ្នាំដាំដុះ | ផលិតផល (តោន) | តំរូវការអង្ករ (តោន) | តុល្យភាពស្បៀង (តោន) | សមាមាត្រ (%) 1/ |
|---|---|---|---|---|
| 2002– 2003 | 45,160 | 45,660 | - 20,510 | 45 |
| 2003 – 2004 | 62,720 | 46,440 | - 11,510 | 25 |
| 2004 – 2005 | 46,950 | 47,140 | - 21,000 | 45 |
| **មធ្យម** | 51,610 | 46,410 | - 17,680 | 38 |

*១: សមាមាត្រនៃភាពខ្វះខាតធៀបទៅនឹងតំរូវការ*

ភាពខ្វះខាតចំនួន ៣៨% ធៀបទៅនឹងតំរូវការត្រូវបានប៉ាន់ស្មានជាមធ្យមនៅក្នុងឃុំនៃគំរោង។ ភាពខ្វះខាត ជាមធ្យមនៃអង្ករមានចំនួន ១៧.៦៨០ តោន ហើយបើគិតជាស្រូវមានចំនួន ៣២.០០០ តោន គឺប្រហែល ៦២% នៃផលិត ផលមធ្យមប្រចាំឆ្នាំដែលមានបរិមាណចំនួន ៥១.៦១០ តោន។

## (២០) ទ្វារទឹករលាំងជ្រៃ: (៤.៨)

ទ្វារទឹករលាំងជ្រៃ គឺជាសំណង់គន្លឹះនៃប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់គោលដៅ។ ទ្វារទឹករលាំងជ្រៃបានកសាង ឡើងនៅក្នុងឆ្នាំ ១៩៧៤។ បច្ចុប្បន្ននេះ ផ្នែកខ្លះនៃទ្វារទឹកនេះមានសភាពចាស់ទ្រុឌទ្រោមជាងការខូចខាត។ ដោយឡែក សន្ទះទ្វារទឹក ដែលមានតួនាទីសំខាន់ក្នុងការរក្សាទឹកទុក និងត្រួតពិនិត្យទឹកជំនន់មានសភាពចាស់ទ្រុឌទ្រោមដ៏ធ្ងន់ធ្ងរ និង មិនអាចដំណើរការបានល្អពេញលេញ។ ដូចនេះ ទាមទារឱ្យមានការជួសជុលជាបន្ទាន់ ដើម្បីធានាដល់កិច្ចដំណើរការ ប្រកបដោយសុវត្ថិភាព។

## (២១) ការស្រោចស្រព និងការដោះទឹក: (៤.៩)

**<u>ការធ្វើបញ្ជីសារពើភ័ណ្ឌប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់</u>**

យោងតាម បញ្ជីសារពើភ័ណ្ឌប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ប្រព័ន្ធធារាសាស្ត្រដែលមាននៅក្នុងតំបន់គោលដៅ មានដូចក្នុងតារាងខាងក្រោម:

| ប្រភពទឹក | ចំនួនប្រព័ន្ធ | ផ្ទៃដីដែលបានពង្រីក (ha) | ចំនួនប្រព័ន្ធមានអាងទឹក |
|---|---|---|---|
| (1) **ស្ទឹងព្រែកត្នោត** | **៣៥** | ១៥.២០៧ | ១៧ |
| (2) **ស្ទឹងអូរក្រាំងអំបិល** | **១** | ៤៩៨ | ១ |
| (3) **ដៃស្ទឹងតូចៗ** | **៤៩** | ១.៧៩៦ | ៤៩ |
| **សរុប** | ៨៥ | ១៧.៥០១ | ៦៧ |

ផ្ទៃដីសារពើភ័ណ្ឌដែលបានរៀបរាប់ខាងលើ គឺប៉ាន់ស្មានដោយពុំបានដាក់បញ្ចូលទស្សនៈ សំរាប់ការផ្គត់ផ្គង់ទឹក ដែលទូទៅត្រូវបានប្រើជាគំរូសំរាប់ផ្ទៃដីស្រោចស្រព និងរួមបញ្ចូលផ្ទៃដីដែលស្រោចស្រពតែ ២ ឬ បី ដង សំរាប់ដំណាំ ប្រចាំរដូវនីមួយៗ ឬផ្ទៃដីដែលស្រោចស្រពតែមួយដង សំរាប់រយៈពេល ២ ឬ បីឆ្នាំ។ ដូច្នេះ ផ្ទៃដីក្នុងសារពើភ័ណ្ឌ មិនមានន័យថា ជាផ្ទៃដីស្រោចស្រពដែលស្ថិតស្ថេរទេ។

**<u>គំរោងមជ្ឈមណ្ឌលអភិវឌ្ឍន៍ចំរុះខាងលិចរាជធានីភ្នំពេញ</u>**

គំរោងនេះ មានគោលបំណងពង្រីកផ្ទៃដីស្រោចស្រពឱ្យបាន ២៤.០០០ ហិកតា នៅក្នុង និងជុំវិញតំបន់គោលដៅ ដោយប្រើប្រាស់ទឹកពីស្ទឹងព្រែកត្នោត។ គំរោងនេះ រួមមានការសាងសង់ប្រឡាយមេប្រវែង ៧៩ គ.ម. ប្រឡាយថ្នាក់ទី២ ប្រវែង ១៩ គ.ម. ប្រឡាយថ្នាក់ទី៣ ប្រវែង ១៩២ គ.ម. ប្រឡាយដោះទឹកប្រវែង ៩៥ គ.ម និងសំណង់ ពាក់ព័ន្ធប្រមាណ ១៥០ សំណង់។ នៅក្នុងតំបន់គំរោងមានប្រព័ន្ធធារាសាស្ត្រចំនួន ៦៦។ គំរោងនេះ បានចាប់ផ្តើម ដំណើរការសាងសង់នៅក្នុងឆ្នាំ ២០០១

ហើយវឌ្ឍនៈភាពនៃគំរោងនេះអនុវត្តបានប្រមាណ ៧% មកទល់ពេលនេះ។ តំបន់ គំរោងនេះ បានបញ្ចូលទៅក្នុងការសិក្សានាពេលបច្ចុប្បន្ននេះ ទោះបីជា ការលើកភ្លឺប្រឡាយបន្ថែម និងសំណង់បន្ថែម ទាមទារឱ្យមានការសាងសង់ឡើង។

ការប្រើប្រាស់ និងថែទាំទ្វារទឹករលាំងជ្រៃ និងប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹកផ្សេងទៀត គួរតែអនុវត្តន៍ ដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ និងសហគមន៍កសិករប្រើប្រាស់ទឹក។ ក៏ប៉ុន្តែ ពួកគេមិនអាចអនុវត្ត អោយបានពេញចិត្តទេ ដោយសារកង្វះខាតបច្ចេកទេស និងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត ការគ្រប់គ្រងទឹកអោយបាន ប្រសើរក៏មិនអាចបំពេញបាន។

### (២២) អាជ្ញាធរមូលដ្ឋាន និងសហគមន៍កសិករប្រើប្រាស់ទឹក: (៤.១០.៣, ៤.១០.៤ និង ៤.១០.៥)

ក្រុមប្រឹក្សាឃុំ និងគណកម្មាធិការអភិវឌ្ឍន៍ភូមិ កំពុងត្រូវបានបង្កើតឡើង នៅក្នុងតំបន់គោលដៅ ដើម្បីចាត់ចែង និងគ្រប់គ្រងឃុំ និងភូមិ។ បន្ថែមពីលើការងារខាងលើនេះ សហគមន៍កសិករប្រើប្រាស់ទឹកចំនួន ២៥ និងក្រុមកសិករ ប្រើប្រាស់ទឹកត្រូវបានបង្កើតឡើង ក៏ប៉ុន្តែ ពុំសូវមានសកម្មភាពដោយសារកង្វះខាតទឹកសំរាប់ការស្រោចស្រព។

### (២៣) ការវិភាគភាពខ្លាំង, ភាពខ្សោយ, ឱកាស និងការគំរាមកំហែងនៃស្ថាប័នរដ្ឋាភិបាល: (៤.១០.៧)

ការវិភាគភាពខ្លាំង, ភាពខ្សោយ, ឱកាស និងការគំរាមកំហែង ត្រូវបានសិក្សាឡើងនៅក្នុងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងនៅមន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីរកសិកម្ម នៃខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល។ លទ្ធផលនៃការសិក្សានេះ បានបង្ហាញឱ្យឃើញពីចំណង់ចំណូលចិត្ត និងការលើកទឹក ចិត្តក្នុងការងារ គឺមានសារៈសំខាន់ណាស់ដើម្បីសំរេចបាននូវបេសកកម្ម និងសហការជាមួយស្ថាប័នដ៏ទៃផ្សេងទៀត។ ការ កែលំអនូវចំណង់ចំណូលចិត្តពិតណាស់ និងចូលរួមដល់ការអនុវត្តន៍ផែនការប្លង់មេ។ គេបានធ្វើការកត់សំគាល់ថា ចំណង់ ចំណូលចិត្តរបស់មន្ត្រី អាចត្រូវបានជំរុញតាមរយៈការយល់ដឹងពីសារៈសំខាន់នៃការងារ ឬតាមរយៈប្រធានអង្គភាព។ ការ ទទួលស្គាល់របស់ប្រធានអង្គភាព និងស្ថាប័នពីក្រៅដែលពាក់ព័ន្ធអាចជួយលើកទឹកចិត្តដល់មន្ត្រី។

### (២៤) សេវាកម្មគាំទ្រកសិកម្ម: (៤.១១)

សេវាកម្មគាំទ្រកសិកម្មនៅក្នុងតំបន់គោលដៅ មិនត្រូវបានអនុវត្តល្អទេដោយសារបញ្ហាកង្វះថវិកា, ខ្វះការសំរប សំរួល និងខ្វះភាពជាម្ចាស់នៃមន្ទីរកសិកម្មខេត្ត។ ដូចនេះ សេវាកម្មគាំទ្រកសិកម្មនៅក្នុងតំបន់គោលដៅ ធ្វើឡើងដោយ ម្ចាស់ជំនួយ, អង្គការក្រៅរដ្ឋាភិបាល ជំនួសមុខឱ្យមន្ទីរកសិកម្ម។ ការពង្រឹងសេវាកម្មគាំទ្រកសិកម្ម បង្ហាញពីការធ្វើ សមាហរណកម្មល្អ និងអនុវត្តការចូលរួមពីកសិករ។

## ជំពូកទី ៥ សិក្ខាសាលាស្តីពីការគ្រប់គ្រងរដ្ឋនៃគំរោង និងការវាយតំលៃរហ័សនៅជនបទ:

### (២៥) សិក្ខាសាលាស្តីពីការគ្រប់គ្រងរដ្ឋនៃគំរោង: (៥.២)

សិក្ខាសាលាស្តីពីការគ្រប់គ្រងរដ្ឋនៃគំរោង ត្រូវបានរៀបចំឡើងនៅក្នុងក្រសួងធនធានទឹក និងឧតុនិយម, ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងនៅមន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ និង ខេត្តកណ្តាល និងកសិករ ដើម្បីស្វែងរកអំពីបញ្ហា និងដំណោះស្រាយ។ អ្នកពាក់ព័ន្ធបានធ្វើសេចក្តីសន្និដ្ឋាន និងកត់សំគាល់ ថា បញ្ហាសំខាន់ដែលកសិករកំពុងប្រឈមមុខគឺប្រាក់ចំណូលទាប និងផលិតផលកសិកម្មទាប។ វិធានការណ៍ចាំបាច់សំរាប់ ដោះស្រាយបញ្ហាខាងលើនេះ គឺទាមទារឱ្យមានការផ្តល់សេវាកម្មគាំទ្រកសិកម្ម ដើម្បីកែលំអរបៀបដាំដុះនាពេលបច្ចុប្បន្ន និងការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាពខ្ពស់។

### (២៦) សិក្ខាសាលាស្តីពីការវាយតំលៃរហ័សនៅជនបទ: (៥.៣)

សិក្ខាសាលាស្តីពីការវាយតំលៃរហ័សនៅជនបទ ត្រូវបានរៀបចំឡើងក្នុងគោលបំណងក្តាប់ឱ្យបាននូវលក្ខខ័ណ្ឌសេដ្ឋ កិច្ច-សង្គមរបស់កសិករនៅក្នុងតំបន់គោលដៅ។ លទ្ធផលនៃការសិក្សាបានបង្ហាញឱ្យឃើញថា កង្វះខាតប្រព័ន្ធធារាសាស្ត្រ ត្រូវបានចាត់ទុកថាជាបញ្ហាសំខាន់។

## ជំពូកទី ៦: សក្តានុពលធនធានទឹកសំរាប់ការអភិវឌ្ឍន៍កសិកម្ម:

### (២៧) ធនធានទឹក និងផ្ទៃដីស្រោចស្រព: (៦.២. ៦.៣ និង ៦.៤)

លទ្ធភាពនៃធនធានទឹកបំរើឱ្យវិស័យកសិកម្មនៅក្នុងតំបន់គោលដៅរួមមាន: ១) ស្ទឹងព្រែកត្នោត, ២)ស្ទឹងអូរ ក្រាំងអំបិល និង ៣) ដៃស្ទឹងព្រែកត្នោត។ ការសិក្សាអំពីតុល្យភាពទឹក និងតំរូវការទឹកសំរាប់ដំណាំ ត្រូវបានរៀបចំឡើង ដោយផ្អែកលើធារទឹកដែលធានាសំរាប់រយៈពេល ៥ ថ្ងៃ ។ លទ្ធផលនៃការសិក្សាខាងលើ បានបង្ហាញអំពីផ្ទៃដីដែលអាច ទទួលការស្រោចស្រពមានដូចខាងក្រោម:

**ផ្ទៃដីដែលអាចទទួលការស្រោចស្រពដោយស្ទឹងព្រែកត្នោតតាមរយៈទ្វារទឹករលាំងជ្រៃ**

| ធានាបាន | ស្រូវបង្កើនរដូវ-១ (ha) | ស្រូវបង្កើនរដូវ-២ (ha) | ស្រូវមធ្យម (ha) |
|---|---|---|---|
| 80% | 400 | 400 | 5,500 |
| 50% | 3,500 | 3,500 | 13,000 |

*ស្រូវបង្កើនរដូវ-១: ពីខែ មេសា ដល់ខែ សីហា, ស្រូវបង្កើនរដូវ-២: ពីខែ សីហា ដល់ខែ ធ្នូ, ស្រូវមធ្យម: ពីខែ កក្កដា ដល់ខែ ធ្នូ*

**ផ្ទៃដីដែលអាចទទួលការស្រោចស្រពដោយស្ទឹងអូរក្រាំងអំបិល**

| ធានាបាន | ស្រូវបង្កើនរដូវ-១ (ha) | ស្រូវបង្កើនរដូវ-២ (ha) | ស្រូវមធ្យម (ha) |
|---|---|---|---|
| 80% | 115 | 115 | 430 |
| 50% | 250 | 250 | 700 |

*ស្រូវបង្កើនរដូវ-១: ពីខែ មេសា ដល់ខែ សីហា, ស្រូវបង្កើនរដូវ-២: ពីខែ សីហា ដល់ខែ ធ្នូ, ស្រូវមធ្យម: ពីខែ កក្កដា ដល់ខែ ធ្នូ*

**ផ្ទៃដីដែលអាចទទួលការស្រោចស្រពដោយការប្រមូលទឹកទុកនៅចុងរដូវវស្សា**

| ធានាបាន | ស្រូវបង្កើនរដូវ-១ (ha) | ស្រូវបង្កើនរដូវ-២ (ha) | ស្រូវមធ្យម (ha) |
|---|---|---|---|
| 80% | - | - | 600 |
| 50% | - | - | 1,200 |

### (២៨) ការអនុវត្តនៃតទនីយភាពផ្សេងក្នុងការផ្គត់ផ្គង់:

បច្ចុប្បន្ននេះ ដីស្រែដែលស្ថិតនៅផ្នែកខ្សែទឹកខាងលើ បានធ្វើស្រែពីរដងក្នុងមួយឆ្នាំ ចំណែកដីស្រែដែលស្ថិតនៅ ផ្នែកខ្សែទឹកខាងក្រោមវិញ ពុំមានទឹកស្រោចស្រពគ្រប់គ្រាន់ពីប្រឡាយមេ ដោយសារទឹកនៅក្នុងប្រលាយមេមានតិច និងកំពស់ទឹកនៅក្នុងប្រលាយទាប។ ដើម្បីជៀសវាងប្រតិកម្មយ៉ាងធ្ងន់ធ្ងរពីកសិករ សំណើបែងចែកទឹកស្រោចស្រពថ្មី មិន អាចផ្លាស់ប្តូរពីស្ថានស្រោចស្រពបច្ចុប្បន្នភ្លាមៗបានទេ។ ជាក់ស្តែង កសិករដែលនៅផ្នែកខ្សែទឹកខាងលើពឹងផ្អែកទាំង ស្រុងលើការស្រោចស្រពដោយសារកសិករទាំងនោះមានទំហំដីស្រែតូចៗ។

ដោយពិនិត្យលើស្ថានភាពស្រោចស្រពនាពេលបច្ចុប្បន្ន, លទ្ធភាពទឹកមានកំរិត និងផែនការអភិវឌ្ឍន៍នៃគំរោង មជ្ឈមណ្ឌលអភិវឌ្ឍន៍ចំរុះខាងលិចរាជធានីភ្នំពេញនោះ តំបន់គោលដៅត្រូវបែងចែកជាពីរតំបន់: តំបន់ដែលធានាទឹកបាន ៨០% និងតំបន់ដែលធានាទឹកបាន ៥០%។

## ជំពូកទី ៧: បទពិសោធន៍ក្នុងគំរោងគំរូ

### (២៩) បទពិសោធន៍ក្នុងគំរោងគំរូ (៧.១ និង៧.២)

ដូចបានពិពណ៌នាក្នុងជំពូកទី ៨ " គំរោងគំរូកែលំអបច្ចេកវិជ្ជានៅលើវាលស្រែនៃធារាសាស្ត្រកសិកម្ម " និង "គំរោងគំរូកែលំអកសិកម្មស្រោចស្រពដោយទឹកភ្លៀង" ត្រូវបានជ្រើសរើសនៅក្នុងផែនការមេ និងប្រតិបត្តិក្នុងរយៈពេល ១.៧ ឆ្នាំ ចាប់ពី ខែឧសភា ឆ្នាំ ២០០៦ ដល់ ខែ កុម្ភៈ ឆ្នាំ ២០០៨។ ដូច្នេះ បទពិសោធន៍ជាច្រើនត្រូវបានសិក្សា និងទទួលយក។ បទពិសោធន៍ទាំងនេះទាក់ទងនិងការស្រោចស្រព, កសិកម្ម និងស្ថាប័ន។

### (៣០) ប្រតិកម្មចំពោះប្លង់មេ

ក្នុងចំណោមបទពិសោធន៍ទាំងនេះ ខ្លឹមសារមួយទាក់ទងនិងការស្រោចស្រព, កសិកម្ម និងស្ថាប័ន ដែលបានពិពណ៌នា នៅក្នុងផែនការមេ ត្រូវបានជ្រើសរើស និងឆ្លុះបញ្ចាំង ។ បទពិសោធន៍ដែលបានជ្រើសរើសមានដូចខាងក្រោមនេះ :

| ផ្នែក | បទពិសោធន៍ដែលបានជ្រើសរើសជាប្រតិកម្មចំពោះប្លង់មេ |
|---|---|
| ការស្រោចស្រព | - ការអនុវត្ត វិធីស្រោចស្រពឆ្លាស់តាមប្រឡាយថ្នាក់ទី៣<br>- ត្រូវការសម្របសម្រួលរវាងក្រសួងធនធានទឹក និងឧតុនិយម, និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- របៀបប្រមូលថ្លៃសេវាកម្មថ្លៃទឹក<br>-ត្រូវការពិនិត្យកំពស់ទឹកភ្លៀងដើម្បីព្យាករណ៍លក្ខខ័ណ្ឌផ្ទុកទឹកចុងរដូវវស្សា<br>-ការពិនិត្រការប្រើប្រាស់ច្រើនបែបនៃទឹកក្នុងអាងសំរាប់ការប្រមូលទឹកទុកចុងរដូវវស្សា<br>-ការផ្គត់ផ្គង់ទឹកត្រូវអនុវត្តអោយស្របតាមកំណើនដីស្រែដើម្បីបង្កើតការគ្រប់គ្រងទឹកសមស្របក្នុងរដូវប្រមូលទឹកទុក |
| កសិកម្ម | - អនុត្តន៍ការគ្រប់គ្រងទឹកលើស្រែដោយត្រួតពិនិត្យជំរៅទឹកក្នុងស្រែ<br>- អនុវត្តការច្រូតកាត់តាមរបៀបដែលមានស្រាប់នាពេលបច្ចុប្បន្ន ដោយគិតដល់ចំនួនរបស់ម៉ាស៊ីនបោកស្រូវនៅមានកំរិត និងតម្រូវការដឹកជញ្ជូនចំបើងជាចំណីគោ<br>- តម្រូវឱ្យមានការអភិវឌ្ឍន៍បច្ចេកទេស និងការបង្ហាញការដាំដំណាំដីលើ |
| ស្ថាប័ន | -ការចូលរួមរបស់មេឃុំ និងក្រុមប្រឹក្សាឃុំ ដើម្បីពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក<br>-ការពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក សំរាប់ការគ្រប់គ្រងទឹក និងការប្រើប្រាស់ និងថែទាំ<br>- តម្រូវឱ្យបង្កើតក្រុមប្រើប្រាស់ទឹក សំរាប់ធ្វើឱ្យសកម្មភាពសហគមន៍កសិករប្រើប្រាស់ទឹកសមស្រប<br>-ការសម្របសម្រួលរវាង ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ពង្រឹងសមត្ថភាពមន្ទីរតាមបណ្តាខេត្ត |

## ជំពូកទី៨ ទស្សនៈជាមូលដ្ឋាន និងវិធីសាស្រ្តនៃផែនការមេសំរាប់ការអភិវឌ្ឍន៍វិសាលភាពកសិកម្មៈ

### (៣១) តំរូវការនៃការអភិវឌ្ឍន៍វិសាលភាពកសិកម្មៈ (៨.១)

ប្រជាកសិករនៅតំបន់គោលដៅ តែងទទួលរងនូវកង្វះខាតអង្ករជាប្រចាំ ដូច្នេះការបង្កើនផលិតផលស្រូវ គឺជា អាទិភាពចំបង ។ ដើម្បីដោះស្រាយនៅកង្វះខាតអង្ករ ចាំបាច់ត្រូវពង្រីកផ្ទៃដីស្រោចស្រព និងកែលំអទិន្នផលដំណាំតាម រយះការពង្រឹងស្ថាប័ន និងការផ្តល់សេវាទ្រទ្រង់កសិកម្ម ។ បន្ថែមពីលើការបង្កើនផលិតផលស្រូវនៅក្នុងតំបន់គោលដៅ គឺទាមទារឱ្យមានការកែលំអនូវការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រី ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមទៀត ។ ដូចនេះ ចាំបាច់ តំរូវឱ្យមានការអភិវឌ្ឍនវិសាលភាពកសិកម្មនៅក្នុងតំបន់គោលដៅ ។

### (៣២) គោលបំណង និងយុទ្ធសាស្រ្តៈ (៨.២)

គោលបំណងនៃផែនការមេ គឺរៀបចំ និងបង្ហាញពីយុទ្ធសាស្រ្តដើម្បីកែលំអផលិតភាពកសិកម្មនៅក្នុងតំបន់គោល ដៅ ទៅតាមឆ្នាំនិមួយៗជាក់លាក់ ដោយប្រើប្រាស់ធនធានទឹកដែលមានស្រាប់ ។ ផ្អែកលើលទ្ធផលនៃការសិក្សា និងការ អង្កេតបានបង្ហាញថា ***"ការកែលំអផលិតភាពកសិកម្មផ្តោតលើស្រូវ"*** ត្រូវបានជ្រើសរើសជាគោលដៅយុទ្ធសាស្រ្តនៃផែន ការមេ ដែលនឹងត្រូវទទួលបានដោយ ***"វិធីសាស្រ្តកម្មវិធី"*** នៅក្នុងន័យថា ***"ការអភិវឌ្ឍន៍ការស្រោចស្រព និងដោះទឹក, ការអភិវឌ្ឍន៍កសិកម្ម និងស្ថាប័នប្រកបដោយភាពសុខដុម"*** ។




## (៣៣) ការរៀបចំប្លង់អភិវឌ្ឍន៍: (៨.៣)

ផែនការមេ ត្រូវបានរៀបចំឡើងសំរាប់រយះពេលមធ្យមគិតត្រឹមឆ្នាំ ២០១៥ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នា ទៅនឹងគោលនយោបាយជាតិ និងផែនការអភិវឌ្ឍន៍ជាតិ។ រយះពេលគោលដៅនេះត្រូវបានចែកចេញជាពីរ ដំណាក់កាលៈ រយះពេលខ្លី គឺចាប់ផ្តើមពី ឆ្នាំ ២០០៦ ដល់ ២០១០ និងរយះពេលមធ្យម គឺចាប់ផ្តើមពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥។ យោងតាមគោលនយោបាយជាតិ ការធ្វើវិមជ្ឈការត្រូវបានចាត់ទុកជាចំណុចសំខាន់សំរាប់រយះពេលខ្លី និងការធ្វើឯកជនូប នីយ៏កម្មសំរាប់រយះពេលមធ្យម។ ដូចនេះ វិធីសាស្រ្តតំរង់ទិសទៅរកស្ថាប័នមូលដ្ឋាន និងវិធីសាស្រ្តតំរង់ទិសទៅរកកសិករ ត្រូវបានបង្ហាញនៅក្នុងរយះពេលខ្លី និងមធ្យម។

**ការរៀបចំបម្លង់**

| | រយៈពេលខ្លី (2006-2010) | រយៈពេលខ្លី (2006-2010) |
|---|---|---|
| គោលដៅយុទ្ធសាស្រ្តរួម | ការកែលំអផលិតភាពកសិកម្មដោយផ្តោតលើស្រូវ | |
| ចំណុចសំខាន់សំរាប់រយៈពេលនិមួយៗ | ការធ្វើវិមជ្ឈការ → | → |
| | → | ការធ្វើឯកជនូបនីយ៍កម្ម |
| **ការអភិវឌ្ឍន៍ការស្រោចស្រព** | | |
| វិធីសាស្រ្តជាយុទ្ធសាស្រ្ត | ការពង្រីកផ្ទៃដីស្រោចស្រពតាមរយៈការប្រើប្រាស់ធនធានទឹកដែលមានស្រាប់ឱ្យមានប្រសិទ្ធភាព | |
| សកម្មភាពសំខាន់ៗ | -កែលំអប្រព័ន្ធធារាសាស្រ្តដែលមានអាទិភាពខ្ពស់ និងបន្ទាន់<br>-អនុវត្តការគ្រប់គ្រងទឹកឱ្យបានល្អដោយវិធីសាស្រ្តតំរង់ទិទៅស្ថាប័នមូលដ្ឋាន<br>-អនុវត្តការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្រ្ត និងដោះទឹកដោយវិធីសាស្រ្តតំរង់ទិសទៅស្ថាប័នមូលដ្ឋាន. | -កែលំអប្រព័ន្ធធារាសាស្រ្តដោយការចូលរួមរបស់កសិករ<br>-អនុវត្តការគ្រប់គ្រងទឹកឱ្យល្អដោយវិធីសាស្រ្តតំរង់ទិសទៅរកកសិករ<br>- អនុវត្តការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្រ្ត និងដោះទឹកដោយវិធីសាស្រ្តតំរង់ទិសទៅរកកសិករ. |
| **ការអភិវឌ្ឍន៍កសិកម្ម** | កែលំអទិន្នផលដំណាំតាមរយៈបច្ចេកវិជ្ជាកសិកម្មសមស្រប និងពង្រឹងសេវាទ្រទ្រង់ | |
| វិធីសាស្រ្តជាយុទ្ធសាស្រ្ត | | |
| សកម្មភាពសំខាន់ៗ | -ជំរុញការអភិវឌ្ឍន៍កសិកម្មនៅក្នុងប្រព័ន្ធធារាសាស្រ្តដែល មានអាទិភាពខ្ពស់<br>- សេវាទ្រទ្រង់កសិកម្មដោយវិធីសាស្រ្តតំរង់ទិសទៅរកស្ថាប័នមូលដ្ឋាន។ | - ការអភិវឌ្ឍន៍កសិកម្មផ្តួចផ្តើមដោយកសិករនៅក្នុងតំបន់ស្រោចស្រព។<br>-<br>សេវាទ្រទ្រង់កសិកម្មដោយវិធីសាស្រ្តតំរង់ទិស |
| **ការអភិវឌ្ឍន៍ស្ថាប័ន** | | |
| វិធីសាស្រ្តជាយុទ្ធសាស្រ្ត | រៀបចំសមាគមកសិករ និងការអភិវឌ្ឍន៍សមត្ថភាពរបស់ស្ថាប័នមូលដ្ឋាន | |
| សកម្មភាពសំខាន់ៗ | - ការរៀបចំ និងចាត់ចែងថវិកាឱ្យបានល្អ<br>- ពង្រឹងការសំរបសំរួលរវាងក្រសួងធនធានទឹក និងក្រសួងកសិកម្ម។<br>- ការអភិវឌ្ឍន៍សមត្ថភាពនៅស្ថាប័នមូលដ្ឋាន។<br>- រៀបចំសហគមន៍កសិករប្រើប្រាស់ទឹក និងសមាគមកសិករដ៏ទៃទៀត។<br>- ចាប់ផ្តើមកសាងសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក និងសមាគម កសិករដ៏ទៃទៀត។ | - រៀបចំសហគមន៍កសិករប្រើប្រាស់ទឹក និងសមាគម កសិករចាំបាច់ដ៏ទៃទៀតសំរាប់ប្រព័ន្ធធារាសាស្រ្ត។<br>- កសាងសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក និងសមាគមកសិករចាបាច់ដ៏ទៃទៀត។<br>- ត្រួតពិនិត្យ និងវាយតំលៃសកម្មភាពអាជ្ញាធរមូលដ្ឋាន, សហគមន៍កសិករប្រើប្រាស់ទឹក និងសមាគមកសិករចាំបាច់ផ្សេងដ៏ទៃទៀត។ |

## (៣៤) ការកំណត់តំបន់នៅក្នុងតំបន់គោលដៅ: (៨.៤)

នៅក្នុងតំបន់គោលដៅ បានបង្ហាញពីភាពផ្សេងគ្នារវាងប្រភពទឹកដែលអាចរកបាន និងការប្រើប្រាស់ដី។ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នារវាងផែនការអភិវឌ្ឍនីវិសាលភាពកសិម្ម និងលក្ខខ័ណ្ឌជាក់ស្តែងនៅមូលដ្ឋាន ការកំណត់តំបន់ដាំដុះគឺជាវិធីសាស្រ្តសមស្របដែលត្រូវបានកំណត់ជាពិសេសសំរាប់ដំណាំរួមផ្សំ ដែលជាប្រភពចំណូលដ៏សំខាន់របស់ប្រជាកសិករនៅក្នុងតំបន់គោលដៅ។ ខាងក្រោមនេះ គឺជាលទ្ធផលនៃការកំណត់តំបន់ដាំដុះនៅក្នុងតំបន់គោលដៅ។




## (៣៥) ការរៀបចំក្របខ័ណ្ឌ និងទស្សនមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍វិសាលភាពកសិកម្មៈ (៨.៥)

មានបញ្ហា និងឧបសគ្គជាច្រើន នៅក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម ដែលបានរកឃើញតាមរយៈសិក្ខាសាលាស្តីពី ការគ្រប់គ្រងវដ្តគំរោង, ការវាយតំលៃយ៉ាងឆាប់រហ័សនៅជនបទ, ការអង្កេតសេដ្ឋកិច្ច-សង្គម និងការវិភាគលើភាព ខ្លាំង, ភាពខ្សោយ, ឱកាស និងការគំរាមកំហែង ព្រមទាំងការចុះពិនិត្យការដ្ឋានដោយក្រុមសិក្សាអង្គការ JICA ។

ផ្អែកលើលទ្ធផលនៃការវិភាគអំពីបញ្ហា និងឧសគ្គនានា ទិសដៅកម្មវិធីត្រូវបានស្នើឡើង ដូចខាងក្រោមនេះ

**គំនូសបំព្រួញនៃវិធីសាស្រ្តក្នុងការអភិវឌ្ឍន៍វិសាលភាពកសិកម្ម**




### <u>ការកែលំអគំរោងហេដ្ឋារចនាសម្ព័ន្ធៈ</u>

អភិក្រមក្នុងការកែលំអគំរោងហេដ្ឋារចនាសម្ព័ន្ធ គឺមានគោលបំណងនាំមកនូវអត្ថប្រយោជន៍ផ្ទាល់ពីគំរោង។ ការកែលំអគំរោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានបែងចែកជាពីរតំបន់ គឺតំបន់ផ្អែកលើវិធីសាស្រ្ត (Zone Based Approach) និងតំបន់ទាក់ទងគ្នា(Zone Crosscutting Approach) ។ នៅក្នុងតំបន់ផ្អែកលើវិធីសាស្រ្ត គំរោងស្រោចស្រពកសិកម្មស្ថិតនៅក្នុងតំបន់ ១ ដល់តំបន់ ៣ និងតំបន់កសិកម្មស្រោចស្រពដោយទឹកភ្លៀងស្ថិតនៅ ក្នុងតំបន់ ៤ ។ គំរោងនេះរៀបចំឡើង ក្នុងគោលបំណងកែលំអផលិតភាពកសិកម្មដោយផ្តោតលើស្រូវនៅក្នុង តំបន់គោលដៅ ហើយចូលរួមចំណែកធ្វើឱ្យមានស្រូវអង្ករគ្រប់គ្រាន់នៅក្នុងតំបន់គោលដៅ។ តំបន់ផ្អែកលើគំរោង

ត្រូវអនុវត្តដោយរបៀបសមាហរណកម្មផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេវាទ្រទ្រង់។ នៅក្នុងតំបន់ទាក់ទងគ្នា ការ អភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីមានទំនាក់ទំនងគ្នាខ្លាំងណាស់ ទៅនឹងតំបន់គោលដៅ ដោយចាត់ទុកថា ជា មធ្យោបាយដ៏ទូលំទូលាយមួយ។ ចំពោះការចិញ្ចឹមត្រី និងការចិញ្ចឹមសត្វ ផលិតផលនេះ នឹងកើនឡើងដោយការ កែលំអប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្ន មិនចាំបាច់គិតដល់ការកំណត់តំបន់។ នៅក្នុងតំបន់គោលដៅ កសិករមួយចំនួន មានផ្ទៃដីស្រែតិចតួចបើទោះបីជាកសិករទាំងនោះមិនមានភាពលើសលប់។ ការបង្កើនប្រាក់ចំណូលដល់កសិករទាំង នេះ នឹងត្រូវបានពិចារណាលើទស្សនៈនៃការកាត់បន្ថយភាពក្រីក្រ។

**<u>ផែនការកែលំអសេវាទ្រទ្រង់:</u>**

ការអភិវឌ្ឍន៍សុខុដមនីយ៏កម្មល្អនៃទិដ្ឋភាពរឹង និងទិដ្ឋភាពទុន គឺមិនអាចខានបាន ក្នុងការសំរេចនូវការកែលំអគំរោងហេដ្ឋារចនាសម្ព័ន្ធ ដូចនេះ អភិក្រមនៃការកែលំអសេវាទ្រទ្រង់ត្រូវបានអនុវត្តយ៉ាងល្អិតល្អន់។ អភិក្រមក្នុងការកែលំអសេវាទ្រទ្រង់ គឺការគាំទ្រដល់គំរោងកែលំអសេវាទ្រទ្រង់ដោយផ្តើមចេញពីទស្សនៈ បច្ចេកទេស, ស្ថាប័ន, សង្គម និងបរិស្ថាន។ ជាលទ្ធផល ការសិក្សា ឬគំរោងកែលំអសេវាទ្រទ្រង់ បានលើកដំកើងប្រសិទ្ធភាព និងនិរន្តរភាពនៃគំរោងការនេះ។ នៅក្នុងគំរោងការខាងលើនេះ គំរោងគំរូជាច្រើនត្រូវបានរៀបចំឡើង ដើម្បីពិនិត្យ ឡើងវិញនូវបច្ចេកវិជ្ជាសមស្រប ចំពោះការគ្រប់គ្រងទឹក, ការអនុវត្តការដាំដុះ និងការចិញ្ចឹមត្រី។

## (៣៦) បញ្ជីឈ្មោះគំរោង/សិក្សាស្នើសុំ (៨.៥.២)

ផ្អែកលើអភិក្រមដែលបានរៀបរាប់ពីខាងលើ គំរោង/ការសិក្សា លំអិត សំរាប់ផែនការ ការកែលំអគំរោងហេដ្ឋា រចនាសម្ព័ន្ធ និងផែនការកែលំអសេវាទ្រទ្រង់ មានដូចខាងក្រោម:

**បញ្ជីឈ្មោះគំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធ និងគំរោងកែលំអសេវាទ្រទ្រង់**

| | | |
|---|---|---|
| | | **គំរោងកែលំពហេដ្ឋារចនាសម្ព័ន្ធ** |
| | **តំបន់ ១** | |
| 1 | A.1(1) | គំរោងគំរូកែលំអធារាសាស្ត្រកសិកម្ម |
| 2 | A.1(2) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅផ្នែកខ្សែទឹកខាងលើនៃប្រឡាយមេខាងជើង |
| 3 | A.1(3) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅផ្នែកខ្សែទឹកខាងលើនៃប្រឡាយមេខាងត្បូង |
| | **តំបន់ ២** | |
| 4 | A.2(1) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅផ្នែកខ្សែទឹកខាងក្រោមនៃប្រឡាយមេខាងជើង |
| 5 | A.2(2) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅផ្នែកខ្សែទឹកខាងក្រោមនៃប្រឡាយមេខាងត្បូង |
| 6 | A.2(3) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅអូក្រាំងអំបិល |
| | **តំបន់ ៣** | |
| 7 | A.3(1) | គំរោងកែលំអធារាសាស្ត្រកសិកម្មដោយការរក្សាទឹកទុកនៅចុងរដូវវស្សា |
| | **តំបន់ ៤** | |
| 8 | A.4(1) | គំរោងកែលំអកសិកម្មស្រោចស្រពដោយទឹកភ្លៀង |
| | **គំរោងឆ្លងកាត់តំបន់** | |
| 9 | B.1(1) | គំរោងកែលំអទ្វារទឹករលាំងជ្រៃជាបន្ទាន់ |
| 10 | B.1(2) | គំរោងកែលំអទ្វារទឹករលាំងជ្រៃ និងទ្វារទឹកចែកចាយទឹក |
| 11 | B.2(1) | គំរោងកែលំអការចិញ្ចឹមសត្វ និងពង្រឹងសេវាបសុសត្វ |
| 12 | B.3(1) | គំរោងអភិវឌ្ឍន៍សហគមន៏ចិញ្ចឹមត្រី |
| 13 | B.5(1) | គំរោងបង្កើនប្រាក់ចំណូលដល់កសិករ |
| | | **គំរោងកែលំអសេវាកម្ម** |
| 14 | C.1(1) | គំរោងពង្រឹងកិច្ចសំរបសំរួលជាមួយក្រសួងធនធានទឹក និងឧតុនិយម ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| 15 | C.1(2) | គំរោងពង្រឹងសមត្ថភាពមន្ទីរតាមបណ្តាខេត្តក្នុងតំបន់គំរោង |
| 16 | C.2(1) | គំរោងសិក្សាអភិវឌ្ឍន៍ការចិញ្ចឹមសត្វ |
| 17 | C.3(1) | គំរោងរៀបចំគោលការណ៏ណែនាំបច្ចេកទេស |
| 18 | C.4(1) | គំរោងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងបរិស្ថាន |
| 19 | C.4(2) | គំរោងតាមដានការគ្រប់គ្រងបរិស្ថាន |
| 20 | C.5(1) | គំរោងគំរូកែលំអបច្ចេកវិជ្ជានៅលើវាលស្រែនៃធារាសាស្ត្រកសិកម្ម |
| 21 | C.6(1) | គំរោងគំរូពង្រឹងសមត្ថភាពការថែទាំសំណង់ធារាសាស្ត្រ |

| | | |
|---|---|---|
| 22 | C.7(1) | គំរោងគំរូកែលំអកសិកម្មស្រោចស្រពដោយទឹកភ្លៀង |
| 23 | C.8(1) | គំរោងគំរូអភិវឌ្ឍន៍សហគមន៍ជលផល |
| 24 | C.9(1) | គំរោងគំរូបង្កើនការយល់ដឹងស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក |
| 25 | C.10(1) | គំរោងពង្រឹងសេវាកម្មទ្រទ្រង់កសិកម្ម និងស្ថាប័ន |
| 26 | C.11(1) | គំរោងពង្រឹងការអង្កេតជលសាស្ត្រ |
| 27 | C.11(2) | ការព្យាករណ៍ទឹកជំនន់ និងការសិក្សាការជូនដំណឹង |

ក្របខ័ណ្ឌរួមសំរាប់ការអភិវឌ្ឍន៍វិសាលភាពកសិកម្មបង្ហាញនៅក្នុងតារាងលេខ ១។

## ជំពូកទី ៩ ការរៀបចំផែនការមេសំរាប់ការអភិវឌ្ឍន៍វិសាលភាពកសិកម្ម

### (៣៧) ម៉ាទ្រីសឡូជីកកម្មវិធី (៩.២)

គំរោងចំនួន ២៧ ត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យសំរេចបាននូវគោលដៅយុទ្ធសាស្ត្រនៃការកែលំអផលិតភាពកសិកម្មដោយផ្តោតលើស្រូវ នៅក្នុងតំបន់គោលដៅដោយប្រើប្រាស់ វិធីកម្មវិធី។ ដើម្បីបញ្ជាក់ទំនាក់ទំនងរវាង គោលនយោបាយរួម និងលទ្ធផល, លទ្ធផលមធ្យមសំរាប់រយៈពេលកណ្តាលអាណត្តិ, លទ្ធផលចុងអាណត្តិ និងសំណើ គំរោងខាងលើនៅក្នុង វិធីកម្មវិធីក្របខ័ណ្ឌតក្កៈត្រូវបានរៀបចំឡើង និងបង្ហាញនៅក្នុងតារាងលេខ ២។

តារាងលេខ ២ [illegible]

| | | | |
|---|---|---|---|
| [illegible] | OP: [illegible] | | |
| [illegible] | EO-1: [illegible] ([illegible] 1999-2010, [illegible]) | | |
| [illegible] | IO-1: [illegible] | | |
| [illegible] | O-1: [illegible] ([illegible] 1996-2010, [illegible]) | | |
| | O-1-1: [illegible] | O-1-2: [illegible] | O-1-3: [illegible] |
| | " [illegible] " | " [illegible] " | " [illegible] " |
| [illegible]<br>(1) [illegible] | | | |
| (a) [illegible] | | | |
| A.1(1) [illegible] | ○ | ○ | ○ |
| A.1(2) [illegible] | ○ | ○ | ○ |
| A.1(3) [illegible] | ○ | ○ | ○ |
| (b) [illegible] | | | |
| A.2(1) [illegible] | ○ | ○ | ○ |
| A.2(2) [illegible] | ○ | ○ | ○ |
| A.2(3) [illegible] | ○ | ○ | ○ |
| (c) [illegible] | | | |
| A.3(1) [illegible] | ○ | ○ | ○ |
| (d) [illegible] | | | |
| A.4(1) [illegible] | ○ | — | ○ |
| (e) [illegible] | | | |
| B.1(1) [illegible] | — | ○ | — |
| B.1(2) [illegible] | — | ○ | — |
| B.2(1) [illegible] | ○ | — | ○ |
| | | | |
| B.3(1) [illegible] | ○ | — | ○ |
| B.4(1) [illegible] | ○ | — | ○ |
| (2) [illegible] | | | |
| C.1(1) [illegible] | — | — | ○ |
| C.1(2) [illegible] | — | — | ○ |
| C.2(1) [illegible] | ○ | — | ○ |
| C.3(1) [illegible] | — | ○ | — |
| C.4(1) [illegible] | — | — | ○ |
| C.4(2) [illegible] | — | — | ○ |
| C.5(1) [illegible] | ○ | ○ | ○ |
| C.6(1) [illegible] | — | ○ | ○ |
| C.7(1) [illegible] | ○ | — | ○ |
| C.8(1) [illegible] | ○ | — | ○ |
| C.9(1) [illegible] | — | ○ | ○ |
| C.10(1) [illegible] | ○ | ○ | ○ |
| C.11(1) [illegible] | — | ○ | — |
| C.11(2) [illegible] | ○ | ○ | ○ |

## (៣៨) ការកែលំអគំរោងហេដ្ឋារចនាសម្ព័ន្ធ (៩.៣)

គំរោងចំនួន ១៣ ត្រូវបានគ្រោងឡើង និងចងក្រងជាឯកសារនៃគំរោង, រយៈពេលនៃការអនុវត្តន៍គំរោង និង តារាងម៉ាទ្រីសរៀបចំគំរោង។ គោលបំណងនៃការរៀបចំគំរោងទាំងនេះ មានដូចខាងក្រោមនេះ:

| លេខកូដ | ឈ្មោះគំរោង | គោលបំណង |
|---|---|---|
| **វិធីផ្អែកតាមមូលដ្ឋានតំបន់** | | |
| **តំបន់ ១** | | |
| 1.A.1(1) | គំរោងគំរូកែលំអធារាសាស្ត្រកសិកម្ម។ | ធ្វើបទបង្ហាញការគ្រប់គ្រងទឹកសមស្រប ហើយបង្កើនផលិតផលស្រូវនៅក្នុងតំបន់គំរូ (៥៧០ ហិកតា) ដោយធ្វើសុខដុមរូបនីយកម្មនៃកសិកម្ម, ការស្រោចស្រព, ការដោះទឹក និងការអភិវឌ្ឍន៍ ស្ថាប័ន។ |
| 2.A.1(2) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅប្រឡាយមេខាងជើងផ្នែកខាងលើ។ | បង្កើនផលិតផលស្រូវនៅតំបន់ខាងជើងផ្នែកខាងលើ (២,២១០ ហិកតា) ដោយកែលំអប្រព័ន្ធធារា សាស្ត្រ និងពង្រឹងសេវាទ្រទ្រង់ កសិកម្ម និង ស.ក.ប.ទ។ |
| 3.A.1(3) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅប្រឡាយមេខាងត្បូងផ្នែកខាងលើ។ | បង្កើនផលិតផលស្រូវនៅតំបន់ខាងត្បូងផ្នែកខាងលើ (២,៨៨០ ហិកតា) ដោយកែលំអប្រព័ន្ធធារា សាស្ត្រ និងពង្រឹងសេវាទ្រទ្រង់ កសិកម្ម និង ស.ក.ប.ទ។ |
| **តំបន់ ២** | | |
| 4.A.2(1) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅប្រឡាយមេខាងជើងផ្នែកខាងក្រោម។ | បង្កើនផលិតផលស្រូវនៅតំបន់ខាងជើងផ្នែកខាងក្រោម (១,៣៩០ ហិកតា) ដោយកែលំអប្រព័ន្ធធារា សាស្ត្រ និងពង្រឹងសេវាទ្រទ្រង់ កសិកម្ម និង ស.ក.ប.ទ។ |
| 5.A.2(2) | គំរោងកែលំអធារាសាស្ត្រកសិកម្មនៅប្រឡាយមេខាងត្បូងផ្នែកខាងក្រោម។ | បង្កើនផលិតផលស្រូវនៅតំបន់ខាងជើងផ្នែកខាងក្រោម (៦,៧៥០ ហិកតា) ដោយកែលំអប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសេវាទ្រទ្រង់ កសិកម្ម និង ស.ក.ប.ទ។ |
| 6.A.2(3) | គំរោងកែលំអធារាសាស្ត្រកសិកម្មអូក្រាំងអំបិល។ | បង្កើនផលិតផលស្រូវនៅតំបន់អូក្រាំងអំបិល (២,៩០០ ហិកតា) ដោយកែលំអប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសេវាទ្រទ្រង់កសិកម្ម និង ស.ក.ប.ទ។ |
| **តំបន់ ៣** | | |
| 7.A.3(1) | គំរោងកែលំអធារាសាស្ត្រកសិកម្មដោយការរក្សាទឹកទុកនៅចុងរដូវវស្សា។ | បង្កើនផលិតផលស្រូវនៅតំបន់ ៣ (១,២០០ ហិកតា) ដោយកែលំអប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសេវាទ្រទ្រង់កសិកម្ម និង ស.ក.ប.ទ។ |
| **តំបន់ ៤** | | |
| 8.A.4(1) | គំរោងកែលំអកសិកម្មពឹងទឹកភ្លៀង។ | កែលំអផលិតភាពកសិកម្មពឹងទឹកភ្លៀង និងបង្កើនផលិតផលស្រូវ នៅក្នុងតំបន់ ៤ នៃតំបន់គោលដៅ។ |
| **តំបន់ឆ្លងកាត់** | | |
| 9.B.1(1) | គំរោងកែលំអជាបន្ទាន់ទ្វារទឹករលាំងជ្រៃ។ | ធានាការប្រើប្រាស់ទ្វារទឹកឱ្យបានសមស្របសំរាប់ផ្គត់ផ្គង់ទឹកស្រោចស្រព និងទឹកជំនន់។ |
| 10.B.1(2) | គំរោងកែលំអទ្វារទឹករលាំងជ្រៃ និង សំណង់ចែកចាយទឹក។ | ផ្គត់ផ្គង់ទឹកស្រោចស្រពឱ្យបានទៀងទាត់ដល់ប្រឡាយមេដោយកែលំអទ្វារទឹករលាំងជ្រៃ និងទ្វារទឹកអណ្តូងស្លា និងទ្វារទឹកវត្តក្រូច។ |
| 11.B.2(1) | ពង្រឹងសេវាបសុពេទ្យ និងគំរោងកែលំអបង្កើនការចិញ្ចឹមសត្វ។ | ជ្រើសរើសភ្នាក់ងារចិញ្ចឹមសត្វថ្មីប្រចាំភូមិ ឬជំរុញភ្នាក់ងារចិញ្ចឹមសត្វដែលមានស្រាប់ ជាអ្នកផ្តល់សេវាផ្សព្វផ្សាយការចិញ្ចឹមសត្វ និងសុខភាពសត្វ ពាហនៈ។ |
| 12.B.3(1) | គំរោងគំរូអភិវឌ្ឍន៍សហគមន៍ចិញ្ចឹមត្រី។ | - ជំរុញការចិញ្ចឹមត្រីក្នុងទឹកនៃគំរោងកែលំអធារាសាស្ត្រកសិកម្មដោយរក្សាទឹកទុកនៅចុងរដូវ។ |

| | | |
|---|---|---|
| | | - ប្រមូលថវិការួមរបស់សហគមន៍ប្រើប្រាស់ទឹកសំរាប់ធានាដល់ការប្រើ ប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ។ |
| 13.B.1(1) | គំរោងបង្កើនប្រាក់ចំណូលបន្ថែមដល់កសិករ។ | បង្កើនប្រាក់ចំណូលបន្ថែមដល់កសិករ និងកែលំអកំរិតសន្តិសុខស្បៀង, ដែល ចូលរួមដល់ សន្តិសុខមនុស្សជាតិ និងកាត់បន្ថយក្រុមដែលងាយទទួលរង គ្រោះថ្នាក់។ |

## (៣៩) ការកែលំអសេវាទ្រទ្រង់: (៩.៤)

គំរោងចំនួន ១៤ ត្រូវបានជ្រើសរើស ហើយបានចងក្រងជាសំណើគំរោង, ការកំណត់ពេលវេលានៃការអនុវត្តន៍ គំរោង និងតារាងម៉ាទ្រីសរៀបចំគំរោង។ គោលបំណងនៃគំរោងទាំងនេះ មានដូចខាងក្រោមនេះ:

| លេខកូដ | ឈ្មោះគំរោង | គោលបំណង |
|---|---|---|
| 1.C.1(1) | គំរោងពង្រឹងកិច្ចសំរបសំរួលរវាងក្រសួង ធនធានទឹក និងឧតុនិយម ជាមួយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ | កែលំអកិច្ចសំរបសំរួលរវាងក្រសួងធនធានទឹក និងឧតុនិយម ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំរាប់ការអនុវត្តន៍គំរោងធារាសាស្ត្រកសិកម្មឱ្យមាន ប្រសិទ្ធភាព និងមានភាពរលូន។ |
| 2.C.1(2) | គំរោងពង្រឹងសមត្ថភាពមន្ទីរនៅតាមខេត្ត | ពង្រឹងសមត្ថភាពមន្ទីរខេត្ត ក្នុងការអនុវត្តន៍គំរោងធារាសាស្ត្រកសិកម្ម ឱ្យមាន ប្រសិទ្ធភាព និងមានភាពរលូន។ |
| 3.C.2(1) | ការសិក្សាអភិវឌ្ឍន៍ការចិញ្ចឹមសត្វ។ | រៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមសត្វចំរុះនៅក្នុងតំបន់គោលដៅសំរាប់ការអភិវឌ្ឍន៍រយះពេលមធ្យម និងវែង។ |
| 4.C.3(1) | គំរោងរៀបចំគោលការណ៍ណែនាំបច្ចេក ទេស។ | រៀបចំគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធដល់ការស្រោចស្រពដូចជា: ១- ផែនការស្រោចស្រព ២- គ្រោងប្លង់សំណង់ធារាសាស្ត្រ ៣- ការត្រួតពិនិត្យការ សាងសង់សំណង់ធារាសាស្ត្រ និង ៤- ការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ។ ការយកចិត្តទុកដាក់ជាពិសេសលើប្រភេទដី ដែលមានភាពងាយរលាយ។ |
| 5.C.4(1) | គំរោងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រង បរិស្ថាន។ | ពង្រឹងសមត្ថភាពមូលដ្ឋានដល់មន្ត្រីពាក់ព័ន្ធនៃក្រសួង ធ.ទ.ឧ និងក្រសួង ក.រ.ន ទាក់ទងនឹងការវាយតំលៃផលប៉ះពាល់បរិស្ថាន និងការគ្រប់គ្រងបរិស្ថាន។ |
| 6.C.4(2) | គំរោងតាមដានការគ្រប់គ្រងបរិស្ថាន។ | តាមដានសកម្មភាពគ្រប់គ្រងបរិស្ថាន និងការរំលោះសមត្ថកិច្ចរបស់មន្ត្រីពាក់ព័ន្ធ នៃ ក្រសួង ធ.ទ.ឧ និងក្រសួង ក.រ.ន ។ |
| 7.C.5(1) | គំរោងគំរូកែលំអបច្ចេកវិជ្ជាកសិកម្មលើ វាលស្រែ។ | បង្កើតម៉ូដែលការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនៅលើវាលស្រែនៅក្នុងតំបន់ ធារាសាស្ត្រកសិកម្ម។ |
| 8.C.6(1) | គំរោងគំរូពង្រឹងសមត្ថភាពថែទាំសំណង់ ធារាសាស្ត្រ។ | បង្កើតម៉ូដែលល្អនៃការថែទាំសំណង់ធារាសាស្ត្រនៅក្នុងតំបន់ធារាសាស្ត្រកសិកម្ម។ |
| 9.C.7(1) | គំរោងគំរូកែលំអកសិកម្មពឹងទឹក ភ្លៀង។ | រៀបចំប្រព័ន្ធកែលំអផលិតកម្មស្រូវក្នុងតំបន់កសិកម្មពឹងទឹកភ្លៀង។ |
| 10.C.8(1) | គំរោងគំរូអភិវឌ្ឍន៍សហគមន៍ចិញ្ចឹម ត្រី។ | បង្កើតម៉ូដែលផលិតនៃសហគមន៍ចិញ្ចឹមត្រី។ |
| 11.C.9(1) | គំរោងបង្កើនចំណេះដឹងស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក។ | បង្កើនការយល់ដឹង និងចំណេះដឹងរបស់កសិករស្តីពីការប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធ ភាព ដោយបង្ហាញពីលទ្ធផលដែលបានមកពី " គំរោងគំរូកែលំអបច្ចេកវិជ្ជាធារាសាស្ត្រ កសិកម្មនៅលើវាលស្រែ" ។ |
| 12.C.10(1) | គំរោងសេវាទ្រទ្រង់កសិកម្ម និង ស្ថាប័ន។ | - បង្កើតស្ថាប័នទទួលខុសត្រូវសំរាប់ជំរុញការកែលំអកសិកម្មដោយផ្តោតលើស្រូវនៅ ដំណាក់កាលដំបូងនៃផែនការមេ។<br>- ជំរុញការផ្សព្វផ្សាយនៃការកែលំអ និងនិរន្តរភាពបច្ចេកទេសស្តីពីផលិតកម្មស្រូវ។<br>- ជំរុញការផ្សព្វផ្សាយនៃការគ្រប់គ្រងទឹកស្រោចស្រព និងបច្ចេកទេសលើការថែទាំ និងប្រើប្រាស់ និងការអនុវត្តន៍ប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព។<br>- រៀបចំ និងជំរុញស.ក.ប.ទ និងក.ក.ប.ទ ព្រមទាំងសហគមន៍កសិករដ៏ទៃ ផ្សេងទៀត។ |

| លេខកូដ | ឈ្មោះគំរោង | គោលបំណង |
|---|---|---|
| 13.C.11(1) | គំរោងពង្រឹងការអង្កេតជលសាស្ត្រ។ | ពង្រឹងប្រព័ន្ធទទួលទិន្នន័យជលសាស្ត្រសំរាប់គំរោងដែលពាក់ព័ន្ធនឹងធនធានទឹក។ |
| 14.C.11(2) | ការសិក្សាជូនដំណឹង និងការព្យាករណ៍ ទឹកជំនន់។ | រៀបចំផែនការប្រព័ន្ធជូនដំណឹង និងព្យាករណ៍ទឹកជំនន់សំរាប់កាត់បន្ថយការខូចខាតដោយទឹកជំនន់នៅផ្នែកខាងក្រោមនៃអាងស្ទឹងព្រែកត្នោត។ |

## (៤០) ផែនការអនុវត្តន៍: (៩.៥)

គំរោងចំនួន ២៧ នឹងត្រូវបានអនុវត្តន៍តាមលំដាប់ថ្នាក់នៃអាទិភាព ដើម្បីបង្កើនប្រសិទ្ធភាព និងអត្ថប្រយោជន៍ ទៅតាមផែនការ។ ដើម្បីរៀបចំផែនការអនុវត្តន៍ឱ្យបានល្អិតល្អន់នៃគំរោងខាងលើលក្ខណ:វិនិច្ឆ័យ ដូចខាងក្រោមនេះ ត្រូវបានយកមកអនុវត្តន៍:

- រយះពេល ៥ ឆ្នាំដំបូង ដែលចាប់ ពី ២០០៦ ដល់ ២០១០ ក្នុងរយះពេល ១០ឆ្នាំ នឹងត្រូវផ្តោតលើ " ការធ្វើ វិមជ្ឈការ " ហើយរយះពេល ៥ ឆ្នាំចុងក្រោយ ដែលចាប់ ពី ២០១០ ដល់ ២០១៥ ត្រូវផ្តោត លើ "ការធ្វើឯកជនូបនីយ៍កម្ម " ទោះបីជាវាគួតែត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ ២០០៦។ ដូចនេះ ការ អនុវត្តន៍គំរោងស្នើឡើងនេះ ត្រូវផ្តោតលើលក្ខណ:វិនិច្ឆ័យខាងលើនេះ។
- គំរោងគំរូចំនួន ៤ កន្លែង ក្នុងចំណោមគំរោងចំនួន ២៧ ត្រូវបានយកមកអនុវត្តដើម្បីធ្វើជាស្ថានចំលងក្នុង ការទទួលបាន និងឆ្លុះបញ្ចាំងនូវមេរៀនពីអតីតកាលចំពោះគំរោងកែលំអកសិកម្មដោយទឹកភ្លៀង និងគំរោង កែលំអប្រព័ន្ធធារាសាស្ត្រខ្នាតធំជាបន្តបន្ទាប់។ ដូចនេះ គំរោងគំរូត្រូវតែអនុវត្តន៍នៅក្នុងដំណាក់កាលដំបូង នៃគំរោង។
- ដូចបានពិពណ៌នាជាញឹកញាប់ថា វិធីសាស្ត្រសមាហរណកម្មនៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាទ្រទ្រង់មានសារៈ សំខាន់ណាស់ក្នុងការធ្វើឱ្យសំរេចបាននូវគោលដៅតាមផែនការដែលបានគ្រោងទុក។ បញ្ហានេះ ត្រូវបាន ពិចារណានៅក្នុងការរៀបចំផែនការអនុវត្តន៍។
- ក្នុងការកែលំអផ្នែកធារាសាស្ត្រកសិកម្ម ការអនុវត្តន៍ត្រូវចាប់ផ្តើមពីផ្នែកខ្សែទឹកខាងលើ ទៅផ្នែកខ្សែទឹក ខាងក្រោមដើម្បីធានាដល់អត្ថប្រយោជន៍នៃគំរោងនាប់ៗដែលអាចធ្វើទៅបាន។ និតិវិធីនេះត្រូវបានបង្ហាញ នៅក្នុងផែនការអនុវត្តន៍គំរោង។

## (៤១) តំរូវការថវិកា: (៩.៥)

តំលៃគំរោងចំនួន ២៧ កន្លែង ត្រូវបានប៉ាន់ស្មានតំលៃចំនួន ៧៥.១៥៣ លានដុល្លារអាមេរិក ហើយថវិកា នេះ ត្រូវបានបែងចែកតាមឆ្នាំនិមួយៗដូចខាងក្រោម:

តំលៃគំរោង

| | | | គំរោង_ការសិក្សា | តំលៃសរុប | 200 | 200 | 200 | 200 | 201 | 201 | 201 | 201 | 201 | 201 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| (1) | **គំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | |
| | ក | តំបន់ ១ | | | | | | | | | | | | |
| | | ក.1(1) | គំរោងគំរូកែលំអធារាសាស្ត្រកសិកម្ម | 1,67 | | | | 73 | 91 | 1 | 1 | 4 | | |
| | | ក.1(2) | គំរោងកែលំអធារាសាស្ត្រកសិកមផ្នែកខាងលើនៃប្រលាយមេខាងជើង | 11,33 | | | | | | 71 | 2,73 | 5,45 | 2,18 | 25 |
| | | ក.1(3) | គំរោងកែលំអធារាសាស្ត្រកសិកមផ្នែកខាងលើនៃប្រលាយមេខាងត្បូង | 9,87 | | | | | | 54 | 2,10 | 4,46 | 2,39 | 35 |
| | ខ | តំបន់ ២ | | | | | | | | | | | | |
| | | ក .2(1) | គំរោងកែលំអធារាសាស្ត្រកសិកម្មផ្នែកខាងក្រោមប្រលាយមេខាងជើង | 3,19 | | | | | | | 965 | 1,55 | 67 | |
| | | ក.2(2) | គំរោងកែលំអធារាសាស្ត្រកសិកម្មផ្នែកខាងក្រោមប្រលាយមេខាងត្បូង | 15,18 | | | | | | 3,04 | 4,72 | 3,15 | 2,24 | 2,01 |
| | | ក.2(3) | គំរោងកែលំអធារាសាស្ត្រកសិកម្មអូក្រាំងអំបិល | 7,21 | | | | | | | 3,03 | 3,59 | | |
| | គ | តំបន់ ៣ | | | | | | | | | | | | |
| | | ក.3(1) | គំរោងកែលំអធារាសាស្រត្តកសិកម្មដោយរក្សាទឹកទុកនៅចុងរដូវវស្សា | 7,42 | | | | | 12 | 1,44 | 2,16 | 2,11 | 83 | |
| | ឃ | តំបន់ ៤ | | | | | | | | | | | | |
| | | ក.4(1) | គំរោងកែលំអធារាសាស្រត្តកសិកម្មស្រោចស្រពដោយទឹកភ្លៀង | 2,97 | | | | 59 | 59 | 59 | 59 | 59 | | |
| | ង | តំបន់ឆ្លងកាត់ | | | | | | | | | | | | |
| | | ខ.1(1) | គំរោងកែលំអជាបន្ទាន់ទ្វារទឹករលាំងជ្រៃ | 7 | 7 | | | | | | | | | |
| | | ខ.1(2) | គំរោងកែលំអជាបន្ទាន់ទ្វារទឹករលាំងជ្រៃ និងទ្វារចែកចាយទឹក | 4,78 | | | | 38 | 2,71 | 1,69 | | | | |
| | | ខ.2(1) | គំរោងកែលំអការចិញ្ចឹមសត្វ និងការពង្រឹងសេវាកម្មបសុសត្វ | 37 | | | | 7 | 7 | 7 | 75 | 7 | | |
| | | ខ.3(1) | គំរោងអភិវឌ្ឍន៍សហគន៍ចិញ្ចឹមត្រី | 41 | | | | | | 7 | 7 | 8 | 8 | 9 |
| | | ខ.4(1) | គំរោងបង្កើនចំណូលបន្ថែមដល់កសិករ | 67 | | | | 9 | 10 | 14 | 16 | 16 | | |
| | | | **សរុប** | 65,20 | | | | 1,88 | 4,53 | 8,34 | 16,65 | 21,25 | 9,01 | 3,45 |
| (2) | **គំរោងកែលំអសេវាកម្ម** | | | | | | | | | | | | | |
| | | គ.1(1) | គំរោងពង្រឹងកិច្ចសំរបសំរួលរវាងក្រសួងកសិកម្ម និងក្រសួងធនធានទឹក និងឧតុនិយម | 9 | | | | 9 | | | | | | |
| | | គ.1(2) | គំរោងពង្រឹងសមត្ថភាពមន្ទីរ | 33 | | | | 33 | | | | | | |
| | | គ .2(1) | ការសិក្សាអភិវឌ្ឍន៍ការចិញ្ចឹមសត្វ | 1,55 | | | | 1,55 | | | | | | |
| | | គ.3(1) | គំរោងរៀបចំគោលការណ៍ណែនាំបច្ចេកទេស | 1,72 | | | | 69 | 86 | 17 | | | | |
| | | គ.4(1) | គំរោងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងបរិស្ថាន | 7 | 3 | 3 | | | | | | | | |
| | | គ.4(2) | គំរោងតាមដានការគ្រប់គ្រងបរិស្ថាន | 52 | | | | | | | 15 | 10 | 10 | 15 |
| | | គ.5(1) | គំរោងគំរូកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្ម | 80 | 30 | 40 | 10 | | | | | | | |
| | | គ.6(1) | គំរោងគំរូពង្រឹងសមត្ថភាពថែទាំសំណង់ធារាសាស្ត្រ | 90 | | | | 34 | 46 | 10 | | | | |
| | | គ.7(1) | គំរោងគំរូកែលំអធារាសាស្ត្រកសិកម្មស្រោចស្រពដោយទឹកភ្លៀង | 10 | 4 | 4 | 1 | | | | | | | |
| | | គ.8(1) | គំរោងគំរូបង្កើនប្រាក់ចំណូលបន្ថែមដល់កសិករ | 10 | | | | 5 | 6 | | | | | |
| | | គ.9(1) | គំរោងបង្កើនការយល់ដឹងស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក | 63 | | | | 25 | 31 | 6 | | | | |
| | | គ.10(1) | គំរោងពង្រឹងសេវាគាំទ្រកសិកម្ម និងស្ថាប័ន | 2,92 | | | | | 29 | 58 | 58 | 58 | 58 | 58 |
| | | គ.11(1) | គំរោងពង្រឹងការអង្កេតជលសាស្ត្រ | 5 | 2 | 2 | | | | | | | | |
| | | គ.11(2) | ការព្យាករណ៍ទឹកជំនន់ និងការប្រកាសជូនដំណឹង | 12 | | 12 | | | | | | | | |
| | | | **សរុប** | 9,94 | 40 | 62 | 11 | 3,31 | 1,99 | 92 | 74 | 69 | 69 | 44 |
| | | | **សរុបរួម** | 75,15 | 40 | 62 | 11 | 5,19 | 6,53 | 9,27 | 17,39 | 21,94 | 9,70 | 3,89 |

## (៤២) ការវាយតំលៃគំរោង: (៩.៧)

ការវាយតំលៃផ្នែកសេដ្ឋកិច្ចត្រូវបានរៀបចំឡើងសំរាប់គំរោងចំនួន ៩ ដែលជ្រើសរើសចេញពីគំរោងកែលំអហេដ្ឋារចនាសម្ព័ន្ធដែលគំរោងទាំងនោះផ្តល់អត្ថប្រយោជន៍ផ្ទាល់ និងចូលរួមចំណែកដល់គោលដៅយុទ្ធសាស្រ្តនៃផែនការមេ។ ក្នុង ចំណោមគំរោងចំនួន ៧ មានគំរោងចំនួន ២ ដែលចាត់ទុកថាជាគំរោងស្នូលនៃ " គំរោងកែលំអទ្វារទឹករលាំងជ្រៃ និងទ្វារ ចែកចាយទឹករលាំងជ្រៃ " គឺ " គំរោងស្តុកទឹកនៅចុងរដូវវស្សា " និង " គំរោងដែលទទួលទឹកស្រោចស្រពដោយទឹកភ្លៀង " ហើយគំរោងចំនួន ៥ ផ្សេងទៀត ត្រូវបានចាត់ទុកថាជាគំរោងអាទិភាពនៅក្នុងតំបន់អភិវឌ្ឍន៍ផ្នែកខ្សែទឹកខាងលើ។ អត្រា ចំណូលផ្នែកខាងក្នុងនៃសេដ្ឋកិច្ច(Economic Internal Rate of Return) ត្រូវបានគណនាសំរាប់គំរោងចំនួន ៩ ទៅតាមរូបភាពនៃការអភិវឌ្ឍន៍ផ្សេងៗគ្នាដូចខាងក្រោមនេះ:

**ផលប្រយោជន៍សេដ្ឋកិច្ចនៃប្រព័ន្ធស្រោចស្រព និងដោះទឹក នៃប្លង់វាយតំលៃទាំង ៩**

| ការវាយតំលៃប្លង់ | | EIRR (%) | NPV (Riel, Million) (7% discount rate) | | | អត្ថប្រយោជន៍ / តំលៃ |
|---|---|---|---|---|---|---|
| | | | អត្ថប្រយោជន៍ | តំលៃ | អត្ថប្រយោជន៍-តំលៃ | |
| 1. | RC | 13.7 | 21,996 | 15,450 | 6,546 | 1.4 |
| 2. | RC + UNMC | 4.8 | 31,091 | 38,524 | -7,433 | 0.8 |
| 3. | RC + Ou Krang Ambel | 9.6 | 37,855 | 30,230 | 7,625 | 1.3 |
| 4. | RC + UNMC + Ou Krang Ambel + LNMC | 6.2 | 54,877 | 59,728 | -4,851 | 0.9 |
| 5. | RC + IAIMP | 10.7 | 26,164 | 20,270 | 5,894 | 1.3 |
| 6. | RC + IAIMP + USMC | 6.2 | 37,217 | 40,117 | -2,990 | 0.9 |
| 7. | RC + IAIMP + USMC + LSMC | 7.4 | 73,098 | 69,487 | 3,611 | 1.1 |
| 8. | Water Harvest | - | 1,593 | 16,954 | -15,361 | 0.1 |
| 9. | Rainfed | 17.7 | 35,172 | 8,612 | 26,560 | 4.1 |

**កំណត់សំគាល់:** RC- គំរោងកែលំអទ្វារទឹករលាំងជ្រៃ និងទ្វារទឹកចែកចាយទឹករលាំងជ្រៃ។

UNMC- គំរោងកែលំអធារាសាស្រ្តកសិកម្មប្រលាយមេខាងជើង។

Ou Krang Ambel - គំរោងកែលំអធារាសាស្រ្តកសិកម្មអូរក្រាំងអំបិល។

LNMC- គំរោងកែលំអធារាសាស្រ្តកសិកម្មប្រលាយមេខាងជើងផ្នែកខាងក្រោម។

IAIMP- គំរោងគំរូកែលំអធារាសាស្រ្តកសិកម្ម។

USMC- គំរោងកែលំអធារាសាស្រ្តកសិកម្មប្រលាយមេខាងត្បូងផ្នែកខ្សែទឹកខាងលើ។

LSMC- គំរោងកែលំអធារាសាស្រ្តកសិកម្មប្រលាយមេខាងត្បូងផ្នែកខ្សែទឹកខាងក្រោម។

ផ្តើមចេញពីការវិភាគសេដ្ឋកិច្ចនៃស្រែគំរូលើចំណូលជាក់ស្តែងស្ថិតក្រោមលក្ខខ័ណ្ឌបច្ចុប្បន និងស្ថិតក្រោមលក្ខខ័ណ្ឌនៃគំរោងត្រូវបានធ្វើឡើងសំរាប់វិភាគទៅលើផ្នែកហិរញ្ញវត្ថុ នៃផែនការកែលំអកសិកម្មដែលទទួលទឹកស្រោចស្រពដោយទឹក ភ្លៀង និងផែនការស្រោចស្រព ។ លទ្ធផលបានបង្ហាញឱ្យឃើញថា ចំណូលជាក់ស្តែងដែលរំពឹងទុកពីដីស្រែស្ថិតនៅក្នុងគំរោង ត្រូវបានប៉ាន់ស្មានពី ២៩៩,000 រៀល ទៅ ៤៤៥,000 រៀល ពីករិតបច្ចុប្បន្ននៅក្នុងតំបន់គំរោងកែលំអធារាសាស្រ្ត កសិកម្ម និងចំណូលជាក់ស្តែងនៅក្នុងគំរោងកែលំអកសិកម្មស្រោចស្រពដោយទឹកភ្លៀងក្នុងតំបន់ ៤ ដែលត្រូវបានប៉ាន់ស្មាន ចំនួន ២៣៦,000 រៀល។

## (៤៣) តុល្យភាពស្បៀងនៅក្នុងតំបន់គោលដៅ: (៩.៧.៤)

តុល្យភាពស្បៀងនាពេលអនាគតនៅក្នុងតំបន់គោលដៅដែលស្ថិតនៅក្រោមប្លង់មេ (ស្ថិតក្រោមគំរោង) និងលក្ខខ័ណ្ឌពុំមានគំរោងត្រូវបានពិនិត្យ និងសង្ខេបដូចខាងក្រោម:

ការសិក្សាតុល្យភាពស្បៀងនៅក្នុងតំបន់គោលដៅ

| ឆ្នាំ | | អត្រាស្រូវគ្រប់គ្រាន់ | |
|---|---|---|---|
| | | ក្រោយគំរោង | មុនគំរោង |
| 2005 | ស្ថានភាពបច្ចុប្បន្ន | - | 68% |
| 2015 | ឆ្នាំចុងក្រោយនៃរយៈពេលមធ្យម[1/] | 93% | 55% |
| 2020 | ឆ្នាំអភិវឌ្ឍន៍ពេញលេញ[2/] | 92% | 50% |

*១- ឆ្នាំចុងក្រោយនៃផែនការមេ*

*២- តំណាក់កាលអភិវឌ្ឍន៍ពេញលេញដែលសំរេចបាននូវផែនការកែលំអកសិកម្ម*

ដូចបានបង្ហាញនៅក្នុងតារាងខាងលើ គោលដៅជាមូលដ្ឋាននៅក្នុងរង្វង់នៃផែនការមេ ស្តីពីស្រូវគ្រប់គ្រាន់សំរាប់ ទ្រទ្រង់ខ្លួនឯងនឹងអាចទទួលបាននៅក្នុងឆ្នាំ ២០១៥ គឺនៅឆ្នាំចុងក្រោយនៃផែនការមេ ដែលប្រៀបធៀបទៅនឹងស្ថាន ភាពពុំទាន់មានគំរោងគឺមានត្រឹមតែ ៥៥% ប៉ុណ្ណោះ។

## ជំពូក ៩ ការវាយតំលៃបរិស្ថានៈ

### (៤៤) ការសិក្សាការវាយតំលៃបរិស្ថានបឋមសំរាប់ផែនការមេៈ (១០.២.៤)

សេចក្តីសន្និដ្ឋាននៃការវាយតំលៃបរិស្ថាបបឋមសំរាប់ផែនការមេមានដូចខាងក្រោមៈ

- ផែនការមេត្រូវមានអត្ថប្រយោជន៏រួមដល់បរិយាកាសសង្គម និងចាត់ទុកថាការងារអាចទទួលយកបានតាម ទស្សនៈបរិស្ថាន។
- ផលប៉ះពាល់អវិជ្ជមានខ្លះមានមកលើសង្គម និងបរិស្ថានត្រូវបានគូសបញ្ជាក់តាមរយៈការសិក្សាវាយតំលៃ បរិស្ថានបឋម។ ដូចនេះទំហំនៃផលប៉ះពាល់អវិជ្ជមានមិនមានសភាពធ្ងន់ធ្ងរ ហើយផលប៉ះពាល់ទាំងនោះ ភាគ ច្រើនអាចជៀសវាងបាន ឬកាត់បន្ថយតាមរយៈការស្នើឡើងនូវប្រតិវិធានការ។
- គំរោងនានាពាក់ព័ន្ធផ្ទាល់ដល់ប្រជាជនមូលដ្ឋាន។ ដូចនេះ វាមានសារៈសំខាន់ណាស់ដើម្បីពិចារណាថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីឱ្យប្រជាជនចូលរួមក្នុងគំរោង រាប់បញ្ចូលទាំងទី តាំង, ពេលវេលា, វិធីសាស្ត្រ, អ្នក ចូលរួម និងការពិភាក្សាលើមាតិកា។ ជាពិសេស ពាក់ព័ន្ធដល់ការដោះស្រាយដីធ្លី និងការផ្លាស់ប្តូរទីលំនៅដោយ ស្ម័គ្រចិត្ត ត្រូវប្រើប្រាស់វិធីដោយប្រុងប្រយ័ត្ន។

## ជំពូក ១០: ការសន្និដ្ឋាន និងអនុសាសន៍

### (៤៥) ការសន្និដ្ឋាន និង អនុសាសន៍ៈ (១១.១ និង ១១.២)

ការសិក្សាប្លង់មេ គ្រោងនឹងបញ្ចប់នូវក្របខ័ណ្ឌអភិវឌ្ឍន៏នៅក្នុងឆ្នាំ ២០១៥ ក្នុងគោលបំណងកែលំអផលិតភាព កសិកម្មផ្តោតលើស្រូវដែលជាយុទ្ធសាស្ត្រគោលដៅនៃផែនការមេ។ ក្របខ័ណ្ឌអភិវឌ្ឍន៏ដែលបានលើកឡើង រួមមានគំរោង កែលំអហេដ្ឋារចនាសម្ព័ន្ធដែលមាន ១៣ គំរោង និងគំរោងកែលំអសេវាទ្រទ្រង់មាន ១៤ គំរោង ដែលគំរោងទាំងនោះ ស្ថិតនៅក្នុងទស្សនៈសុខុដមនីយកម្មនៃទិដ្ឋភាពរឹង និងទន់។ ការអនុវត្តន៏ប្លង់មេប្រកបដោយជោគជ័យ នឹងចូលរួមដល់ការ ទ្រទ្រង់ខ្លួនឯងក្នុងការផលិតស្រូវនៅក្នុងតំបន់គោលដៅ និងជួយបង្កើនប្រាក់ចំណូលតាមរយៈកាធ្វើកសិកម្មប្រហែលពី ១.៥ ដល់ ២ ដងនៃចំណូលបច្ចុប្បន្ន។ ដូចនេះ ប្លង់មេនេះ នឹងត្រូវយកមកអនុវត្តន៏ឱ្យបានឆាប់ៗដែលអាចធ្វើទៅបាន។

ពាក់ព័ន្ធនិងការអនុវត្តន៏របស់ប្លង់មេ បញ្ហាអនុសាសន៏ គឺ ១) រៀបចំធនធានថវិកាសំរាប់អនុវត្តន៏ប្លង់មេ, ២) តំរូវឱ្យមានការជួសជុលជាបន្ទាន់នូវទ្វារទឹករលាំងជ្រៃ និងសំណង់ចែកទឹក, ៣) តំរូវឱ្យមាននូវកិច្ចសំរបសំរួលរវាងក្រសួង ធ.ទ.ឧ និង ក្រសួងកសិកម្ម, ៤) តំរូវឱ្យមានការពង្រឹងការគ្រប់គ្រងបរិស្ថាន សម្រាប់អង្គភាពប្រតិបត្តិ, ៥) តំរូវឱ្យមានការត្រួតពិនិត្យ ពីការអនុវត្តផែនការមេ ៦) តំរូវឱ្យមានការសិក្សាស្តីពីការអភិវឌ្ឍន៏នូវធនធានទឹកថ្មី ៧) តំរូវឱ្យមានការពង្រឹងអាជ្ញាធរថ្នាក់ខេត្ត សម្រាប់ការទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និង ៨) តំរូវឱ្យមានការកែតំរូវឡើងវិញនូវផែនការមេឱ្យទាន់ពេលវេលា ។

# ក្បាលទី ៣ ការសិក្សាសមិទ្ធិនៃគំរោងជួសជុលជាបន្ទាន់ ឬគំរោងអាទិភាព

## ផ្នែក ក: ព័ត៌មានទូទៅ

### ជំពូក ១ សេចក្ដីផ្ដើម:

### (១) ការជ្រើសរើសគំរោងអាទិភាព ឬបន្ទាន់សំរាប់សិក្សាសមិទ្ធិ: (ក.១.៣.២)

ដើម្បីសំរេចគោលដៅយុទ្ធសាស្ត្ររបស់ផែនការមេគំរោងស្នើសុំ/ការសិក្សា ចំនួន ២៧ ត្រូវបានលើកឡើង។ ក្នុង ចំណោមគំរោងទាំងនោះ គំរោងអាទិភាព ឬបន្ទាន់ពីរ ត្រូវបានជ្រើសរើសពីទស្សនៈបច្ចេកទេសសមស្រប, សេដ្ឋកិច្ចល្អ, សង្គម និងបរិស្ថានបរិសុទ្ធ ដោយគិតទុកថា ការអនុវត្តនេះមានភាពបន្ទាន់ និងកើតមានឡើងដល់អត្ថប្រយោជន៍នៃគំរោង។ គំរោង អាទិភាព ឬបន្ទាន់ពីរនោះ គឺគំរោងកែលំអទ្វារទឹករលាំងជ្រៃ និងទ្វារចែកចាយទឹក និងគំរោងគំរូកែលំអធារាសាស្ត្រកសិកម្ម។

### (២) ការរៀបចំកិច្ចប្រជុំពិគ្រោះជាសាធារណៈ : (ក.១.៥)

ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៧ ការប្រជុំពិគ្រោះជាសាធារណៈមួយបានប្រារព្ធឡើងក្នុងគោលដៅធ្វើរបាយការណ៍ និងពន្យល់លទ្ធផលគំរោងគំរូ និងការសិក្សាសមិទ្ធិ សំរាប់ទ្វារទឹករលាំងជ្រៃ និងគំរោងកែលំអទ្វារទឹកចែកចាយ និងជាមួយ គំរោងគំរូកែលំអធារាសាស្ត្រកសិកម្ម។ ការប្រជុំបានចូលរួមដោយ មនុស្ស ចំនួន១០នាក់ ដោយរួមមានបុគ្គលិកក្រសួងធន ធានទឹក និងឧតុមិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, មន្ទីរធនធានទឹក និងឧតុនិយម, មន្ទីរកសិកម្ម, សមាជិក សហគមន៍កសិករប្រើប្រាស់ទឹកអូរវែង, សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកភូមិរំពង់ និងប្រធានឃុំ។ ជាលទ្ធផលការ ស្នើផែនការអភិវឌ្ឍន៍ ត្រូវបានយល់ព្រម ទោះបីជាមានការតវ៉ា ពីដីធំសំរាប់កសាងប្រឡាយរង និងផ្លូវទឹក។

## ផ្នែកខ: គំរោងសំណង់នាំទឹក និងទ្វារទឹករលាំងជ្រៃ

### ជំពូកខ.១ ទីតាំងគំរោង

### (១) ទីតាំង (ខ.១.១)

ទ្វារទឹករលាំងជ្រៃស្ថិតនៅក្នុងស្ទឹងព្រែកត្នោត ផ្នែកខ្សែទឹកខាងលើចំងាយប្រមាណ ១០០គម ពីទន្លេបាសាក់។ សំណង់ស្ទាក់ទឹកអណ្ដូងស្លាត្រូវបានសាងសង់ឡើងនៅក្បាលប្រឡាយមេខាងជើង និងសំណង់ស្ទាក់ទឹកវត្តក្រូចត្រូវបានសាងសង់ឡើង នៅក្បាលប្រឡាយមេខាងត្បូងពីទ្វារទឹករលាំងជ្រៃ។

### (២) ស្ថានភាពដី (ខ.១.២)

ច្រាំងផ្នែកខាងស្ដាំនៃទ្វារទឹករលាំងជ្រៃ បង្ហាញនូវរយៈកំពស់ ៣៩.៦៥១ម ធៀបនឹងកំពស់ទឹកសមុទ្រ។ ការសិក្សាពំនុះបណ្ដោយ បានបង្ហាញថាចំណោតបណ្ដោយពីផ្នែកខ្សែទឹកខាងលើស្ទឹងមកទល់នឹងទ្វារទឹករលាំងជ្រៃមានកំរិត ១/២.៧២០ ដែលមានកំរិតចោតជាងបន្តិចបើធៀបនឹងខ្សែទឹកផ្នែកខាងក្រោមពីទន្លេបាសាក់មកទល់ស្ពានពាមឃ្លេ (ចំងាយ១១៣.៤ គម) មាន កំរិត ១/៣.០០០។

### (៣) ទឹកជំនន់ (ខ.១.៣.៣)

ឆ្នាំទ្វារទឹករលាំងជ្រៃគឺជាអ្នកដែលមានបទពិសោធន៍ ៣៨ ឆ្នាំមកហើយ តាមរបាយការណ៍បានបង្ហាញថា ទឹកជំនន់ ខ្ពស់បំផុតកើតឡើងនៅឆ្នាំ ១៩៩១ ដែលធារទឹកនេះត្រូវបានគេប៉ាន់ប្រមាណថាប្រហែល ១.៣៦៩ $ម^{៣}$/វិនាទី។ ម្យ៉ាងវិញ ទៀត តាមលទ្ធផលនៃការធ្វើឋានលេខាលើស្ទឹងព្រែកត្នោត បានបង្ហាញថា ធារទឹកស្ទឹងមានកំរិតពី ១.៣០០ $ម^{៣}$/វិនាទី ទៅ ១.៥០០ $ម^{៣}$/វិនាទី សំរាប់ផ្នែកខាងលើនៃស្ទឹង ដែលមានតួលេខប្រហែលគ្នានឹងការអង្កេតរបស់ឆ្នាំទ្វារទឹកដែរ។ ជាមួយគ្នានឹង តួលេខនេះ អាចនិយាយបានថា ធារទឹកជំនន់ដែលប៉ាន់ប្រមាណសំរាប់ការលើកគំរោងនៃការប្រើប្រាស់ទ្វារទឹករលាំងជ្រៃឱ្យបាន ប្រសើរឡើង គួរគ្រោងប្រមាណពី ១.៣០០ $ម^{៣}$/វិនាទី ទៅ ១.៥០០ $ម^{៣}$/វិនាទីរឺរវាងពី ១.៤០០ $ម^{៣}$/វិនាទី ទៅ ១.៦០០ $ម^{៣}$/វិនាទី ។

### (៤) ទ្វារទឹករលាំងជ្រៃ (ខ.១.៤)

ទ្វារទឹករលាំងជ្រៃ បានកសាងឡើងក្នុងឆ្នាំ ១៩៧៤។ ផ្នែកមួយចំនួននៃទ្វារ ទឹករលាំងជ្រៃមានស្ថានភាពល្អនៅឡើយ ដូចជា: ស្លាបជញ្ជាំង, សសរទ្វារ និងស្ពានការ ងារ ក៏ប៉ុន្តែ ផ្នែកការពារការហូរច្រោះផ្នែកខាងក្រោមតំរូវឱ្យធ្វើការកែលំអ ដើម្បីការ ពារទ្វារទឹក។ បន្ថែមលើសនេះសំណង់ដោះទឹកទៅផ្នែកខាងក្រោម តំរូវឱ្យមានការសាងសង់ឡើងដើម្បីផ្តល់ទឹកទៅផ្នែកខាងក្រោមដោយស្ថានភាពទ្វារទឹករលាំងជ្រៃនាពេលបច្ចុប្បន្នមានទំហំធំ។



ទិដ្ឋភាពមើលពីខាងក្រោម នៃទ្វារទឹករលាំងជ្រៃ

ម្យ៉ាងទៀត ទ្វារទឹក និងគ្រឿងបង្គុំដទៃទៀតមានសភាពទ្រុឌទ្រោមខ្លាំង តំរូវឱ្យផ្លាស់ប្តូរជាបន្ទាន់ លើកលែងតែ សន្ទះទ្វារទឹក និងដែកស៊ុមនៅដំណើការល្អ។

## (៥) សំណង់ស្នាក់ទឹកអណ្តូងស្លា និងប្រឡាយនាំទឹក (ខ.១.៥)

សំណង់ស្នាក់ទឹកអណ្តូងស្លា បានកសាងឡើងក្នុងឆ្នាំ ១៩៧៤ តំណាលគ្នានឹងទ្វារទឹករលាំងជ្រៃ។ គ្រឿងបង្គុំនៃ សំណង់នេះ ដូចជា សសរស្ពាន និងស្ពានការងារ មិនប្រឈមនឹងស្ថានភាពធ្ងន់ធ្ងរទេ ក៏ប៉ុន្តែ ផ្នែកខាងក្រោមនៃសំណង់មាន ការខូចខាតស្ទើរទាំងស្រុង។



ទ្វារទឹកអណ្តូងស្លាមានការច្រោះលេចផ្នែកខាងលើ

សន្ទះទ្វារទឹកកោងមានការលេចជ្រាបទឹកតាមទ្រនាប់ជ័រ និងប្រហោងខ្សែ កាប។ បន្ថែមលើសនេះ ខ្សែកាបសំរាប់លើកទ្វារទឹកត្រូវខូចខាត។ សន្ទះទ្វារទឹកកោង មានសភាពមិនរឹងមាំ គ្រោងឆ្អឹងនៃសន្ទះ ទ្វារទឹកប្រភេទនេះមិនមានស្ថេរភាព ដោយសារសន្ទះទ្វារទឹកមានកំរាស់ស្តើង, ងាយស្រួលច្រេះចាប់ និងពិបាកក្នុងការថែទាំ បណ្តាលមកពីទ្វារទឹកនេះជានិច្ចជាកាលស្ថិតនៅក្នុងទឹក ហើយមានការលំបាកក្នុងការ ទប់ភ្ជិត។

ប្រឡាយនាំទឹកចូលមិនចាំបាច់ធ្វើការកែលំអទេ ព្រោះសមត្ថភាពនាំទឹកមាន គ្រប់គ្រាន់ និងជើងទេរប្រឡាយពុំ មានការហូរច្រោះធ្ងន់ធ្ងរឡើយ។

## (៦) សំណង់ស្នាក់ទឹកវត្តក្រូច និងប្រឡាយនាំទឹក (ខ.១.៦)

ថ្វីបើប្រឡាយនាំទឹកពីស្ទឹងព្រែកត្នោតទៅសំណង់ស្នាក់ទឹកវត្តក្រូច ពុំមានសមត្ថភាពនាំទឹកគ្រប់គ្រាន់តាមការគ្រោង ក៏ដោយ ក៏ពុំឃើញមានការហូរច្រោះធ្ងន់ធ្ងរនៅតាមជើងទេរនៃប្រឡាយឡើយ។ សំណង់ស្នាក់ទឹកវត្តក្រូច ជាសំណង់មានគ្រោងឆ្អឹងរឹងមាំ ក៏ប៉ុន្តែនៅផ្នែកខាងក្រោម នៃសំណង់មានការហូរច្រោះយ៉ាងខ្លាំង។



វិធានការបណ្តោះអាសន្នសំរាប់ខ្សែកាប

សំណង់ស្នាក់ទឹកវត្តក្រូច ត្រូវបានបំពាក់ដោយ សន្ទះទ្វារទឹកកោងដែលមានទ្រនាប់ភ្ជិតនៅតាមគែមចំនួន ០៤។ សំណង់នេះ មានផល លំបាកខ្លះ សំរាប់ការស្រោចស្រពដោយបង្វេរដោយសារការបាត់បង់កំរិតកំពស់ទឹកមានកំរិតខ្ពស់។

## (៧) ការប្រើប្រាស់ និងការថែទាំ (ខ.១.៧)

មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ក្រោមការទ្រទ្រង់ពីនាយកដ្ឋានធារាសាស្រ្តកសិកម្ម គឺទទួលបន្ទុកផ្ទាល់ លើការប្រើប្រាស់ និងថែទាំសំណង់នេះ។ ក៏ប៉ុន្តែ ការប្រើប្រាស់ និងការថែទាំឱ្យបានល្អិតល្អន់នោះពុំទាន់អនុវត្តន៍បានល្អនៅ ឡើយ ដោយសារខ្វះថវិកា និងបុគ្គលិក។

## (៨) បរិស្ថាន (ខ.១.៨)

ស្ពានដែលសាងសង់លើទ្វារទឹករលាំងជ្រៃ មានតួនាទីសំខាន់ណាស់សំរាប់ប្រជាជន ០៣ ភូមិ ដែលស្ថិតក្នុង និងនៅជុំវិញទីតាំងគំរោង ពីព្រោះពុំមានស្ពានកាត់ស្ទឹងព្រែកត្នោតនៅក្បែរឡើយ។ ប្រជាជននៅមូលដ្ឋានបានត្អូញត្អែរអំពីការថយចុះ នូវផលត្រីដោយសារការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងការហូរចូលនូវសារធាតុពុលទៅក្នុងស្ទឹង។

## (៩) តំរូវការកែលំអ (ខ.២.១.១)

ទ្វារទឹករលាំងជ្រៃ និងអណ្តូងស្លា បានកសាងឡើងក្នុងឆ្នាំ ១៩៧៤ និងមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំងដែលធ្វើកិច្ចដំណើរការពុំប្រព្រឹត្តទៅបានល្អឡើយ។ សំណង់ទ្វារទឹកវត្តក្រូច ដែលកសាងឡើងក្នុងឆ្នាំ ២០០២ ក៏ប្រឈមនិងបញ្ហា បច្ចេកទេសផងដែរ ដូចជាការបាត់បង់កំពស់ទឹក, ការខូចខ្សែកាប, ការហូរច្រោះផ្នែកខាងក្រោមសំណង់ និងពុំមានឧបករណ៍ វាស់វែង។ ប្រសិនបើ ទុកឱ្យស្ថានភាពទាំងនេះនៅបន្តនោះការផ្គត់ផ្គង់ទឹកទៅឱ្យផ្ទៃដីស្រោចស្រព នឹងជួបការលំបាក ឬក៏មិនអាចប្រព្រឹត្តទៅបានដោយសារសំណង់ទាំងនោះមិនដំណើរការបានល្អ ដែលធ្វើឱ្យយុទ្ធសាស្ត្រគោលដៅនៃប្លង់មេ ពាក់ព័ន្ធនឹងការកែលំអផលិតភាពកសិកម្មផ្តោតលើស្រូវមិនអាចសំរេចបាននៅឆ្នាំ ២០១៥។ ដើម្បីធានាការផ្គត់ផ្គង់ទឹកឱ្យមាន ស្ថេរភាព និងដើម្បីសំរេចបាននូវយុទ្ធសាស្ត្រគោលដៅខាងលើ តំរូវឱ្យមានការកែលំអជាបន្ទាន់។

## (១០) គោលបំណង និងទស្សនអភិវឌ្ឍន៍ (ខ.២.១.២)

គំរោងមានគោលបំណងមិនត្រឹមតែផ្តល់ទឹកឱ្យមានស្ថេរភាពសំរាប់ប្រឡាយមេខាងត្បូង និងប្រឡាយមេខាងជើង ក៏ប៉ុន្តែផ្តល់ឱ្យដល់ផ្ទៃដីស្រោចស្រពផ្នែកខាងក្រោមផងដែរ។ ដោយពិនិត្យលើលក្ខខ័ណ្ឌបច្ចុប្បន្ន និងសារៈសំខាន់នៃទ្វារទឹក រលាំងជ្រៃ, ទ្វារទឹកអណ្តូងស្លា ជាមួយប្រឡាយនាំទឹក និងទ្វារទឹកវត្តក្រូច ជាមួយប្រឡាយនាំទឹកសំរាប់ការអភិវឌ្ឍន៏កសិកម្ម ព្រមទាំងដើម្បីសំរេចបាននូវគោលបំណងក្រុមសិក្សារបស់អង្គការ JICA បានលំអិតនូវទស្សនៈអភិវឌ្ឍន៏ស្តីពីការ ***"សំរេចបាន នូវការប្រើប្រាស់ល្អប្រសើរតាមរយៈការផ្តល់នូវសំណង់សមស្រប "*** សំរាប់គំរោង។ ក្នុងន័យនេះ ផែនការអភិវឌ្ឍន៏ សំណង់និមួយៗនឹងត្រូវបានយកមកអនុវត្តន៏ដោយកំណត់តាមទស្សនៈខាងលើ។

## (១១) ផែនការជួសជុលទ្វារទឹករលាំងជ្រៃ (ខ.២.២)

ផែនការកែលំអទ្វារទឹករលាំងជ្រៃ ត្រូវបានអនុវត្តន៏ដោយផ្តោតការយកចិត្តទុកដាក់លើ

1- ការប្រើប្រាស់ឱ្យបានអតិបរមានូវសំណង់ដែលមានស្រាប់
2- ងាយស្រួលក្នុងការថែទាំ
3- ងាយស្រួលក្នុងការប្រើប្រាស់
4- ធានាសុវត្ថិភាពដល់ទ្វារទឹក
5- ផ្តល់ទឹកតាមតំរូវការដល់ផ្ទៃដីផ្នែកខាងក្រោម

ផែនការគ្រោងជួសជុលសំណង់ទ្វារទឹករលាំងជ្រៃ ផ្អែកលើធារទឹកគ្រោងដែលមានបរិមាណ ១,៦០០ ម$^{៣}$/វិនាទី មានដូចខាងក្រោមៈ

1- ជួសជុលផ្នែកខ្សែទឹកខាងក្រោមនៃទ្វារទឹក
2- ជួសជុលជញ្ជាំងទប់ដី
3- សាងសង់ផ្លូវវៀង

ក្រៅពីការងារជួសជុលខាងលើ នៅមានការជួសជុលប្រព័ន្ធអ៊ីដ្រូមេកានិកនៃទ្វារទឹក មានដូចខាងក្រោមៈ

1- ជួសជុលកង់យោង
2- លាបពណ៌ទ្វារទឹក
3- ជួសជុលជ័រភ្ជិត ឬទ្រនាប់
4- ផ្លាស់ប្តូរថ្មី ទំពក់ស្ទូច
5- ដំឡើងប្រព័ន្ធបញ្ជារពីចំងាយ

## (១២) ផែនការជួសជុលទ្វារទឹកអណ្តូងស្លា (ខ.២.៣)

ផែនការជួសជុលទ្វារទឹកអណ្តូងស្លា ត្រូវបានគិតគូរយ៉ាងលំអិតទៅលើៈ

១- ផែនការអភិវឌ្ឍន៏ផ្ទៃដីស្រោចស្រពកំពុងដំណើរការ
២- កាត់បន្ថយផលប៉ះពាល់ជលសាស្ត្រតិចតួចទៅលើផ្នែក ខ្សែទឹកខាងក្រោម

៣- ជ្រើសរើសប្រភេទទ្វារទឹកសមស្រប

៤- ឥទ្ធិពលនៃទឹកចាល់ដោយជំនន់

ផែនការអភិវឌ្ឍន៍ផ្ទៃដីស្រោចស្រពដែលកំពុងដំណើរការ ក្នុងគំរោងមជ្ឈមណ្ឌលអភិវឌ្ឍន៍ចំរុះខាងលិចរាជធានី ភ្នំពេញ ត្រូវបានលើកយកមកពិចារណាដើម្បីកំណត់ទំហំ និងចំនួននៃទ្វារទឹក។ ផ្អែកលើលទ្ធផលនៃការពិនិត្យស្ថិតិពីបញ្ហានេះ ការជួសជុលទ្វារទឹកនេះ ត្រូវផ្អែកលើវិធីសាស្ត្រដូចតទៅនេះ:

១- គ្រោងសង់ទ្វារទឹកចំនួន ០៤ ប្រឡោះ

២- តំឡើងទ្វារទឹកចំនួន ០២ ប្រឡោះ ក្នុងចំណោមទ្វារ ០៤ ប្រឡោះ ដើម្បីធានាការដោះទឹក ដែលមានបរិមាណចំនួន 10,40 ម$^3$/វិនាទី ក្នុងការសិក្សានេះ។

៣- បិទទ្វារទឹក ០២ ប្រឡោះទៀតដែលនៅសល់ដោយដុំបេតុង ដើម្បីងាយស្រួលក្នុងការ តំឡើងទ្វារទឹកថ្មី នៅពេលអនាគត។

ពាក់ព័ន្ធដល់ការងារខាងលើនេះ ទាមទារឱ្យធ្វើការសិក្សាគ្រោងប្លង់នូវជញ្ជាំងទប់ដី សសរទ្វារទឹក ស្ពានការងារ និង ផ្នែកខាងក្រោមនៃសំណង់។

ទ្វារទឹកចំនួន ០៣ ប្រភេទ ត្រូវបានលើកមកធ្វើការជ្រើសរើសសំរាប់បំពាក់នៅទ្វារទឹកអណ្តូងស្លា ដូចជា ប្រភេទទ្វារ ទឹកកោង, ទ្វារទឹកបញ្ឈរ និងទ្វារទឹករំអិល។ ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ ដោយផ្អែកលើទស្សនៈបច្ចេកទេស និង សេដ្ឋកិច្ច ជាពិសេសដោយគិតគូរពីភាពងាយស្រួលក្នុងការប្រើប្រាស់ និងជាប់យូរអង្វែង ប្រភេទទ្វារទឹកបញ្ឈរត្រូវបានជ្រើស រើសសំរាប់បំពាក់ក្នុងទ្វារទឹកអណ្តូងស្លា។ ការស្នើសុំបង្កើតឡើងនូវប្រព័ន្ធបញ្ជាពីចំងាយភ្ជាប់ពីទ្វារទឹករលាំងជ្រៃ ទៅទ្វារទឹក អណ្តូងស្លា គឺក្នុងគោលបំណងប្រើប្រាស់ឱ្យបានទាន់ពេលវេលា។

## (១៣) ផែនការជួសជុលទ្វារទឹកវត្តក្រួច (ខ.២.៤)

ផែនការជួសជុលទ្វារទឹកវត្តក្រួច និងប្រឡាយនាំទឹកចូល ត្រូវបានរៀបចំឡើងយោងតាមទស្សនៈដូចខាងក្រោម:

1- ផែនការអភិវឌ្ឍន៍ផ្ទៃដីស្រោចស្រពដែលមានស្រាប់នៅក្នុងតំបន់អភិវឌ្ឍន៍ខាងលិចរាជធានីភ្នំពេញ

2- ការប្រើប្រាស់ប្រភេទទ្វារទឹកសមស្រប

3- ឥទ្ធិពលនៃទឹកចាល់ដោយជំនន់

ផ្តើមចេញពីទស្សនៈនៃតំបន់អភិវឌ្ឍន៍ និងតំរូវការធារទឹកក្រោមការសិក្សាប្លង់មេ និងតាមការសិក្សានៃផែនការ អភិវឌ្ឍន៍មជ្ឈមណ្ឌលអភិវឌ្ឍន៍ចំរុះខាងលិចរាជធានីភ្នំពេញ បានបង្ហាញឱ្យឃើញថា តំរូវការទឹកសំរាប់អភិវឌ្ឍន៍មជ្ឈមណ្ឌល នេះមានបរិមាណចំនួន 17,4 ម$^3$/វិនាទី រីឯតំរូវការទឹកនៃការសិក្សាប្លង់មេ មានបរិមាណត្រឹមតែ 16,3 ម$^3$/វិនាទី គឺតិច ជាងចំនួន 1,1 ម$^3$/វិនាទី។ ភាពខុសគ្នាបន្តិចបន្តួចនៃធារទឹកនេះ មិនអាចចាត់ទុក ថាជាកត្តាសំរេចសំរាប់កំណត់ចំនួន និងទំហំ ទ្វារទឹកឡើយ។ ហេតុដូចនេះ ទំហំទ្វារទឹកនេះ ត្រូវបានកំណត់ ដូចត ទៅ : ទ្វារទឹកមានចំនួន 2 ប្រឡោះ, ទ្វារទឹកមានកំពស់ 5 ម និងទទឹង 4 ម។

ទាក់ទងនិងការគ្រោងធារទឹកថ្មី និងដើម្បីធានានូវការបាត់បង់កំពស់ទឹក ការងារដែលត្រូវជួសជុល មានដូចខាង ក្រោម:

1- ជួសជុលផ្នែកខ្សែទឹកខាងលើ និងផ្នែកខាងក្រោមនៃទ្វារទឹក

2- សាងសង់សសរទ្វារទឹក និងលូប្រអប់

3- សាងសង់សំណង់ការពារការហូរច្រោះផ្នែកខ្សែទឹកខាងលើ និងផ្នែកខាងក្រោមនៃប្រឡាយ

4- ជួសជុលប្រឡាយនាំទឹកចូល។

ប្រព័ន្ធបញ្ជារពីចំងាយ ដើម្បីភ្ជាប់ទៅទ្វារទឹករលាំងជ្រៃ ក៏បានតភ្ជាប់ទៅនឹងទ្វារទឹកវត្តក្រួចផងដែរ ក្នុងគោលបំណង ធ្វើឱ្យមានភាពងាយស្រួល និងប្រើប្រាស់បានទាន់ពេលវេលា។

## (១៤) ផែនការប្រើប្រាស់ និងការថែទាំ (ខ.២.៥)

មានការពន្យល់នៅក្នុងផែនការប្រើប្រាស់ទ្វារទឹករលាំងជ្រៃ, ក្នុងករណីការប្រើប្រាស់ទ្វារទឹកក្នុងលក្ខខ័ណធម្មតា និង នៅពេលមានជំនន់។ និតិវិធីនៃការប្រើប្រាស់ទ្វារទឹកដែលបានស្នើឡើងសំរាប់លក្ខខ័ណ្ឌធម្មតា គឺមានដូចខាងក្រោមៈ

1- ត្រួតពិនិត្យកំពស់ទឹកផ្នែកខ្សែទឹកខាងលើនៃទ្វារទឹក

2- គ្រប់គ្រងកំពស់ទឹកផ្នែកខ្សែទឹកខាងលើនៃទ្វារទឹកឱ្យនៅត្រឹមកំពស់ 35.7ម

3- បើកទ្វារទឹក

4- កត់ត្រាធារទឹកនៃទ្វារទឹក

5- កត់ត្រាធារទឹកសំរាប់ដោះទឹកទឹក

ការបិទបើកទ្វារទឹក នៅពេលមានទឹកជំនន់ ត្រូវមានការពិភាក្សាអំពីរយៈពេលកើនឡើងនៃទឹកជំនន់ និងរយៈពេល ថយចុះនៃទឹកជំនន់។ សំរាប់ករណីទាំងពីរខាងលើនេះ ការបិទ និងបើកទ្វារទឹក ដោយធ្វើការអង្កេតនូវកំពស់ទឹកនៅផ្នែកខ្សែ ទឹកខាងលើត្រឹមកំរិត 35.7ម ត្រូវបានលើកយកមកសិក្សា និងស្នើឡើង។

ដោយទ្វារទឹកអណ្តូងស្លា និងទ្វារទឹកវត្តក្រូចនៅដំណើរការធម្មតា ទ្វារទឹកទាំងពីរនេះ ត្រូវប្រើប្រាស់ដោយផ្អែកលើ ផែនការសេវាស្រោចស្រព។ ដើម្បីសម្រួលដល់ការប្រើប្រាស់នោះ តំរូវឱ្យរៀបចំជាមុននូវក្រាហ្វិក បង្ហាញអំពីភាពទំនាក់ទំនង ក្នុងភាពខុសគ្នារវាងកំពស់ទឹកនៅខ្សែទឹកផ្នែកខាងលើ និងកំពស់ទឹកនៅខ្សែទឹកផ្នែកខាងក្រោម, ការបើកទ្វារទឹក និងការវាស់ ធារទឹក។

ដើម្បីឱ្យការងារថែទាំប្រព្រឹត្តទៅដោយរលូន ផែនការថែទាំសំរាប់ទ្វារទឹករលាំងជ្រៃ, ទ្វារទឹកអណ្តូងស្លា និងទ្វារទឹក វត្តក្រូច ត្រូវបានស្នើឡើងដូចខាងក្រោមៈ

1- ការពិនិត្យប្រចាំថ្ងៃ

2- ការពិនិត្យម្តងម្កាល

3- កម្មវិធីថែទាំប្រចាំឆ្នាំ

4- តំរូវការការងារថែទាំ

5- ការងារជួសជុលជាបន្ទាន់

## (១៥) ការពិចារណាលើបរិស្ថាន (ខ.២.៦)

នៅក្នុងដំណើរការរៀបចំផែនការកែលំអផ្សេងៗ ការពិចារណាលើបរិស្ថានត្រូវបានរៀបចំឡើង ក្នុងគោលបំណង អនុវត្តន៏គំរោងឱ្យមានចិរភាពផ្នែកបរិស្ថាន។ ចំណុចដែលត្រូវពិចារណាលើបរិស្ថានក្នុងគំរោងនោះគឺៈ

1- លទ្ធភាពទឹកសំរាប់កសិកម្មក្នុងអំឡុងពេលសាងសង់

2- វិធីសាស្រ្តក្នុងការសាងសង់ប្រឡាយបេតុងនៃប្រឡាយនាំទឹក

3- ការបំពុលខ្យល់ដោយសារការដឹកជញ្ជូននៃគ្រឿងចក្រធុនធ្ងន់

## (១៦) ផែនការអនុវត្តន៍ (ខ.២.៧)

ការងារគំរោងរួមមាន សេវាវិស្វកម្ម, ការរៀបចំឯកសារដេញថ្លៃ, ការងារសាងសង់ និងការតាមដានផ្នែកបរិស្ថាន។ តំរូវការពេលវេលាសំរាប់ដំណើរការសាងសង់មានចំនួន 45 ខែ ដោយចាប់ផ្តើមពីខែ សីហា ឆ្នាំ 2007 ដល់ខែ មេសា ឆ្នាំ 2011។ រយៈពេលនៃការអនុវត្តន៏គំរោងមានដូចខាងក្រោមៈ

**កាលវិភាគប្រតិបត្តិគំរោង**




ក្រសួងធនធានទឹក និងឧតុនិយម គឺជាស្ថាប័នប្រតិបត្តិគំរោង។ នៅក្នុងអំឡុងពេលនៃការអនុវត្តន៏គំរោងនាយកដ្ឋាន វិស្វកម្មនឹងទទួលខុសត្រូវលើការសិក្សាគ្រោងប្លង់ និងការសាសង់។ ដើម្បីឱ្យការត្រួតពិនិត្យការសាងសង់មានប្រសិទ្ធិភាព តំរូវឱ្យបង្កើតការដ្ឋានសាងសង់នៅមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ។ បន្ទាប់ពី ការងារសាងសង់ត្រូវបានបញ្ចប់ ដោយមានការគាំទ្រពីនាយកដ្ឋានធារាសាស្ត្រកសិកម្ម មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកផ្ទាល់លើ ការប្រើប្រាស់ និងថែទាំនូវរាល់សំណង់ដែលបានជួសជុលរួច។ ទាក់ទងដល់ការងារនេះ ការិយាល័យថែទាំ និងប្រើប្រាស់សំរាប់ ទ្វារទឹករលាំងជ្រៃ, ទ្វារទឹកអណ្តូងស្លា និងទ្វារទឹក វត្តក្រូចនឹងត្រូវបានបង្កើតឡើងក្នុងមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ ស្ពឺ ដើម្បីពង្រឹងដល់សកម្មភាពប្រើប្រាស់ និងថែទាំសំណង់។

## (១៧) ការវាយតំលៃលើបរិស្ថាន (ខ-២.៨)

ការវាយតំលៃលើបរិស្ថានជំហានដំបូងនៃគំរោងរួមមាន:

១- ជារួម ប្រសិនបើវិធានការកាត់បន្ថយសមស្របដែលបានបង្ហាញលើកមុនត្រូវបានអនុវត្តន៏ នោះផែនការអភិវឌ្ឍន៏នៃគំរោងត្រូវបានវាយតំលៃទទួលយកបានតាមទស្សនៈបរិស្ថាន ។

២- ផលប៉ះពាល់អវិជ្ជមានខ្លះមកលើបរិស្ថានសង្គម និងធម្មជាតិ ត្រូវបានគូសបញ្ជាក់ ដូចជា ការហាមប្រាម មិនឱ្យចូលការដ្ឋាន និងបរិមាណទឹកមានកំរិតក្នុងពេលសាងសង់។ ដូចនេះ ការគ្រប់គ្រងសមស្រប ជាមួយនឹងសំណើវិធានការកាត់បន្ថយ និងផែនការត្រួតពិនិត្យត្រូវបានអនុវត្តន៏ ដើម្បីកាត់បន្ថយ ឱ្យបានច្រើននូវផលប៉ះពាល់អវិជ្ជមានដែលបានរំពឹងទុក។

### (១៨) ការប៉ាន់ស្មានតំលៃ (ខ-២.៩)

តំលៃវិនិយោគសរុបគឺ 4,991,000 ដុល្លារអាមេរិក ស្មើនឹង 20,263,460,000 រៀល ក្នុងនោះសំរាប់ចំណាយ លើការងារដូចខាងក្រោមៈ

1- តំលៃសេវាវិស្វកម្ម

2- តំលៃសំណង់

3- តំលៃរដ្ឋបាល

4- តំលៃត្រួតពិនិត្យបរិស្ថាន

5- តំលៃត្រៀមបំរុង

តំលៃនៃការជួរទ្វារទឹក និងគ្រឿងបរិក្ខារមួយចំនួន មានចំនួន 1,374,200 ដុល្លារអាមេរិក គឺស្មើនឹង 5,579,252,000 រៀល។ ការងារជួសជុលនេះ អាចធានាប្រើប្រាស់បានរយះពេល 25 ឆ្នាំ ចាប់តាំងពីថ្ងៃ ដែលបានជួសជុល។ ចំណែកថ្លៃសំរាប់ការងារថែទាំ និងប្រើប្រាស់មានចំនួន 9,300 ដុល្លារអាមេរិក គឺស្មើ 37,758,000 រៀល។

### (១៩) ការវាយតំលៃគំរោង (ខ-២.១០)

***អាត្រាត្រលប់ផ្ទៃក្នុងសេដ្ឋកិច្ច*** នៃគំរោងត្រូវបានប៉ាន់ស្មានស្មើ 14,9%។ ផលសងរវាងផលចំណេញ និងតំលៃ ស្មើនិង 7% នៃអាត្រាបញ្ចុះតំលៃ ត្រូវបានប៉ាន់ស្មានស្មើនឹង 7,772 លានរៀល និងផលធៀបរវាងផលចំណេញ និងតំលៃ ស្មើនឹង 7% នៃអាត្រាបញ្ចុះតំលៃ ត្រូវបានប៉ាន់ស្មានស្មើនឹង 1,6 លានរៀល។

សន្ទស្សន៍សេដ្ឋកិច្ចដែលបានប៉ាន់ស្មានទាំងនេះ បង្ហាញឱ្យឃើញថា គំរោងនេះមានប្រសិទ្ធភាពសេដ្ឋកិច្ច។ ការវិភាគ យ៉ាងល្អិតល្អន់បានបង្ហាញថា គំរោងនេះមានភាពទាក់ទងទៅការកាត់បន្ថយផលចំណេញ ជាងការកើនតំលៃ ថ្វីបើសន្ទស្សន៍នេះ អាចសំរបសំរួលទៅនឹងបំលាស់ប្តូរគួរឱ្យចាប់អារម្មណ៍នៅក្នុងអថេរទាំងនោះ។

ការវិភាគថវិកាកសិដ្ឋាន លើកសិដ្ឋានគំរូរស្តីពីតំលៃដើមនៃវាលស្រែគំរូរក្រោមលក្ខខ័ណ្ឌបច្ចុប្បន្នមានគំរោង និង អនាគតគ្មានគំរោង ត្រូវបានធ្វើឡើងសំរាប់ការវិភាគផ្នែកហិរញ្ញវត្ថុនៃគំរោង។ លទ្ធផលនៃការវិភាគត្រូវបានសង្ខេបក្នុង តារាងដូចខាងក្រោមនេះ:

**លទ្ធផលនៃការវិភាគសេដ្ឋកិច្ចកសិកម្ម (ឯកតា: រៀល)**

| តំបន់ / គំរោង | 1. ទុនដើមលក់ស្រូវក្នុង ស្រែមួយអំពក (ក្នុងករណីមានគំរោង) | 2. ទុនដើមលក់ស្រូវក្នុង ស្រែមួយអំពក (ក្នុងករណីមានគំរោង) | តំលៃបន្ថែមក្នុងស្រែមួយអំពក (1 – 2) |
|---|---|---|---|
| តំបន់ -1 1/ | | | |
| - គំរោងគំរូរ | 791,000 | 424,000 | 367,000 |
| - គកធរសកប្រមជ | 552,000 | 417,000 | 135,000 |
| - គកធរសកប្រមត | 486,000 | 417,000 | 68,000 |
| តំបន់ -2 | 469,000 | 417,000 | 51,000 |

1/: *គំរោងគំរូកែលំអធារាសាស្រ្តកសិកម្ម (គកធរសក)*

*គំរោងកែលំអធារាសាស្រ្តកសិកម្មប្រឡាយមេខាងជើង (គកធរសកប្រមជ)*

*គំរោងកែលំអធារាសាស្រ្តកសិកម្មប្រឡាយមេខាងត្បូង (គកធរសកប្រមត)*

ដូចមានបង្ហាញក្នុងតារាងខាងលើនេះ ក្តីសង្ឃឹមទុកនៃការកើនឡើងនៃទុនដើម ដូចជា ទុនដើមដែលបានសន្សំពី ការបាត់បង់ដោយការមិនដំណើរការទាំងស្រុងនៃទ្វារទឹក, ពីស្រែក្រោមលក្ខខ័ណ្ឌមានគំរោង ត្រូវបានប៉ាន់ស្មានតំលៃពី 367,000 រៀល ទៅ 51,000 រៀល ក្នុងមួយគ្រួសារ។ ក្នុងន័យសមាមាត្រ សន្ទស្សន៍នេះ អាចបញ្ជាក់ថា ពី 10% ទៅ46% នៃចំណូលកសិផលសរុបក្នុងមួយគ្រួសារនៅថេរ ដោយសារភាពមិនដំណើរការនៃទ្វារទឹក។

### (២០) ការសន្និដ្ឋាន និងអនុសាសន៍ (ខ.២.១១)

ការសិក្សាសមិទ្ធិ បានបង្ហាញថា គំរោងនេះមានប្រសិទ្ធភាពសេដ្ឋកិច្ច និងលក្ខណៈបច្ចេកទេសអាចទទួលយកបាន។ តាមទស្សនៈសង្គម និងបរិស្ថានធម្មជាតិ ក៏បានបញ្ជាក់យ៉ាងច្បាស់ថា គំរោងនេះមានប្រសិទ្ធិភាពល្អ។ ការអនុវត្តន៍គំរោង អាចសំរេចនូវគោលបំណងគ្រឹះដូចតទៅៈ

1- ការផ្គត់ទឹកគ្រប់គ្រាន់សំរាប់ដីកសិកម្មចំនួន 16,700 ហិកតា ដែលឈានទៅបង្កើនទិន្នផលស្រូវ 3,285 តោន

2- ចូលរួមកាត់បន្ថយផ្ទៃដីដែលលិចលង់ដោយសារទឹកជំនន់ តាមរយៈការបិទបើកទ្វារទឹកឱ្យបានល្អ

3- ធានាការផ្គត់ទឹកទៅឱ្យផ្ទៃដីស្រែផ្នែកខ្សែទឹកខាងក្រោម

អាស្រ័យហេតុនេះ គំរោងនេះ ត្រូវតែអនុវត្តន៍ឱ្យបានឆាប់ជាបន្ទាន់។

ទាក់ទងដល់ការអនុវត្តន៍គំរោង អនុសាសន៍មួយចំនួនត្រូវបានលើកឡើងដូចជា ការពង្រឹងការប្រើប្រាស់ និងថែទាំ និងការបង្កើតឡើងនូវប្រព័ន្ធទាក់ទងរវាងស្ថានីយ៍អង្កេតពាមក្លែ និងទ្វារទឹករលាំងជ្រៃ ដែលមានសារសំខាន់ក្នុងការគ្រប់ គ្រងឱ្យបានសមស្រប និងមាននិរន្តរភាពនៃគំរោង។

## ផ្នែក គៈ គំរោងគំរូកែលំអធារាសាស្ត្រកសិកម្មៈ

## ជំពូក គ.១ តំបន់គំរោង

### (១) ទីតាំង និងស្ថានភាព (គ.១.១.១, គ.១.១.២)

គំរោងគំរូកែលំអធារាសាស្ត្រកសិកម្មស្ថិតនៅចំងាយ 25 គ.ម ខាងលិចរាជធានីភ្នំពេញ។ ផ្ទៃដីគំរោងលាតសន្ធឹងលើផ្ទៃដីផ្នែកខាងស្តាំនៃស្ទឹងព្រែកត្នោតដែលនៅចន្លោះរវាងស្ទឹង និងផ្នែកខ្សែទឹកខាងលើនៃប្រឡាយមេខាងត្បូង។ ផ្លូវ ជាតិលេខ ៤ រត់កាត់ក្នុងតំបន់គំរោង។ ទីតាំងគំរោងលាតសន្ធឹងពីទិសខាងលិចទៅទិសខាងកើត ដោយមានជំរាល ប្រមាណ 1/2,000។

### (២) ស្ថានភាពឧតុនិយម (គ.១.១.៣)

តំបន់គំរោងមានលក្ខណៈអាកាសធាតុត្រូពិកដែលកំណត់ឱ្យមានរដូវពីរ។ រដូវវស្សាចាប់ផ្តើមពីខែ ឧសភា ដល់ខែ តុលា ហើយរដូវប្រាំងចាប់ផ្តើមពីខែ វិច្ឆិកា ដល់ខែ មេសា។ សីតុណ្ហភាពមធ្យម បានបង្ហាញថា សីតុណ្ហភាពប្រចាំរដូវ មានការបំរែបំរួលតិចតួច គឺក្នុងខែ ធ្នូ សីតុណ្ហភាពមានកំរិត 26,1 អង្សារសេ ហើយនៅក្នុងខែ មេសា សីតុណ្ហភាព មានកំរិត 30,5 អង្សារសេ។ សំណើមមានការប្រែប្រួលពី 66% ទៅ 77% ក្នុងខែ កុម្ភៈ និងមីនា ហើយនិងពី 80% ទៅ 90% នៅក្នុងខែ កញ្ញា និងខែ តុលា។

### (៣) ស្ថានភាពដី (គ.១.១.៤)

45,5% នៃដីតំបន់គំរោងចែកចេញជា Gleyic Acrisol Medium Textured Phase (GAm2) and Gleyic Acrisol Medium to Fine Textured Phase (GAf) ហើយត្រូវបានចាត់ថ្នាក់ជាប្រភេទដីមានជីជាតិមធ្យមសំរាប់ដំណាំកសិកម្ម ហើយ 54,5% ទៀតចែកចេញជាGleyic Acrisol Coarse to Medium Textured Phase និងត្រូវបានចាត់ថ្នាក់ ជាប្រភេទដីមានជីជាតិបន្ទាប់បន្សំ។

### (៤) រដ្ឋបាល និងប្រជាពលរដ្ឋ (គ.១.២.១)

តំបន់គំរោង មានភូមិចំនួន 18, ឃុំចំនួន 3 និងស្រុកចំនួន 2 ដែលស្ថិតក្នុងខេត្តកំពង់ស្ពឺ។ យោងតាមមូលដ្ឋាន ទិន្នន័យឃុំរបស់កម្មវិធីសិលា ឆ្នាំ 2005 ចំនួនប្រជាពលរដ្ឋនៅក្នុងតំបន់គំរោងមាន 10,000 នាក់។ ប្រជាពលរដ្ឋដែល មានអាយុពី 15 ឆ្នាំ ដល់ 64 ឆ្នាំ ដែលជាវ័យអាចបំពេញការងារបានមានចំនួន 6,000 នាក់។

### (៥) លក្ខខ័ណ្ឌផ្គត់ផ្គង់ស្បៀង (គ.១.២.២)

យោងតាមការអង្កេតសេដ្ឋកិច្ចសង្គម លើកសិករចំនួន 100 នាក់ បានបង្ហាញថា កសិករចំនួន 90% មានស្រូវ ហូបគ្រប់គ្រាន់ និងលើសពីតំរូវការ។ ក៏ប៉ុន្តែ ផលិតផលគ្រាប់ធញ្ញជាតិ, សណ្តែក និងបន្លែផ្សេងៗ ពុំទាន់ឆ្លើយតបទៅនឹង តំរូវការរបស់គ្រួសារកសិករឡើយ។

ផលិតផលដំណាំដីលើតំរង់ទិសជាចំបង ទៅរកការផ្គត់ផ្គង់ការហូបចុកគ្រប់គ្រាន់ សំរាប់គ្រួសារ និងលើសពីនេះសំរាប់លក់លើទីផ្សារ។ តាមរយះការណែនាំការដាំដុះដំណាំដី នៅដើមរដូវវស្សាត្រូវបាន គេអនុវត្ត។

## (៦) ការប្រើប្រាស់ដី (គ-១.៣.១)

ផ្ទៃដីដាំដុះរបស់គំរោងមាន 600 ហិកតា ដែលក្នុងចំណោមនោះ 580 ហិកតា ជាដំណាំស្រូវ ។ ផ្អែកលើការអង្កេតប្រព័ន្ធធារាសាស្ត្រលំអិតសិក្សាដោយក្រុមសិក្សារបស់អង្គការ JICA និងដោយផ្អែកលើស្ថានភាពប្រព័ន្ធធារាសាស្ត្រនាពេល បច្ចុប្បន្ន តំបន់គំរោងត្រូវបានបែងចែកជាពីរប្រភេទ:

**ការប្រើប្រាស់ដីបច្ចុប្បន្ន ( ស្ថានភាពប្រព័ន្ធធារាសាស្ត្រ )**

| ប្រភេទ | ផ្ទៃដី (ha) | សមាមាត្រ (%) | |
|---|---|---|---|
| | | តំលៃដើម | តំលៃសរុប |
| ស្រែដាំស្រូវម្តងក្នុង 1 ឆ្នាំ | 377 | 65 | 63 |
| ស្រែដាំស្រូវពីរដងក្នុង 1 ឆ្នាំ 1/ | 203 | 35 | 34 |
| សរុប | 580 | 100 | 97 |
| មធ្យោបាយត្រឹមត្រូវ Right of ways | 20 | - | 3 |
| សរុបរួម | 600 | - | 100 |

*1/: រាប់បញ្ចូលទាំងស្រែធ្វើបីដងក្នុង 1 ឆ្នាំ មានផ្ទៃដី ពីរ ហិកតា ប្រភពព័ត៌មាន: ក្រុមសិក្សាអង្គការ JICA*

## (៧) សិទ្ធប្រើប្រាស់ដី និងការកាន់កាប់ដីនៅក្នុងតំបន់គំរោង (គ-១.៣.២)

យោងតាមការអង្កេតសេដ្ឋកិច្ចសង្គម ទំហំជាមធ្យមនៃដីស្រែដែលកាន់កាប់ដោយកសិករមានប្រមាណពី 0,60 ហិកតា ទៅ 0,84 ហិកតា ក្នុងមួយគ្រួសារនៅក្នុងតំបន់គំរោង។ លទ្ធផលដូចគ្នានេះ បង្ហាញថា ៩៨% នៃគ្រួសារកសិករ ដែលបានធ្វើអង្កេតនៅក្នុងតំបន់គំរោង គឺជាម្ចាស់ស្រែ និងធ្វើស្រូវខ្លួនឯង។

## (៨) ប្រតិទិនដាំដុះ និងប្រភេទដាំដុះដំណាំ (គ-១.៣.៣)

ប្រភេទដាំដុះដំណាំមាននៅក្នុងតំបន់គំរោង អាស្រ័យលើទឹកស្រោចស្រពគ្រប់គ្រាន់ ហើយត្រូវបានចាត់ថ្នាក់ជា ការដាំស្រូវមួយដង និងពីរដងក្នុងមួយឆ្នាំ ដូចមានបង្ហាញក្នុងតារាងខាងក្រោម។ ដំណាំផ្សេងៗទៀតក្រៅពីស្រូវមានការ ពិបាកដាំដុះណាស់នៅក្នុងតំបន់គំរោងនេះ។

**ប្រភេទដាំដុះមានក្នុងតំបន់គំរោង**

| ប្រភេទដាំដុះ | | ផ្ទៃដី (%) |
|---|---|---|
| ធ្វើស្រែម្តងក្នុង ១ ឆ្នាំ | ស្រូវរដូវវស្សា — ពុំមានការដាំដុះស្រូវ | 377 ha ( 65) |
| ធ្វើស្រែពីរដងក្នុង ១ ឆ្នាំ | ស្រូវបង្កើនរដូវ — ស្រូវរដូវវស្សា — ពុំមានការដាំដុះស្រូវ | 203 ha ( 35) |
| សរុបរួម | - | 580 ha (100) |

*ប្រភព: ក្រុមសិក្សាអង្គការ JICA*

## (៩) ផ្ទៃដីដាំដុះ និងដង់ស៊ីតេដំណាំ (គ-១.៣.៤)

ផ្ទៃដីដាំដុះ និងដង់ស៊ីតេដំណាំស្រូវនាពេលបច្ចុប្បន្ននៅក្នុងតំបន់គំរោង ត្រូវបានប៉ាន់ស្មានដូចខាងក្រោម:

**ការប៉ាន់ស្មានផ្ទៃដីដាំដុះ និងដង់ស៊ីតេដំណាំស្រូវនៅក្នុងតំបន់គំរោង**

| ប្រភេទនៃការប្រើប្រាស់ដី | ផ្ទៃដី (ha) (ផ្ទាល់) | សន្ទស្សន៍ | ផ្ទៃដីដាំដុះ និងដង់ស៊ីតេ | | |
|---|---|---|---|---|---|
| | | | ស្រូវដើមរដូវ | ស្រូវវស្សា | ប្រចាំឆ្នាំ |
| ធ្វើស្រែម្តងក្នុង ១ ឆ្នាំ | 377 | ផ្ទៃដីដាំដុះ (ha) | 0 | 377 | 377 |
| | | ដង់ស៊ីតេដាំដុះ (%) | - | 100 | 100 |

| | | | | | |
|---|---|---|---|---|---|
| ធ្វើស្រែពីរដងក្នុង ១ ឆ្នាំ | 203 | ផ្ទៃដីដាំដុះ (ha) | 203 | 203 | 406 |
| | | ដង់ស៊ីតេដាំដុះ (%) | 100 | 100 | 200 |
| តំបន់គំរោង | 580 | ផ្ទៃដីដាំដុះ (ha) | 203 | 580 | 783 |
| | | ដង់ស៊ីតេដាំដុះ (%) | 35 | 100 | 135 |

*ប្រភព: ក្រុមសិក្សាអង្គការ* JICA

## (១០) ការផលិត និងទិន្នផលដំណាំ (គ.១.៣.៥)

ទិន្នផលស្រូវនៅក្នុងតំបន់គំរោងដែលទទួលបានប្រមាណ ២,៣០ តោនក្នុង ១ ហិកតា សំរាប់ស្រូវប្រភេទមធ្យម ហើយសំរាប់ស្រូវបង្កើតទទួលបាន ២,៤ តោន ក្នុង ១ ហិកតា។ ផលិតផលស្រូវសរុបប្រចាំឆ្នាំនៅក្នុងតំបន់គំរោង មានប្រមាណ ១,៨២១ តោន។

## (១១) សេដ្ឋកិច្ចស្រូវនាពេលបច្ចុប្បន្ន (គ.១.៣.៦)

កសិករនៅតំបន់គំរោងត្រូវបានគេចែកចេញជាពីប្រភេទធំៗ គឺប្រភេទដាំដុះពីរដង（ប្រភេទ A） និងប្រភេទ ដាំដុះម្តង（ប្រភេទ A）។ សេដ្ឋកិច្ចស្រូវនាពេលបច្ចុប្បន្ននៃស្រែគំរូ មានបង្ហាញក្នុងតារាងខាងក្រោម។ ដូចបានបង្ហាញក្នុង តារាងខាងក្រោម ពុំមានភាពខុសគ្នាច្រើននៃការលើនៅក្នុងប្រភេទទាំងពីរនេះទេ ក៏ប៉ុន្តែមានលក្ខណៈសន្សំសំចៃនៅក៏រិត ទាបបំផុត។

**សេដ្ឋកិច្ចស្រូវនាពេលបច្ចុប្បន្ន (ឯកតា: ,000រៀល)**

| ពិពណ៌នា | | ប្រភេទ A | ប្រភេទ B | ភាពខុសគ្នា (A-B) |
|---|---|---|---|---|
| សរុប ចំណូល | ផលិតផលស្រូវ | 1,302 | 680 | 622 |
| | ចំណូលពីកសិផលផ្សេងៗ | 1,066 | 1,145 | - 79 |
| | ចំណូលក្រៅពីកសិផល | 2,267 | 1,959 | 308 |
| | ចំណូលសរុប | 4,635 | 3,784 | 851 |
| ចំណាយ | តំលៃផលិតនៃផលិតផលកិសកម្ម | 1,076 | 797 | 279 |
| | ចំណាយផ្សេងៗ | 3,017 | 2,483 | 534 |
| | ចំណាយសរុប | 4,093 | 3,280 | 813 |
| បរិមាណលើស ១សមត្ថភាពចំណាយច | | 542 | 504 | 38 |

*ប្រភព: ក្រុមសិក្សាអង្គការ* JICA

## (១២) ប្រឡាយស្រោចស្រព និងសំណង់ពាក់ព័ន្ធ (គ.១.៤.១)

តំបន់គំរោងគ្របដណ្តប់ដោយប្រព័ន្ធធារាសាស្ត្រ ដែលមានប្រឡាយមេខាងត្បូងប្រវែង ៧,៨ គ.ម ប្រឡាយរង ប្រវែង ៤ គ.ម ប្រឡាយរងថ្នាក់ទី ៣ ប្រវែង ១៥,៩ គ.ម និងសំណង់ពាក់ព័ន្ធចំនួន ៣៨ កន្លែង។ គ្រប់ប្រឡាយទាំងអស់ ជាប្រឡាយដី និងពុំមានការថែទាំល្អឡើយ។ សំណង់ខ្លះ និងស្ពានខ្លះធ្វើអំពីបេតុងអាម៉េ។ សំណង់ទាំងនេះ ស្ទើរតែមិន ដំណើរការ ទាមទារឱ្យមានការជួសជុល និងកែលំអជាបន្ទាន់ ជាពិសេសសំណង់បញ្ចូលទឹកក្នុងស្រែ និងសំណង់ស្ទាក់ទឹក។

## (១៣) ប្រភេទស្រោចស្រព (គ.១.៤.២)

ការផ្គត់ផ្គង់ទឹកនៅក្នុងតំបន់គំរោងគឺធ្វើឡើងដោយបង្ហៀរ ដោយបូម និងដោយមធ្យោបាយទាំងពីរប្រភេទ។ ការ អង្កេតសារពើភ័ណ្ឌបែងចែកផ្ទៃដីស្រោចស្រពតាមប្រភេទស្រោចស្រព ដោយបង្ហៀរមានចំនួន ៣០៦ ហិកតា ដោយ បូមមានចំនួន ១៩០ ហិកតា និងដោយបង្ហៀរ និងបូមមានចំនួន ៨៤ ហិកតា។

## (១៤) ប្រឡាយដោះទឹក និងសំណង់ពាក់ព័ន្ធ (គ.១.៤.៣)

ពុំមានប្រព័ន្ធដោះទឹកនៅក្នុងតំបន់គំរោងឡើយ។ បរិមាណទឹកលើស ត្រូវដោះតាមវាលស្រែមួយទៅវាលស្រែ មួយទៀត ហើយហូរទៅកន្លែងទំនាប ឬអូរដែលដើរតួនាទីជាប្រព័ន្ធដោះទឹក។ នៅក្នុងករណីខ្លះ ប្រឡាយដែលមានស្រាប់ មានតួនាទីទ្វេ គឺស្រោចស្រព និងដោះទឹក។ ចំណែកសំណង់ដោះទឹកផ្សេងៗទៀត ធ្វើឡើងដោយលូបេតុងហើយបង្កប់ ក្រោមបាត។

## (១៥) ការប្រើប្រាស់ និងថែទាំ (គ.១.៤.៥)

អង្កេតសារពើភ័ណ្ឌ និងព័ត៌មាន ប្រមូលដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ បង្ហាញថា ការទទួល ខុសត្រូវលើការប្រើប្រាស់ និងថែទាំប្រព័ន្ធស្រោចស្រពនៅក្នុងតំបន់គំរោង ត្រូវបានបែងចែកការទទួលខុសត្រូវដោយមន្ទីរ ធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ និងសហគមន៍កសិករប្រើប្រាស់ទឹកដូចខាងក្រោម:

**ការបែងចែកការទទួលខុសត្រូវសំរាប់ការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ**

| សំណង់ | មន្ទីរធនធានទឹក និង ឧតុនិយមខេត្តកំពង់ស្ពឺ | សហគមន៍កសិករប្រើប្រាស់ទឹក |
|---|---|---|
| (ក) ប្រឡាយមេខាងត្បូង | ទទួលខុសត្រូវ | X |
| (ខ) ប្រឡាយរងថ្នាក់ទី ២ | ទទួលខុសត្រូវរួមគ្នា | |
| (គ) ប្រឡាយរងថ្នាក់ទី ៣ | X | ទទួលខុសត្រូវ |
| (ឃ) ប្រឡាយបញ្ចូលស្រែ | X | ទទួលខុសត្រូវ |

*កំណត់សំគាល់: សហគមន៍កសិករប្រើប្រាស់ទឹក អូរវែង និងភូមិរូង*

ការប្រើប្រាស់ និងថែទាំសំណង់ពុំបានអនុវត្តបានល្អទេ ទាំងមន្ទីរធនធានទឹក និងឧតុនិយម ទាំងសហគមន៍កសិករ ប្រើប្រាស់ទឹក ដោយសារបញ្ហាហិរញ្ញវត្ថុ និងស្ថាប័ន។

## (១៦) ការគ្រប់គ្រងទឹក (គ.១.៤.៦)

យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមលើគ្រួសារចំនួន ១០០ នៅក្នុងតំបន់គំរោង បង្ហាញថាគ្រួសារចំនួន ៨៣ បាន ប្រើប្រាស់ទឹកស្រោចស្រពមិនទៀងទាត់តាមតំរូវការ។ បញ្ហាសំខាន់ គឺកំរិតកំពស់ទឹកនៅក្នុងប្រឡាយមេខាងត្បូងមានកំរិត ទាបដោយសារពុំមានសំណង់ស្ទាក់ទឹក និងការប្រើប្រាស់មិនបានល្អនូវទ្វារទឹកវត្តក្រូច និងការសន្សំសំចៃប្រេងសំរាប់បូមទឹក។

## (១៧) សហគមន៍កសិករប្រើប្រាស់ទឹក (គ.១.៥.៣)

មានសហគមន៍កសិករប្រើប្រាស់ទឹកក្នុងតំបន់គំរោងពីរ គឺអូរវែង និងភូមិរូង។ សហគមន៍ទាំងពីរនេះ រៀបចំដោយ គំនិតផ្តួចផ្តើមរបស់មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ និងម្ចាស់ជំនួយ ដូចជា អូរវែងដោយប្រាសាក់ និងភូមិរូង ដោយធនាគារពិភពលោក។ បច្ចុប្បន្ននេះសហគមន៍ទាំងពីរនេះ ចាត់ចែងដោយគណៈកម្មាធិការ រួមមានបុគ្គលិក ០៤ រូប ដែលមានប្រធាន ០១ រូប អនុប្រធានទី១ មួយរូប អនុប្រធានទី ២ មួយរូប និងគណេនី មួយរូប។ សមត្ថភាពនៃ សហគមន៍ទាំងពីរនេះ នៅទន់ខ្សោយ ហើយមានបញ្ហាច្រើនទាំងផ្នែករដ្ឋបាល ទាំងផ្នែកហិរញ្ញវត្ថុ។

## (១៨) សហគមន៍កសិករដទៃទៀត (គ.១.៥.៤)

យោងតាមលទ្ធផលនៃការអង្កេតកំរងសំណួរស្តីពីសហគមន៍កសិករ បង្ហាញថា សហគមន៍កសិករចំនួន ៣៦ ត្រូវបាន រៀបចំឡើងនៅក្នុងភូមិចំនួន ១៥ ក្នុងចំណោមភូមិចំនួន ១៨ នៃតំបន់គំរោង។ តាមការអង្កេតរួម បង្ហាញថា សហគមន៍ ទាំងនេះទើបតែបង្កើតឡើងក្នុងឆ្នាំ ២០០០ ផ្តួចផ្តើមឡើងដោយអង្គការក្រៅរដ្ឋាភិបាល (CEDAC, CGA, CWPD, RHAC) ស្ថាប័នមីក្រូហិរញ្ញវត្ថុ (Amret, ACLEDA Bank) និងម្ចាស់ជំនួយនានា (PRASAC, SEILA) ឬ គំរោងរបស់រដ្ឋាភិបាល (IMP)។ ក្នុងន័យនេះ ស្ទើរតែគ្រប់សហគមន៍គ្រាន់តែជាការប្រមូលផ្តុំកសិករដែលមានបំណងចូលរួម ក្នុងសកម្មភាពនានា ឬក្នុងវគ្គបណ្តុះបណ្តាលដែលផ្តល់ដោយម្ចាស់ជំនួយផ្សេងៗ។

### (១៩) សេវាទ្រទ្រង់កសិកម្ម (គ.១.៦)

សេវាទ្រទ្រង់កសិកម្មដែលមានសំរាប់គំរោងគឺ ១) ការស្រាវជ្រាវ និងការអភិវឌ្ឍន៍បច្ចេកទេសដោយវិទ្យាស្ថាន ស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កសិដ្ឋានរដ្ឋ និងស្ថានីយ៍ពិសោធន៍) ២) សេវាផ្សព្វផ្សាយដោយមន្ទីរកសិកម្ម ៣) ការផ្គត់ផ្គង់ និងការផលិតពូជដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កសិដ្ឋានរដ្ឋ និងអ្នកផលិតពូជ ពាណិជ្ជកម្ម) ៤) ការផ្គត់ផ្គង់ទុនសំរាប់កសិដ្ឋានដោយផ្នែកឯកជន និង ៥) ឥណទានកសិដ្ឋានដោយវិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាល។ ជាទូទៅ សេវាទ្រទ្រង់ទាំងនេះពឹងផ្អែកលើកម្មវិធីទ្រទ្រង់ដោយភ្នាក់ងារម្ចាស់ជំនួយ និងអង្គការ ក្រៅរដ្ឋាភិបាល ដោយសារបញ្ហាខ្វះថវិកានៃស្ថាប័នរដ្ឋាភិបាល ដូចជាមន្ទីរកសិកម្ម។

### (២០) បរិស្ថាន (គ.១៧)

បញ្ហាបរិស្ថាននានាដែលពាក់ព័ន្ធទៅនឹងគំរោងផ្ទាល់ដូចជា ការប្រើប្រាស់ទឹកសំរាប់គ្រួសារ ការបាត់បង់ដី និងការ ប្រើប្រាស់ជី។ យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមធ្វើឡើងនៅឆ្នាំ ២០០៥ បង្ហាញថា ៩%នៃគ្រួសារគំរូប្រើប្រាស់ទឹកក្នុងអាង ឬទឹកស្រះសំរាប់ហូបចុកប្រចាំថ្ងៃ និង ៤០% ប្រើប្រាស់ក្នុងគ្រួសារនៅក្នុងរដូវប្រាំង។ គ្រួសារគំរូជាង ៩៥% បានឆ្លើយថា តំលៃជីមានតំលៃថ្លៃ ក៏ប៉ុន្តែប្រហែល ២០% ចាត់ទុកថាការប្រើប្រាស់ជីគ្រប់គ្រាន់ និងត្រឹមត្រូវតាមកំរិត មាន ប្រសិទ្ធភាពក្នុងការកែលំអផលិតភាពស្រូវ ហើយការប្រើប្រាស់នេះអាចពាក់ព័ន្ធដល់ការបំពុលទឹកស្ទឹង ឬក៏នៅក្បែរអាងទឹក និងស្រះទឹក។ តាមការសាកសួរប្រជាកសិកររស់នៅក្នុងតំបន់គំរោងស្តីពីការបាត់បង់ដី បានបង្ហាញថា កសិករទាំងនោះទាម ទារឱ្យមានសំណងទៅលើការបាត់បង់ដី។ ចំនួន ៦៣% នៃចំនួនប្រជាកសិករដែលបានសំភាសន៍ទាមទារឱ្យមានការសងជាដី ចំណែក ៣៧% ទាមទារឱ្យសងជាថវិកា។

## ជំពូក គ.២ គំរោង

### (២១) គំរូវការអនុវត្តគម្រោងគំរូ (គ.២.១.១)

ធារាសាស្រ្តកសិកម្មនៅក្នុងតំបន់គោលដៅ ស្ថិតក្នុងតំណាក់កាលបែបបូរាណនៅឡើយពាក់ព័ន្ធនឹងការធ្វើស្រែ ការគ្រប់គ្រងទឹក និងសហគមន៍កសិករប្រើប្រាស់ទឹក។ ដើម្បីកែលំអស្ថានភាពបែបនេះ និងបង្កើតឡើងនូវយន្តការកែលំអ ផលិតភាពកសិកម្ម ការសិក្សាផែនការមេ បានលើកឡើងនូវសំណើអនុវត្តការអភិវឌ្ឍន៍ជាជំហាន១។ ក្នុងជំហានដំបូង ធារាសាស្រ្តកសិកម្មនៅតាមកំរិតវាលស្រែត្រូវបង្កើតឡើងជាគំរោងគំរូ ។ ក្នុងគំរោងគំរូនេះ ការគ្រប់គ្រងទឹក ការធ្វើស្រែ និងសកម្មភាពសហគមន៍កសិករប្រើប្រាស់ទឹកនឹងត្រូវបានកែលំអនៅកំរិតវាលស្រែ។ ក្នុងតំណាក់កាលទី ២ នៅលើផ្ទៃដីធំ ការគ្រប់គ្រងប្រព័ន្ធធារាសាស្រ្តពីប្រឡាយមេដល់សំណង់បញ្ចូលស្រែនឹងត្រូវបង្កើតឡើង ហើយបន្ទាប់មកការគ្រប់គ្រងទឹក មានលក្ខណៈសមស្រប ការកែលំអរបៀបធ្វើស្រែ និងពង្រឹងសកម្មភាពសហគមន៍កសិករប្រើប្រាស់ទឹកត្រូវបានពង្រីក ហើយ បង្ហាញជាគំរោងគំរូនៅលើផ្ទៃដីធារាសាស្រ្តកសិកម្មដែលនៅសេសសល់ក្នុងតំបន់គោលដៅ។ ជំហានទី១ គំរោងគំរូបានចាប់ផ្តើមដំណើរការក្រោមការសិក្សា។ បច្ចុប្បន្ននេះ ដល់ពេលដំណាក់កាលទី ២ ដែលគំរោងត្រូវចាប់ផ្តើមអនុវត្តគំរោងគំរូកែ លំអធារាសាស្រ្តកសិកម្ម។

### (២២) គោលបំណង និងទស្សនៈមូលដ្ឋាន (គ.២.១.២)

គំរោងមានបំណងបង្ហាញពីការគ្រប់គ្រងទឹកសមស្រប និងបង្កើនផលិតផលស្រូវ ដោយសុខដុមរម្យកម្មកសិកម្ម ការដោះទឹក និងការស្រោចស្រពនិងស្ថាប័នរួមគ្នាល្អ។ ដើម្បីសំរេចបាននូវគោលបំណងនេះ យុទ្ធសាស្រ្តមូលដ្ឋានលំអិត សំរាប់ការអភិវឌ្ឍន៍គំរោងគឺ " ការរៀបចំផែនការអភិវឌ្ឍន៍អនុវត្តដោយផ្តោតការយកចិត្តទុកដាក់លើការផ្សព្វផ្សាយការកែ លំអការអនុវត្តន៍របៀបធ្វើស្រែ បង្កើតឡើងការគ្រប់គ្រងទឹកសមស្រប និងការពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក " ដោយ ពិចារណាលើបទពិសោធន៍ក្នុងគំរោងគំរូ។ រូបភាពទស្សនៈអភិវឌ្ឍន៍សំរាប់គំរោងត្រូវបានបង្ហាញដូចខាងក្រោម:

រូបភាពគោលគំនិតអភិវឌ្ឍន៍




## (២៣) ផែនការអភិវឌ្ឍន៍កសិកម្ម (គ-២.២)

### (ក) ទស្សនៈអភិវឌ្ឍន៍

អភិក្រមនៃការអភិវឌ្ឍន៍ដែលស្នើឡើង គឺការអភិវឌ្ឍន៍ធារាសាស្ត្រកសិកម្ម ហើយមានទិសដៅ ១) កែលំអផលិតភាព និងការបង្កើនផលិតផលស្រូវ ២) កែលំអដង់ស៊ីតេការប្រើប្រាស់ដីដោយណែនាំវិធីសាស្ត្រ ធ្វើស្រែពីរដងក្នុងមួយរដូវ និង ៣) ការកែលំអដង់ស៊ីតេការប្រើប្រាស់ដីតាមរយៈការណែនាំការដាំដុះដំណាំដីលើ ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍នានាដើម្បីទទួលបាននូវគោលដៅទាំងនេះ គឺ ១) ណែនាំរបៀបធ្វើស្រែពីរដងក្នុង១រដូវឱ្យបានច្រើនដែលអាចធ្វើទៅបាន ២) ពង្រឹងសេវាទ្រទ្រង់កសិកម្មដល់កសិករតាមទស្សនៈការចូលរួម ៣) ណែនាំរបៀបដាំស្រូវបែបសន្សំសំចៃទឹក និង ៤) ណែនាំរបៀបដាំដុះដំណាំ ឬបន្លែដីលើ ។

### (ខ) សំណើរបៀបដាំដុះ និងដង់ស៊ីតេដំណាំ និងផ្ទៃដីដាំដុះ

យោងតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបានរៀបរាប់ខាងលើ របៀបដាំដុះ និងដង់ស៊ីតេដំណាំ និងផ្ទៃដីដាំដុះត្រូវបានស្នើឡើងដូចខាងក្រោម:

**សំណើរបៀបដាំដុះ និងដង់ស៊ីតេដំណាំ និងផ្ទៃដីដាំដុះ (ឯកតា: ហិកតា និង %)**

| ដំណាំ | ស្រូវបង្កើនរដូវ | | ស្រូវរដូវវស្សា | | ផលស្រូវប្រចាំឆ្នាំ | | ផលស្រូវបច្ចុប្បន្ន | | ផ្ទៃដី | ដង់ស៊ីតេ |
|---|---|---|---|---|---|---|---|---|---|---|
| | ផ្ទៃដី | ដង់ស៊ីតេ | ផ្ទៃដី | ដង់ស៊ីតេ | ផ្ទៃដី | ដង់ស៊ីតេ | ផ្ទៃដី | ដង់ស៊ីតេ | (ហិក) | (%) |
| ស្រូវបង្កើនរដូវ | 285 | 50 | 285 | 50 | 570 | 100 | 203 | 35 | 367 | 65 |
| ស្រូវមធ្យម | - | - | 285 | 50 | 285 | 50 | 580 | 100 | -295 | -50 |
| ផលស្រូវសរុប | 285 | 55 | 570 | 100 | 855 | 150 | 783 | 135 | 72 | 15 |
| ដំណាំដីលើ 1/ | 30 | 5 | - | - | 30 | 5 | - | - | 30 | 5 |
| សរុប | 315 | 55 | 570 | 100 | 885 | 155 | 783 | 135 | 102 | 20 |

*1/: រាប់បញ្ចូលទាំងបន្លែ*

### (គ) ផ្ទៃដីដាំដុះប្រចាំឆ្នាំ និងផលិតផលដំណាំក្នុងល័ក្ខខ័ណ្ឌគ្មានគំរោង និងគ្មានគំរោង

ផលិតផលដំណាំស្ថិតក្នុងលក្ខខ័ណ្ឌមានគំរោង និងគ្មានគំរោង ត្រូវបានប៉ាន់ស្មានដោយផ្អែកលើ មូលដ្ឋានផ្ទៃដីដាំដុះគ្រោង និងទិន្នផលដំណាំគ្រោង មានដូចខាងក្រោម:

**ផ្ទៃដីដាំដុះប្រចាំឆ្នាំ និងផលិតផលដំណាំក្នុងល័ក្ខខ័ណ្ឌមានគំរោង និងគ្មានគំរោង**

| ដំណាំ | ប្រភេទ | គ្មានគំរោង | មានគំរោង | ចំនួនបន្ថែម 1/ | |
|---|---|---|---|---|---|
| | | | | ផ្ទៃដី / ផលិតផល | % |
| 1. ស្រូវបង្កើនរដូវវស្សា (ស្រូវដើមរដូវ) | - ផ្ទៃដីដំណាំ (ha) | 203 | 285 | + 82 | 40 |
| | -ទិន្នផលដំណាំ (ton)/ (ha) | 2.4 | 3.8 | 1.4 | |
| | - ផលិតផល (ton) 2/ | 487 | 1,083 | + 596 | 122 |
| 2. ស្រូវរដូវវស្សា (ស្រូវស្រាល) | - ផ្ទៃដីដំណាំ (ha) | - | 285 | + 285 | - |
| | - ទិន្នផលដំណាំ (ton)/ (ha) | - | 3.8 | | |
| | - ផលិតផល (ton) 2/ | - | 1,083 | + 1,083 | - |
| 3. ស្រូវរដូវវស្សា (ស្រូវមធ្យម) | - ផ្ទៃដីដំណាំ (ha) | 580 | 285 | - 295 | 51 |
| | -ទិន្នផលដំណាំ (ton)/ (ha) | 3.2 | 3.3 | 1.0 | |
| | - ផលិតផល (ton) 2/ | 1,334 | 941 | - 393 | 29 |
| 4. ស្រូវសរុប | - ផ្ទៃដីដំណាំ (ha) | 783 | 855 | + 72 | - 9 |
| | -ទិន្នផលដំណាំ (ton)/ (ha) | 2.4 | 3.8 | 1.4 | |
| | - ផលិតផល (ton) 2/ | 1,821 | 3,107 | 1,286 | 71 |
| 5. ដំណាំដីលើ 3/ | - ផ្ទៃដីដំណាំ (ha) | - | 30 | 30 | - |
| | -ទិន្នផលដំណាំ (ton)/ (ha) | - | 0.7 | | |
| | - ផលិតផល (ton) 2/ | - | 21 | 21 | - |

*1/( គ្មាន និងមានគំរោង) x 100 2/: ផលិតផលស្រូវ 3/: តំណាងដោយ សណ្តែកបាយ*

ដូចបានកំណត់ក្នុងតារាងខាងលើ គំរោងបានផ្តោតទៅលើ:

- ការប្រើប្រាស់ប្រភពទឹកមានកំណត់ប្រកបដោយប្រសិទ្ធិភាព តាមរយ:ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់ គ្រងទឹក និងការជួសជុលឡើងវិញនូវសំណង់ស្រោចស្រព និងសំណង់ដោះទឹកដែលមានស្រាប់, ការធ្វើឱ្យមានស្ថេរភាពនូវដំណាំស្រូវរដូវវស្សាដោយការស្រោចស្រពបន្ថែម, ការពង្រីកផ្ទៃដីដំណាំ និងផ្ទៃដីស្រោចស្រពនៃស្រូវបង្កើនរដូវដោយការសន្សំសំចៃទឹកស្រោចស្រព (ពី ២០៣ ហិកតា ទៅ ២៨៥ ហិកតា) ។
- ការបង្កើនទិន្នផល និងផលិតផលស្រូវ (ស្រូវបង្កើនរដូវពី ២,៤ ទៅ ៣,៨ តោន/ហត សំរាប់ស្រូវដើមរដូវ ពី ២,៣ ទៅ ៣,៣ តោន/ហត សំរាប់ស្រូវកណ្តាលពី ២,៤ ទៅ ៣,៨ តោន/ហត) ។
- ដំណាំឆ្លាស់គ្នា និងការបង្កើនអាំតង់ស៊ីតេដំណាំ ដោយណែនាំឱ្យដាំដំណាំដីខ្ពស់ ។

### (ឃ) សេដ្ឋកិច្ចគ្រួសារកសិករ

លទ្ធផលនៃការវិភាគសេដ្ឋកិច្ចកសិករប្រភេទគំរូ (គ្រួសារធ្វើស្រែពីរដង (ប្រភេទ ក) និងគ្រួសារធ្វើ ស្រែមួយដង (ប្រភេទ ខ) ត្រូវបានបង្ហាញដូចខាងក្រោមនេះ:

**សេដ្ឋកិច្ចកសិករស្ថិតក្នុងលក្ខខ័ណ្ឌមានគំរោង (ឯកតា: ,000រៀល)**

| | | ប្រភេទ ក | | ប្រភេទ ខ | |
|---|---|---|---|---|---|
| | | បន្ទាប់គំរោង | ភាពខុសគ្នាមុន និងក្រោយគំរោង | បន្ទាប់គំរោង | ភាពខុសគ្នាមុន និងក្រោយគំរោង |
| ចំណូលសរុប | ផលិតផលស្រូវ | 1,986 | | 1,385 | |
| | ចំណូលផ្សេងៗរបស់កសិករ 1/ | 1,066 | | 1,145 | |

| | | | | | |
|---|---|---|---|---|---|
| | ចំណូលក្រៅពីស្រូវ | 2,267 | | 1,959 | |
| | ចំណូលសរុប | 5,319 | +684 | 4,489 | +705 |
| ចំណាយ | តំលៃផលិតកម្មនៃផលិតផលស្រូវ | 1,291 | | 1,054 | |
| | ចំណាយផ្សេងៗ 1/ | 3,017 | | 2,483 | |
| | ចំណាយសរុប | 4,308 | +215 | 3,537 | +257 |
| បរិមាណលើស (សមត្ថភាពអាចចំណាយ) | | 1,011 | +469 | 952 | +448 |

*ប្រភព: ក្រុមសិក្សា JICA 1/: ការចិញ្ចឹមសត្វ, នេសាទ និងដំណាំផ្សេងៗក្រៅពីស្រូវ*

**(ង) សំណើវិធីសាស្ត្រសំរាប់កែលំអទីផ្សារ**

សំណើវិធីសាស្ត្រនានា សំរាប់ដោះស្រាយបញ្ហាតំលៃស្រូវទាបនៅទីផ្សារ និងតំលៃទីផ្សារមិនស្ថិតស្ថេរ ព្រមទាំងតំរូវការទីផ្សារមានកំណត់ មានដូចខាងក្រោម:

១) ការកែលំអផលិតភាព និងគុណភាពផលិតផលតាមរយះការកែលំអការដាំដុះដំណាំ

២) រៀបចំក្រុមកសិករ និងណែនាំសកម្មភាពសេដ្ឋកិច្ចជាក្រុម ដូចជា ក្រុមទិញទុនចូលកសិកម្ម និងក្រុមផ្ទេរបច្ចេកវិទ្យាក្នុងក្រុម និងក្នុងចំណោមក្រុម។

៣) ណែនាំអំពីការរីកលូតលាស់នៃកិច្ចសន្យា និងកិច្ចព្រមព្រៀងជាដៃគូរ

៤) បង្កើនសកម្មភាពសេដ្ឋកិច្ចឆ្ពោះទៅរកការនាំចេញរួម និងទីផ្សាររួម

៥) រៀបចំសហករដោយចងក្រងជាក្រុម

## (២៤) ផែនការកែលំអការស្រោចស្រព និងការដោះទឹក (គ.២.៣)

**(ក) ទស្សនៈអភិវឌ្ឍន៍**

គំរោងមានគោលបំណងបង្ហាញការគ្រប់គ្រងទឹកសមស្រប និងបង្កើនផលិតផលស្រូវក្នុងតំបន់គំរោងដែលប្រតិបត្តិដោយសុខុដម្បនីយ៍កម្មកសិកម្មល្អ, ការស្រោចស្រព, ការដោះទឹក និងការអភិវឌ្ឍន៍ស្ថាប័ន។ ដើម្បី សំរេចគោលបំណងនេះ ផែនការកែលំអការស្រោចស្រព និងការដោះទឹក ត្រូវបានអនុវត្តស្របគ្នាជាមួយ យុទ្ធសាស្ត្រដូចខាងក្រោម:

| | |
|---|---|
| ផែនការកែលំអការស្រោចស្រព | - ការប្រើប្រាស់អតិបរមានៃសំណង់ដែលមានស្រាប់ |
| | - ការជួសជុលអប្បបរមា/ កែលំអការងារ |
| | - ប្រើប្រាស់ដីល្អសំរាប់ភ្លឺប្រឡាយ |
| | - អនុវត្តន៏របៀបស្រោចស្រពដោយបង្វេរ |
| | - អនុវត្តន៏ដង់ស៊ីតេចំពោះប្រឡាយតូច |
| ផែនការកែលំអការដោះទឹក | - រៀបចំប្រព័ន្ធដោះទឹកដោយឡែក |
| | - ប្រើប្រាស់អូរ-ស្ទឹងធម្មជាតិតូចៗ និងតំបន់ទំនាបជាប្រព័ន្ធដោះទឹក |

**(ខ) ការពង្រាងខ្សែប្រលាយ**

ប្លង់រួមរបស់ប្រលាយក្នុងតំបន់គំរោងត្រូវបានគ្រោងដោយពិចារណាទៅតាមហេតុការណ៍ ដែលបន្ថែមលើយុទ្ធសាស្ត្រមូលដ្ឋានដូចខាងក្រោម:

១- ទំហំនៃផ្ទៃដីស្រោចស្រពប្រលាយថ្នាក់ទី ៣

២- ប្រវែងប្រលាយថ្នាក់ទី៣

៣- ទំហំនៃផ្ទៃដីស្រោចស្រពប្រលាយនាំទឹកបញ្ចូលស្រែ

៤- ផ្ទៃដីរបស់ប្រលាយនាំទឹកបញ្ចូលស្រែនីមួយៗដែលត្រូវស្រោចស្រពដោយប្រលាយថ្នាក់ទី៣

ជាលទ្ធផលប្រវែងប្រលាយគ្រោងរបស់ប្រឡាយមេខាងត្បូងមានប្រវែង ៧.៨ គម, ប្រលាយថ្នាក់ ទី២ មាន ប្រវែង ៤.៦៧ គម, ប្រលាយថ្នាក់ទី៣ មានប្រវែង ១៨.៣៤ គម និងប្រលាយបញ្ចូលស្រែ ១៤២.៥ គម។ ចំណែកប្រវែងគ្រោងប្រឡាយមេដោះទឹកមានប្រវែង ០.៣ គ.ម, ប្រវែងរងដោះទឹកមាន ប្រវែង ៨.០ គ.ម និងប្រឡាយដោះទឹកថ្នាក់ទី៣ មានប្រវែង ១៥.១ គ.ម។

**(គ) ការគ្រោងធារទឹក**

ក្នុងការរៀបចំផែនការកែលំអការស្រោចស្រព និងដោះទឹក ធារទឹកគ្រោង ដែលបង្ហាញនៅខាងក្រោម ត្រូវបានយកមកប្រើប្រាស់។ ដោយឡែក ធារទឹកគ្រោងសំរាប់ស្រោចស្រពត្រូវបានប៉ាន់ស្មានដោយផ្អែកលើ គោលគំនិតការសន្សំទឹកស្រោចស្រព។

១) ធារទឹកគ្រោងសំរាប់ស្រោចស្រព (រយៈពេល ០៥ឆ្នាំ កើតមានឡើងម្តងៈ ប្រសិទ្ធភាពស្រោច ស្រពរួមចំនួន ៦៦% សំរាប់ដំណាំស្រូវ និង ៥៣% សំរាប់ដំណាំដីខ្ពស់)

-ប្រលាយមេ : ១.៦០លីត្រ/វិនាទី/ហត

-ប្រលាយរង : ១.៤១លីត្រ/វិនាទី/ហត

-ប្រលាយរងទី៣: ២.១០លីត្រ/វិនាទី/ហត (អនុវត្តការស្រោចស្រពឆ្លាស់វេន)

២) បិរមាណធារទឹកគ្រោងសំរាប់ដោះទឹក

- ៥លីត្រ/វិនាទី/ហត (ដោះទឹកចំនួន ០៣ ថ្ងៃ សំរាប់ភ្លៀងជាប់គ្នា ០៣ ថ្ងៃ ដោយការប៉ាន់ស្មាន រយៈពេល ០៥ឆ្នាំ កើតមានឡើងម្តង)

**(ឃ) ការគ្រោងប្លង់ប្រលាយ និងសំណង់ផ្សេងៗ**

គ្រប់ប្រលាយទាំងអស់ត្រូវបានគ្រោងជាប្រឡាយមិនមែនបេតុង ដែលមានមុខកាត់រាងចតុកោណព្នាយ។ ចំនួនសំណង់ដែលត្រូវសាងសង់ថ្មី ឬជួសជុលឡើងវិញសំរាប់ប្រព័ន្ធស្រោចស្រព គឺមានសំណង់នាំទឹកចូលចំនួន ០៣, សំណង់នាំទឹកចេញចំនួន ១៧, សំណង់ស្ទាក់ទឹកចំនួន ០៧, ទំនប់បង្វៀរចំនួន ០៣, ស្ពានចំនួន ០៤, លូប្រអប់ចំនួន ០១, លូបេតុងចំនួន ១៥, ជើងស្ពានចំនួន ០៣, បំពង់បង្ហូរដោះទឹកចំនួន ០៣ និងប្រអប់ចែក ចាយទឹកចំនួន ៨៥។ លើសពីនេះតំរូវឱ្យមានសំណង់ដោះទឹកឆ្លងកាត់ប្រលាយចំនួន ៣២ និងសំណង់កាត់គ្នាចំនួន ១៨។

## (២៥) ផែនការប្រើប្រាស់ ថែទាំ និងការគ្រប់គ្រងទឹក (គ.២.៣.៤ និង គ.២.៣.៥)

ដោយពិនិត្យលើគោលនយោបាយនេះ, សមត្ថភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹកបច្ចុប្បន្ន, ទំហំរបស់ប្រលាយ និងសារសំខាន់របស់សំណង់សំរាប់ការគ្រប់គ្រងគំរោង ខាងក្រោមនេះគឺជាការបែងចែកការទទួលខុសត្រូវដែលបានស្នើៈ

**សំណើនៃការបែងចែកការទទួលខុសត្រូវសំរាប់ការប្រើប្រាស់ និងថែទាំ**

| ស្ថាប័នទទួលខុសត្រូវ | អ្នកទទួលខុសត្រូវ | ប្រលាយ | ការទទួលខុសត្រូវសំរាប់ O&M |
|---|---|---|---|
| រដ្ឋាភិបាល | ការិយាល័យគំរោង | ប្រលាយមេខាងត្បូង | ប្រលាយមេខាងត្បូង និងគ្រប់គ្រងទ្វារទឹកសំរាប់ នាំទឹកទៅប្រលាយរង |
| ស.ក.ប.ទ អូរវែង និងស.ក.ប.ទ ភូមិរូង | ស.ក.ប.ទ | ប្រលាយរង | ប្រលាយរង និងគ្រប់គ្រងទ្វារទឹកសំរាប់ទឹកទៅ ប្រលាយបញ្ចូលស្រែ |
| | ក.ក.ប.ទ | ប្រលាយរងទី៣ | ប្រលាយរងទី៣ និងគ្រប់គ្រងប្រអប់ចែកចាយទឹក/នាំទឹកចេញទៅប្រលាយបញ្ចូលស្រែ |
| | ក.ប.ទ | ប្រលាយបញ្ចូលស្រែ | ប្រលាយបញ្ចូលស្រែ និងគ្រប់គ្រងប្រអប់ចែកចាយទឹកទៅស្រែនិមួយៗ |

ការបើកបិទទ្វារទឹកសំរាប់ប្រលាយនិមួយៗ ត្រូវអនុវត្តឱ្យស្របនិងផែនការសេវាកម្មស្រោចស្រព។ ការផ្គត់ផ្គង់ទឹក ទៅប្រលាយមេខាងត្បូង និងប្រលាយរង ត្រូវធ្វើជាប្រចាំពេញមួយឆ្នាំលើកលែងតែខែ កុម្ភះ និងមីនា។ សំរាប់ប្រលាយរង ទី៣ ការផ្គត់ផ្គង់ទឹកឆ្លាស់វេនគ្នា នឹងត្រូវបានដាក់ស្នើដើម្បីឱ្យទឹកអាចចែកចាយទៅដល់ចុងប្រលាយ ។

ស្របពេលជាមួយការប្រើប្រាស់សមស្រប ការថែទាំជាប្រចាំ និងសមស្របនៃសំណង់គំរោង គឺមានភាពចាំបាច់ណាស់ ដើម្បីធានាដល់ដំណើររឹងមាំ និងសមស្រប និងសំរេចបាននូវការប្រើប្រាស់សំណង់យូរអង្វែង។ ការងារថែទាំដ៏ទូលំទូលាយរួម មានៈ

- ការងារថែទាំជាប្រចាំ គឺជាការថែទាំជាប្រចាំ និងកែលំអរសំណង់ទាំងឡាយនៃគំរោង
- ការងារថែទាំម្តងម្កាល រួមមានការជួសជុលការខូចខាតបន្តិចបន្តួច
- ការងារជួសជុលបន្ទាន់ រួមមានការជួសជុលការខូចខាតដែលមិនបានគ្រោងទុក ដែលបណ្តាលមកពីជំនន់ ដោយភ្លៀងជោកជាំ ឬករណីផ្សេងៗទៀត ។
- ការជួសជុលប្រចាំឆ្នាំ ទាក់ទងទៅនឹងទំហំការងារធំ ឬតំរូវឱ្យមានជំនាញពិតប្រាកដ

## (២៦) ផែនការពង្រឹងសេវាកម្មគាំទ្រកសិកម្ម (គ.២.៤)

### (ក) វិធានការមូលដ្ឋាន

ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍន៍ក្នុងតំបន់គំរោង និងការគិតគូលិ្អតល្អន់លើតួនាទីនៃគំរោង គំរូការពង្រឹងសេវាកម្មគាំទ្រកសិកម្មគឺជាការចាំបាច់ដើម្បីធានាការសំរេចនៃគោលដៅគំរោងក្នុងដំណាក់កាលដំបូង។

ដូច្នេះការពង្រឹងសេវាកម្មគាំទ្រកសិកម្មត្រូវបានពង្រឹងជាមួយនឹងគោលដៅមួយចំនួនដូចតទៅ:

១- ការអភិវឌ្ឍន៍ និងផ្សព្វផ្សាយនូវបច្ចេកវិជ្ជាកសិកម្មប្រកបដោយនិរន្តរភាពលើផលិតកម្មស្រូវ ដើម្បីជំរុញផលិតភាពសកម្មភាពកសិកម្មចំបងក្នុងតំបន់គំរោង។

២- ការផ្តល់សិទ្ធដល់បុគ្គលិកផ្សព្វផ្សាយដោយវិធីរៀនសូត្រតាមការអនុវត្តន៍ជាក់ស្តែង

៣- ផ្សព្វផ្សាយចំពោះការផ្ទេរបច្ចេកវិជ្ជាពីកសិករទៅកសិករ

៤- ការអភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកវិជ្ជាសំរាប់ដំណាំដីខ្ពស់ និងការដាំបន្លែ

៥- បង្កើតស្ថាប័នមួយ ដែលទទួលខុសត្រូវលើការផ្សព្វផ្សាយការកែលំអផលិតភាពកសិកម្មនៅក្នុង និងជុំវិញតំបន់គំរោងនៅដំណាក់កាលចាប់ផ្តើមគំរោង។

### (ខ) ផែនការដែលបានស្នើ

សេវាកម្មគាំទ្រកសិកម្មតម្រូវឱ្យមានការផ្សព្វផ្សាយការអនុវត្តន៍កសិកម្មដែលបានស្នើ និងដើម្បីសំរេចគោលដៅនៃវិធីដំដុះគ្រោងរបស់គំរោង, អាំតង់ស៊ីតេដំណាំ និងទិន្នផលដំណាំ ក្នុងដំណាក់កាលដំបូង ដូចមានបង្ហាញក្នុង តារាងខាងក្រោម:

**សេវាកម្មគាំទ្រកសិកម្មដែលបានស្នើ**

| សកម្មភាព | តម្រូវការកម្មវិធី |
|---|---|
| កម្មវិធីផ្សព្វផ្សាយនៅទីវាល | ការបង្ហាញនៅក្នុងតំបន់ និងស្រែ, ការផ្លាស់ប្តូរពិសោធន៍ កម្មវិធីជ្រើសរើសពូជ |
| កម្មវិធីបណ្តុះបណ្តាលកសិករ/ក្រុមកសិករ | កម្មវិធីបណ្តុះបណ្តាល, សាលាវាលស្រែកសិករ, ទស្សនៈកិច្ច សិក្សា, បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយតាមភូមិ |
| ការណែនាំជាក្រុម/សិក្ខាសាលា | ការណែនាំជាក្រុម/សិក្ខាសាលា |
| គាំទ្រការផ្សព្វផ្សាយពីកសិករ ទៅកសិករ 1/ | គាំទ្រការផ្សព្វផ្សាយពីកសិករ ទៅកសិករ |
| បង្កើនសមត្ថភាពបុគ្គលិក | បណ្តុះបណ្តាលបុគ្គលិក, ពង្រឹងការងារដឹកនាំ |

1/ *ផ្តល់ការគាំទ្រសំរាប់ការផ្សព្វផ្សាយពីកសិករ ទៅកសិករ ដោយភ្នាក់ងារផ្សព្វផ្សាយភូមិ*

## (២៧) ផែនការពង្រឹងស្ថាប័ន (គ.២.៥)

ការពង្រឹងស្ថាប័នគឺជាផ្នែកមួយនៃកត្តាជាច្រើនដែលមិនអាចចៀសរួច ដើម្បីសំរេចបានគោលដៅយុទ្ធសាស្ត្រនៃផែន ការមេ គឺការកែលំអផលិតភាពកសិកម្មផ្តោតលើដំណាំស្រូវ។ នៅក្នុងគំរោងនេះ ផែនការពង្រឹង ០៤ យ៉ាង ត្រូវបានដាក់ចេញ ជាពិសេសផ្តោតទៅលើតួនាទីជាគំរោងគំរូ។

### (ក) ការពង្រឹងមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ

គោលបំណងនៃការពង្រឹងមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថ ភាពការងារ និងសមត្ថភាពមន្ត្រីមន្ទីធនធានទឹក និងឧតុនិយមខេត្ត ក្នុងគោលបំណងធ្វើឱ្យសំរេចបាននូវគោលដៅ យុទ្ធសាស្ត្រដែលបានរៀបរាប់កន្លងមក។ ដើម្បីសំរេចបានគោលដៅនេះ ទាមទារឱ្យមាននូវសកម្មភាពដូចខាងក្រោម:

1. រៀបចំសិក្ខាសាលាស្តីពី SWOT ដោយមានការចូលរួម
2. រៀបចំសកម្មភាពបង្កើនសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាល, ទស្សនៈកិច្ចសិក្សា និងការរៀនផង ធ្វើការផង
3. បន្តកិច្ចប្រជុំជាប្រចាំរវាងការិយាល័យ និងការិយាល័យ
4. ការពិនិត្យតាមដាន និងវាយតំលៃ

### (ខ) ពង្រឹងការសំរបសំរួលរវាងមន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ

ការពង្រឹងការសំរបសំរួលរវាងមន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម មានគោលដៅពង្រឹងទំនាក់ ទំនងរវាងមន្ទីរខេត្តពីរដែលទាក់ទងនឹងការអភិវឌ្ឍន៍ធារាសាស្ត្រកសិកម្ម។ ដើម្បីសំរេចគោលដៅនេះ ការិយាល័យ គំរោងមួយនឹងត្រូវរៀបចំឡើង ហើយសកម្មភាពមួយចំនួនដូចខាងក្រោមនឹងត្រូវអនុវត្តដោយការិយាល័យនេះ ១) ការបន្តកិច្ចប្រជុំជាប្រចាំ ២) ការបោះពុម្ពផ្សាយពិតមានស្តីពីគំរោង និង ៣) ការតាមដាន និងវាយតំលៃ។

### (គ) ការពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក (FWUC)

គោលបំណងនៃការពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) គឺដើម្បីអភិវឌ្ឍន៍ និងធ្វើឱ្យប្រសើរ ឡើងនូវមុខងាររបស់ FWUC ដោយយោលទៅលើលក្ខន្តិកៈ FWUC គោលគំនិតរបស់ PIMD និងដោយយោល ទៅលើបទពិសោធន៍នៃគំរោងសាកល្បង។ សំណើដែលឈានទៅរកការពង្រឹង FWUC និមួយៗ មានដូចខាង ក្រោម:

| អូរវែង ស.ក.ប.ទ | ភូមិរូង ស.ក.ប.ទ |
|---|---|
| (១) ការរៀបចំផែនទីម្ចាស់កម្មសិទ្ធិ និងការកាន់កាប់ដី នៃការគ្រប់គ្រងដីរបស់ ស.ក.ប.ទ អូរវែង | (១) បញ្ចប់ និងកែតំរូវឡើងវិញនូវផែនទីម្ចាស់កម្មសិទ្ធិ និងការកាន់កាប់ដី នៃការគ្រប់គ្រងដីរបស់ ស.ក.ប.ទ ភូមិរូង |
| (២) ការជ្រើសរើសឡើងវិញនូវតំណាងក្រុម និងអនុក្រុមកសិករប្រើប្រាស់ទឹក និងក្រុមប្រើប្រាស់ទឹកទៅតាម ខ្សែប្រលាយដែលបានគ្រោង | (២) ការជ្រើសរើសតំណាងក្រុមប្រើប្រាស់ទឹកសំរាប់ ប្រលាយរងដែលសាងសង់ថ្មី |
| (៣) រៀបចំការបណ្តុះបណ្តាលលើមុខវិជ្ជាផ្សេងៗដែលជាតំរូវការ សំរាប់គ្រប់គ្រង **ស.ក.ប.ទ** ដោយចាប់ផ្តើមពីការរៀបចំកិច្ច ប្រជុំ និងការសំរបសំរួលកិច្ចប្រជុំ | (៣) ការចែកចាយទស្សនាវដ្តីរូបភាព ដើម្បីផ្តល់ពិតមាន ដែលទាក់ទងទៅនឹងសកម្មភាព **ស.ក.ប.ទ** |
| (៤) សាងសង់អាគារការិយាល័យ **ស.ក.ប.ទ** | (៤) រៀបចំការបណ្តុះបណ្តាលស្តីពីការរៀបចំ និងធ្វើសំណើ |
| (៥) រៀបចំការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ | (៥) ការបន្តផ្តល់ការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាព និងការផ្តល់សេវាកម្មគាំទ្រដោយមន្ទីរធ.ទ.ឧ |
| (៦) ការចែកចាយទស្សនាវដ្តីរូបភាព ដើម្បីផ្តល់ព័ត៌មាន ដែលទាក់ទងទៅនឹងសកម្មភាព **ស.ក.ប.ទ** | |

| | |
|---|---|
| (៧) ស្ថាប័ន្ទរដ្ឋាភិបាលដែលពាក់ព័ន្ធ ផ្ដួចផ្ដើមគំនិតរៀបចំកិច្ចព្រមព្រៀងសំរាប់ផ្ទេរការគ្រប់គ្រងជាមួយគណៈកម្មាធិការ **ស.ក.ប.ទ** | |
| (៨) រៀបចំការបណ្ដុះបណ្ដាលស្ដីពីសិក្សាសមិទ្ធិងាយៗ, ការប៉ាន់តំលៃ និងការរៀបចំសំណើគំរោង | |
| (៩) ការផ្ដល់ការបណ្ដុះបណ្ដាលបន្តលើការបង្កើនសមត្ថភាព និងសេវាកម្មគាំទ្រដោយមន្ទីរធ.ទ.ឧ | |

**(៤) ការអភិវឌ្ឍន៍នូវការរៀបចំក្រុមកសិករ**

នៅក្នុងតំបន់គំរោង មានក្រុមអង្គការ CEDAC ចំនួន ០៤ ក្រុម និងក្រុមសន្សំប្រាក់របស់ IPM ចំនួន ០២ ក្រុម ដែលបច្ចុប្បន្ននេះជាក្រុមកសិករគ្រប់គ្រងដោយសមាជិករបស់ពួកគេតាមលក្ខណៈប្រជាធិបតេយ្យ។ ក្រុម សន្សំសំចៃនេះ ទាមទារឱ្យមានការកែលំអដើម្បីក្លាយជាគ្រឹះនៃសហករកិសកម្មដំបូង ដែលនិងមានទំនាក់ទំនង ជាមួយ ១) ការជាវសំភារៈកសិកម្មរួមគ្នា ដូចជា ជី ថ្នាំសំលាប់សត្វល្អិត និងឧបករណ៏កសិកម្ម ២) ការប្រមូលទិញ និងលក់ផលិតផលកសិកម្ម និង ៣) ការសន្សំប្រាក់ និងឥណទាននៅពេលអនាគត។ សកម្មភាពទាំងឡាយដែលបាន ស្នើ សំរាប់ធ្វើឱ្យប្រសើរឡើងនូវក្រុមសន្សំប្រាក់បច្ចុប្បន្នរួមមានៈ ១) ការពិនិត្យឡើងវិញ និងបញ្ជាក់ឱ្យបានច្បាស់ លាស់នូវនិតិវិធីដែលមានស្រាប់ ២) រក្សា និងធ្វើឱ្យប្រសើរឡើងនូវតម្លាភាពហិរញ្ញវត្ថុ ៣) បង្កើនមូលនិធិដើមទុន និង៤) ការរៀបចំសំរាប់ការអភិវឌ្ឍន៏ឱ្យទៅជាសហករកសិកម្មដំបូង។

## (២៨) ការពិចារណាអំពីបរិស្ថាន (គ.២.៦)

ក្នុងដំណើការនៃការរៀបចំផែនការកែលំអផ្សេងៗ ការពិចារណាទៅលើបរិស្ថានមួយចំនួន ត្រូវបានពិនិត្យតាមដានដើម្បីអនុវត្តគំរោងឱ្យមាននិរន្តរភាព និងបរិស្ថានល្អ។ ចំណុចសំខាន់ៗនៃបរិស្ថាននៅក្នុងគំរោងរួមមានៈ ១) ទីកដែលអាចប្រើប្រាស់បានសំរាប់កសិកម្មក្នុងអំឡុងពេលនៃដំណាក់ការសាងសង់ ២) វិធីសាស្ត្រក្នុងការសាងសង់ប្រលាយបេតុងត្រង់កន្លែង ដែលហូរច្រោះ និងដីងាយរលាយដោយសារទឹក និង ៣) ការហុយដីដោយការប្រើគ្រឿងចក្រក្នុងពេលសាងសង់។

## (២៩) ផែនការប្រតិបត្តិ (គ.២.៧)

ការងារគំរោងរួមមាន ១) ការបង្កើតការិយាល័យគំរោង ២) ការរៀបចំការបរិចាគដីសំរាប់សាងសង់ ៣) សេវាកម្ម វិស្វកម្ម ៤) ការធ្វើលទ្ធកម្ម ៥) ការសាងសង់ ៦) ការសាងសង់ប្រលាយជើងក្អែបដោយកសិករ ៧) សេវាកម្មទ្រទ្រង់កសិកម្ម ៨) ការបង្កើត និងពង្រឹងសហគមន៏កសិករប្រើប្រាស់ទឹក ៩) ការរៀបចំអភិវឌ្ឍន៏ក្រុមកសិករ ១០) ការពង្រឹងមន្ទីរធនធាន ទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ១១) ពង្រឹងការសំរបសំរួលរវាងមន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម និង១២) ការពិនិត្យតាមដានបរិស្ថាន។ ការអនុវត្តន៏គំរោងនឹងប្រើប្រាស់រយៈពេល ៣៩ ខែ ដោយពុំរាប់បញ្ចូលការតាមដាន បរិស្ថាន មានរយៈពេល ២០ឆ្នាំ។ កាលវិភាគប្រតិបត្តិសំរាប់ការងាររបស់គំរោងមានបង្ហាញជូនខាងក្រោមៈ

**កាលវិភាគសំរាប់ការងារប្រតិបត្តិគំរោង**




ក្រសួងធនធានទឹក និងឧតុនិយម ជាភ្នាក់ងារប្រតិបត្តិគំរោងទាំងមូល។ គោលបំណងរបស់គំរោង គឺដើម្បីបង្ហាញពីការគ្រប់គ្រងទឹកឱ្យបានសមស្រប និងបង្កើនផលិតផលស្រូវ តាមរយៈធ្វើសុខដុមរនីយកម្មលើការអភិវឌ្ឍន៍កសិកម្ម, ការ ស្រោចស្រព, ការដោះទឹក និងស្ថាប័ននានា។ មានន័យថា ការសំរបសំរួលយ៉ាងជិតស្និទ្ធរវាងមន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម គឺជាកាចាំបាច់បំផុត។ ជាងនេះទៀត គំរោងនឹងត្រូវបានអនុវត្តដោយមានការចូលរួមចាប់ពីដំណាក់កាលដំបូង។ ដោយយោលទៅលើការយកចិត្តទុកដាក់ខាងលើ សំណើរស្តីពីការបង្កើតឱ្យមានការិយាល័យគំរោងមួយត្រូវបានស្នើឡើង ស្ថិត នៅក្រោមរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ដោយផ្ទាល់។ សំណើស្តីពីការរៀបចំការិយាល័យគំរោងត្រូវបាន ផ្តល់ជូនដូចខាងក្រោម:

**ការរៀបចំគំរោងដែលបានស្នើ**




## (៣០) ការពិនិត្យតាមដានលើបរិស្ថាន (គ_២.៨)

ការពិនិត្យតាមដានលើបរិស្ថានដំបូងនៃគំរោងត្រូវបានសន្និដ្ឋានដូចខាងក្រោម:

- ជាទូទៅ ផែនការអភិវឌ្ឍន៍គំរោង ត្រូវបានវិនិច្ឆ័យថា អាចទទួលយកបានដោយផ្តើមពីទស្សនៈបរិស្ថាន ប្រសិនបើវិធានការកាត់បន្ថយសមស្របដែលបានបង្ហាញពេលមុនត្រូវបានយកមកអនុវត្ត។

- ផលប៉ះពាល់ដែលទំនងជាកើតឡើងមួយចំនួនទាំងលើបរិស្ថានសង្គម និងធម្មជាតិ ត្រូវបានបង្ហាញ ដូចជា ទឹកមានកំណត់នៅក្នុងអំឡុងពេលសាងសង់ និងការធ្វើអោយខូចខាតគុណភាពទឹកបន្ទាប់ពីកិច្ច ប្រតិបត្តិការបានចាប់ផ្តើម។ ដូច្នេះ ការគ្រប់គ្រងដ៏សមស្របស្របគ្នា និងការដាក់ចេញនូវវិធានការ កាត់បន្ថយ និងផែនការពិនិត្យតាមដាន /គ្រប់គ្រង ត្រូវបានអនុវត្ត ដើម្បីជៀសវាង/កាត់បន្ថយនូវផល អវិជ្ជមានដែលនឹងកើតមានឡើង។
- ដោយពិចារណាលើភាពប្រែប្រួលយ៉ាងខ្លាំងរបស់កសិករចំពោះប្រធានបទ ដំណើរការនៃការបរិចាគដី ត្រូវអនុវត្តដោយប្រុងប្រយ័ត្នជាទីបំផុត ជាមួយនឹងការគ្រប់គ្រង និងប្រតិបត្តិឱ្យបានសមស្របនូវ សំណើរផែការគ្រប់គ្រង និងវិធានការណ៍កាត់បន្ថយ។

## (៣១) ការប៉ាន់ស្មានតំលៃ (គ-២.៩)

តំលៃវិនិយោគសរុបត្រូវបានប៉ាន់ប្រមាណ ២,៤៧៩,000 US$ ដែលស្មើនឹង ១០,០៦៤,៧៤០,000 រៀល។ តំលៃ សំរាប់ជួរទ្វារទឹករួមនឹងគ្រឿងបន្លាស់ផ្សេងទៀតត្រូវបានប៉ាន់ប្រមាណ ១៨៧,000 US$ ស្មើនឹង ៧៥៩,២២០,000 រៀល ដែលអាចនឹងកើតមានឡើងនៅឆ្នាំទី ២៥ បន្ទាប់ពីការងារជួសជុលបានចប់សព្វគ្រប់។ តំលៃសំរាប់ការប្រតិបត្តិ និងថែទាំ ត្រូវបានប៉ាន់ប្រមាណ ៥, ៩00 US$ ស្មើនឹង ២៣, ៩៥៤, 000 រៀល ។ លើសពីនេះទៀត តំលៃពិនិត្យតាមដានលើ បរិស្ថានបន្ទាប់ពីការងារសាងសង់បានបញ្ចប់ នឹងបន្តរយៈពេល ២០ ឆ្នាំ ទៀត ហើយតំលៃប្រចាំឆ្នាំត្រូវបានប៉ាន់ប្រមាណ ៦៤៨ US$ ស្មើនឹង ២,៦៣០,៨៨០ រៀល។

## (៣២) ការវាយតំលៃគំរោង (គ-២.១០)

EIRR របស់គំរោងត្រូវបានប៉ាន់ប្រមាណប្រហែល ១១,១ %។ ផលសងរវាងអត្ថប្រយោជន៏ និងតំលៃ (B-C) និង ផលចែករវាងអត្ថប្រយោជន៏ និងតំលៃ (B/C) នៅក៏រិត ៧% នៃអត្រាបញ្ចុះតំលៃ ត្រូវបានប៉ាន់ប្រមាណប្រហែល ២,៩៦៩ លានរៀលសំរាប់ B-C និង ១,៥ លានរៀលសំរាប់ B/C ។ ការវិនិច្ឆ័យដោយផ្តើមចេញពីសន្ទស្សន៍សេដ្ឋកិច្ចទាំងនេះ អាចបញ្ជាក់ថាគំរោងនេះមានលក្ខណៈសេដ្ឋកិច្ចល្អ។ គំរោងថែមទាំងបានបង្ហាញពីការកើនឡើងនូវទិន្នផលស្រូវពី ១,៨២១ តោន ទៅ ៣,១០៧ តោន ដែលអាចនិយាយបានថាកើនឡើង ៧0 %។

ការវិភាគលើថវិកាកសិដ្ឋានត្រូវបានធ្វើសំរាប់ប្រភេទកសិដ្ឋាន (ប្រភេទ ក: កសិដ្ឋានមានការដាំដុះដំណាំស្រូវពីរដង និងប្រភេទ ខ: សំរាប់កសិដ្ឋានដែលមានការដាំដុះដំណាំស្រូវតែម្តង) ដែលស្ថានភាពបច្ចុប្បន្នពុំទាន់មានគំរោង និងពេល អនាគតមានគំរោង។ ក្រោមលក្ខខណ្ឌ័មានគំរោង ចំណូលសរុបជាមធ្យមនៃគ្រួសារកសិករអាចនឹងកើនឡើង ៨៧% សំរាប់ ប្រភេទ ក និង ៨៩ % សំរាប់គ្រួសារកសិករប្រភេទ ខ ហើយប្រាក់ចំណូលពិតប្រចាំឆ្នាំជាមធ្យមមាន ៤៦៩,000 រៀល សំរាប់ប្រភេទ ក និង ៤៤៨,000 រៀល សំរាប់គ្រួសារកសិករប្រភេទ ខ។ លទ្ធភាពរបស់កសិករក្នុងការចំណាយត្រូវបាន វាយតំលៃជាផលធៀបនៃសេវាកម្មថ្លៃទឹកស្រោចស្រព (ISF) ទៅនឹងកំណើនចំណូលពិតប្រចាំឆ្នាំជាមួយលក្ខខ័ណ្ឌមានគំរោង។ សេវាកម្មថ្លៃទឹកស្រោចស្រព (ISF) ជាមធ្យមត្រូវបានគេប៉ាន់ប្រមាណ ៤៧,៤00 រៀល/ឆ្នាំ/គ្រួសារ សំរាប់ប្រភេទ ក និង ១៥,៣00 រៀល/ឆ្នាំ/គ្រួសារសំរាប់កសិដ្ឋានប្រភេទ ខ។ តំលៃរួមទាំងនេះតិចជាង ១១% នៃកំណើនចំណូលពិតប្រចាំឆ្នាំ សំរាប់ប្រភេទ ក និងតិចជាង ៤ % នៃគ្រួសារកសិករប្រភេទ ខ។ តួលេខទាំងនេះ បង្ហាញថា កសិករ ស្ទើរតែទាំងអស់អាចមានលទ្ធភាពបង់ថ្លៃសេវាកម្មទឹកសំរាប់ស្រោចស្រព។

គំរោងក៏ចូលរួមយ៉ាងខ្លាំងផងដែរលើទិដ្ឋភាពសេដ្ឋកិច្ច-សង្គមជាច្រើន ដូចជា ១) ការធ្វើឱ្យប្រសើរឡើងនូវចំណូល របស់កសិករ និងមនុស្សមួយចំនួនទៀត និងផ្តល់ឳកាសមានការងារធ្វើ ២) ការទ្រទ្រង់ខ្លួនឯងលើដំណាំខ្ពង់រាប និងបន្លែ ក្នុងតំបន់គំរោង ៣) កែលំអសេដ្ឋកិច្ចក្នុងតំបន់ ៤) ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកដែលពាក់ព័ន្ធ និង ៥) ការជះឥទ្ធិពល ពីគំរូអភិវឌ្ឍន៍ទៅតំបន់ជិតខាង និងទៅតំបន់ផ្សេងៗទៀត។

## (៣៣) ការពិនិត្យតាមដានសំរាប់ប្រសិទ្ធភាពគំរោង (គ-២.១១)

នេះគឺជាគំរោងគំរូសំរាប់បង្ហាញពីការគ្រប់គ្រងទឹកឱ្យបានត្រឹមត្រូវ និងបង្កីនផលិតផលស្រូវដោយសុខដុម្យនីយ៏កម្ម ទុនចូលលើផ្នែកកសិកម្ម, ការស្រោចស្រព, ការដោះទឹក និងការអភិវឌ្ឍន៏ស្ថាប័ន។ ក្នុងពេលបញ្ចប់សំណង់នានានៃគំរោង សេវាកម្មគាំទ្រនឹងត្រូវអនុវត្តផងដែរដើម្បីធានានូវប្រសិទ្ធភាពគំរោង។ ក្នុងន័យនេះ គំរូវឱ្យមានសកម្មភាពតាមដានសំរាប់ គំរោង

ដែលនឹងត្រូវប្រតិបត្តិដោយការិយាល័យគំរោង។ រយៈពេលពិនិត្យតាមដាន មានរយៈពេល ៤ ឆ្នាំ ចាប់តាំងពី គំរោងបានរួចរាល់សព្វគ្រប់។ សន្ទស្សន៍ដែលត្រូវបានដាក់ស្នើសំរាប់ការពិនិត្យតាមដានមានដូចខាងក្រោមៈ

- កសិកម្ម : ទិន្នផលដំណាំ និងសក្តានុពលនៃដំណាំ
- ការស្រោចស្រព : ធារទឹកដែលបានវាស់នៅដើមប្រលាយថ្នាក់ទី២
- ស្ថាប័ន : អត្រាប្រមូលសេវាកម្មថ្លៃទឹកស្រោចស្រព

## (៣៤) សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ (គ-២.១២)

យោងតាមលទ្ធផលនៃការសិក្សាសមិទ្ធិ គំរោងនេះ មានលក្ខណៈបច្ចេកទេសល្អ និងលក្ខណៈសេដ្ឋកិច្ចអាចទទួល យកបាន។ ផ្តើមពីទិដ្ឋភាពបរិស្ថានធម្មជាតិ និងសង្គម ព្រមទាំងទិដ្ឋភាពនៃការរៀបចំ និងស្ថាប័ន គំរោងនេះបង្ហាញថា មានលក្ខណៈល្អប្រសើរ។ ការប្រតិបត្តិនៃគំរោងអាចសំរេចបានគោលដៅជាគោលការណ៍នៃការបង្ហាញការគ្រប់គ្រងទឹក អោយបានសមស្រប និងបង្កើនផលិតផលស្រូវក្រោមការអភិវឌ្ឍន៍សុខុដុមរម្យនៃកសិកម្ម, ការស្រោចស្រព, ការដោះទឹក និង ស្ថាប័នដទៃទៀត។ ជារួម គំរោងនេះត្រូវប្រតិបត្តិឱ្យបានទាន់ពេលវេលាដូចមានក្នុងផែនការនៃការសិក្សានេះ។

ទាក់ទងជាមួយការប្រតិបត្តិគំរោង បញ្ហាមួយចំនួនដែលអាចផ្តល់ជាអនុសាសន៍មាន ១) ការប្រតិបត្តិគំរោងជាបន្ទាន់ ២) តំរូវឱ្យបង្កើតការិយាល័យគំរោងឱ្យបានទាន់ពេលវេលា ៣) តំរូវឱ្យមានការរៀបចំថវិកាសំរាប់សេវាកម្មគាំទ្រ និង ៤) តំរូវឱ្យមានការពិនិត្យតាមដានលើបរិស្ថាន។

## ក្បាលទី ៤:     គម្រោងសាកល្បង

### ផ្នែក ក: ព័ត៌មានទូទៅ

### (១) ប្រវត្តិសង្ខេប: (ក-២)

គម្រោងសាកល្បងចំនួន 04 កន្លែង នៅក្នុងផែនការមេនៃគម្រោងអភិវឌ្ឍន៍វិសាលភាពកសិកម្ម ក្នុងអាងស្ទឹងព្រែកត្នោត ត្រូវបានជ្រើសរើសសម្រាប់យកមកអនុវត្ត។ គម្រោងអាទិភាពចំនួន 02 ក្នុង ចំណោមគម្រោងចំនួន 04 កន្លែង ត្រូវបានអនុវត្តនៅក្នុង 03 តំបន់ ដែលបានជ្រើសរើសដោយផ្អែក លើទស្សនៈនៃសារៈសំខាន់នៅក្នុងផែនការមេ ភាពបន្ទាន់ និងការលើកទឹកចិត្តរបស់កសិករ។

- គម្រោងសាកល្បងស្តីពីការកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្មលើការដាំដុះស្រូវ( ក្នុងតំបន់ ១ និងក្នុងតំបន់ ៣) ។
- គម្រោងសាកល្បងស្តីពីការកែលំអកសិកម្មរំពឹងទឹកភ្លៀង ( ក្នុងតំបន់ ៤)

### (២) គោលបំណង និងផ្លូវឆ្ពោះនៃគម្រោងសាកល្បង (ក-២.២.២, ក-៣.១)

គោលបំណងនៃគម្រោងសាកល្បង គឺការបង្កើតគម្រោងគំរូដ៏ល្អនៃការកែលំអដោយបញ្ចូលចម្លើយ របស់កសិករចំពោះសកម្មភាពកែលំអដែលបានស្នើឡើងនៅក្នុងផែនការមេ និងចូលរួមធ្វើឱ្យប្រសើរឡើងនូវផែនការមេ។ "គម្រោងគំរូដ៏ល្អនៃការកែលំអ" មានន័យថា គម្រោងគំរូអាចបង្ហាញពីប្រសិទ្ធភាពនៃដំណើរការកែលំអដែលបានស្នើឡើងដើម្បីសម្រេចបានគោលដៅនៃផែនការមេ។




**សំណើដំណើរការកែលំអពីរដំណាក់កាល ជាមួយនឹងសកម្មភាពបីប្រភេទ**

ដំណើរការកែលំអពីរជំហានដែលបានស្នើឡើងសម្រាប់សកម្មភាពបីប្រភេទ ត្រូវបានបង្ហាញដូចខាង ក្រោម: គេសង្ឃឹមថា កសិករនឹងកែលំអល័ក្ខខណ្ឌហិរញ្ញវត្ថុតាមការកែលំអមួយជំហានដោយគ្មានការវិនិយោគបន្ថែម។ បន្ទាប់មក កសិករនឹងបន្តឈានចូលជំហានទី ២ និងអនុវត្តនូវការដាំដុះប្រកបដោយការកែលំអខ្ពស់ ជាមួយ និងចំនួនទុនចូលសមស្របក្នុងពេលអនាគត។

### (៣) យុទ្ធសាស្ត្រមូលដ្ឋានសម្រាប់អនុវត្ត (ក-៤.២)

យុទ្ធសាស្ត្រមូលដ្ឋានចំនួន 05 សម្រាប់អនុវត្តត្រូវបានស្នើឡើង:

| | |
|---|---|
| យុទ្ធសាស្ត្រទី ១ | សិក្សាតាមកសិករមានស្នាដៃល្អក្នុងការដាំដុះនៅកម្ពុជា |
| យុទ្ធសាស្ត្រទី ២ | ការប្រតិបត្តគម្រោងដោយកិច្ចសហការរួមគ្នារវាងក្រុមកសិករ រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល |
| យុទ្ធសាស្ត្រទី ៣ | ភ្នាក់ងាររដ្ឋាភិបាលសហការជាមួយសកម្មភាពទាក់ទងនិងធារាសាស្ត្រកសិកម្ម |
| យុទ្ធសាស្ត្រទី ៤ | កាត់បន្ថយឱ្យបានអតិបរមានូវទុនចូលជាសំភារៈ និងឧបករណ៍ពីកសិករ |
| យុទ្ធសាស្ត្រទី ៥ | ណែនាំការផ្សព្វផ្សាយពីកសិករទៅកសិករ |

### (៤) ការរៀបចំស្ថាប័ន (ក-៥)

កុមការងារគម្រោងសាកល្បង ដែលចាត់ទុកថាជាក្រុមផ្តល់យោបល់ និងក្រុមអនុវត្តគម្រោង ដូច មានបង្ហាញនៅក្នុងរូបខាងស្តាំត្រូវបានបង្កើតឡើងសម្រាប់ការអនុត្តគម្រោងសាកល្បង




**ការបង្កើតស្ថាប័នអនុវត្តគំរោងគំរូ**

ក្រុមអនុត្តគម្រោងត្រូវបានបង្កើតឡើង សម្រាប់គម្រោងកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្មលើការដាំដុះ ស្រូវ និងគម្រោងកែលំអកសិកម្មរំពឹងទឹកភ្លៀង។

### (៥) ប្រតិកម្មរបស់សិក្ខាសាលា (ក-៦)

សិក្ខាសាលាបង្ហាញពីលទ្ធផលសកម្មភាពរបស់គម្រោងសាកល្បងត្រូវបានរៀបចំឡើងនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ក្នុងខេត្តកំពង់ស្ពឺ។ សិក្ខាកាមចូលរួមមាន: មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចំនួន ០៣ រូប, មន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម ចំនួន ០៣ រូប, មន្ត្រីមន្ទីរកសិកម្ម ចំនួន ០៧ រូម, មន្ត្រីអង្គការ CEDAC ចំនួន ០២ រូប និងកសិករចំនួន ២០ រូប។ បន្ទាប់ពីការពន្យល់ស្តីពីប្រវត្តសង្ខេបនៃការសិក្សា តំណាងមន្ទីរធនធានទឹក និងឧតុនិយម, មន្ទីរកសិកម្ម និងអង្គការ CEDAC បានពន្យល់អំពីសកម្មភាព គម្រោងសាកល្បង។ យោងតាមលទ្ធផលនៃការពិភាក្សាតាមក្រុមស្តីពីបញ្ហាជុំវិញ, បញ្ហាដែលបានសិក្សា និង សកម្មភាពសម្រាប់អនាគត បង្ហាញថាកសិករស្ទើរតែទាំងអស់មានបំណងបន្តសកម្មភាពការងាររបស់គម្រោង សាកល្បងដែលបានស្នើឡើង។

## <u>ផ្នែក ខ: គម្រោងសាកល្បង (២០០៦/២០០៧)</u>

### គម្រោងទី ១: គម្រោងសាកល្បងកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្មលើការដាំដុះស្រូវ(តំបន់១)

### ជំពូក ១១-១: ក្របខ័ណ្ឌនៃគម្រោង

### (១) គោលបំណង (១១-១.១) និងសកម្មភាព (១១-១.២.១)

គោលបំណងនៃគម្រោងសាកល្បងគឺការបង្កើតឡើងនូវគំរូដ៏ល្អមួយនៃការកែលំអធារាសាស្ត្រកសិកម្មលើការដាំដុះស្រូវក្នុងតំបន់ ១។ សកម្មភាពបីប្រភេទត្រូវបានអនុវត្តដូចជា ១) ការគ្រប់គ្រងការស្រោចស្រពដោយ មានការចូលរួម និងកិច្ចអភិវឌ្ឍន៍, ២) ការផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម, ៣) ការកែលំអការដាំដុះ តាមរយៈការពិសោធន៍។

### ជំពូក ១១-២: សកម្មភាពការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍

### (២) គោលបំណង (១១-២.១) និងផ្ទៃដី (១១-២.៣.១)

គោលបំណងនៃសកម្មភាពការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ គឺដើម្បីសម្រេចបាននូវការប្រើប្រាស់ទឹកស្រោចស្រពប្រកបដោយប្រសិទ្ធភាពដោយផ្អែកលើផែនការសេវាស្រោចស្រព។ ផ្ទៃដីនៅប្រឡាយថ្នាក់ទី ៣ (RT-2) ត្រូវបានជ្រើសរើសជាតំបន់សកម្មភាព។

## (៣) ស្ថានភាពមុនពេលអនុវត្តគម្រោងសាកល្បង (១១.២.៣)

មានសំណង់បញ្ចូលទឹកក្នុងស្រែមួយចំនួនបំពាក់ដោយសន្ទះទ្វារទឹកនៅក្បាលប្រឡាយថ្នាក់ទី ៣ (RT-2) ក៏ប៉ុន្តែពុំមានសំណង់សម្រាប់នាំទឹកទៅដល់តំបន់ស្រោចស្រពឡើយ។ តំបន់ស្រោចស្រពនេះ គ្រប់គ្រងដោយ **ស.ក.ប.ទ** អូរវែង។ **ស.ក.ប.ទ** ដំណើរការពុំបានល្អឡើយដោយការយល់ដឹងស្ដីពីសារៈសំខាន់នៃការគ្រប់គ្រង ការស្រោចស្រពនៅមានកំរិតទាប, ខ្វះព័តិមានមូលដ្ឋាន និងសមត្ថភាពដឹកនាំនៅមានកំរិត ។ល។

## (៣) សកម្មភាពអនុវត្តសម្រាប់ការកែលំអ (១១.២.៥)

ថ្នាក់ដឹកនាំរបស់ **ស.ក.ប.ទ** អូរវែង បានធ្វើទស្សនៈកិច្ចសិក្សានៅ **ស.ក.ប.ទ** អូរទ្រាំង។ ថ្នាក់ដឹកនាំទាំងពីរក្រុម បានវិភាគនូវស្ថានភាពក្នុងតំបន់របស់ខ្លួន ហើយបានរៀបចំផែនការកែលំអជាមួយគ្នាដោយ មានការចូលរួមពីមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម។ ផែនការកែលំអរួមមានសកម្មភាពចំនួន ១១។ ក្នុង ចំណោមសកម្មភាពទាំង ១១ សកម្មភាពចំនួន ៣ ត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០០៦/០៧ និងសកម្មភាពចំនួន ៨ ត្រូវបានយកមកអនុវត្តដូចខាងក្រោម៖

| សកម្មភាពបានអនុវត្ត | លទ្ធផល |
|---|---|
| (ក) អនុវត្តការរៀបចំផែនទីកាន់កាប់ដីដំបូង | ផែនទីកាន់កាប់ដីរបស់ប្រឡាយថ្នាក់ទី ៣ (RT-2) ប្រមាណ ៦៣ ហិកតា ត្រូវបានរៀបចំដោយប្រើប្រាស់ឧបករណ៍ GPS និងកម្មវិធីប្រព័ន្ធព័តិមាន ភូមិសាស្ត្រ ជាមួយនិងថ្នាក់ដឹកនាំរបស់ **ស.ក.ប.ទ** ក្នុងតម្លៃទាប និងរហ័ស។ |
| (ខ) អនុវត្តការរៀបចំផែនទីប្រើប្រាស់ទឹក | ស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ទឹកត្រូវបានធ្វើអង្កេត និងដៅនៅលើផែនទី។ លទ្ធផលបានបង្ហាញថា អ្នកភូមិនៅខ្សែទឹកខាងលើស្ទើរតែទាំងអស់មិនបានបង់ថ្លៃសេវាផ្គត់ទឹក និងមានគ្រួសារមួយចំនួនដែលមិនបានធ្វើស្រែពេញលេញ។ |
| (គ) អនុវត្តការកាត់បន្ថយ និងការកំណត់ការបាត់បង់ទឹក | ធារទឹកនៅក្នុងប្រឡាយត្រូវបានវាស់ដោយមន្ទីរធនធានទឹក និងឧតុនិយម ហើយបានរកឃើញនូវការបាត់បង់ទឹកនៅចំណុចសំណង់បង្ហៀរ។ សន្ទះទ្វារទឹកត្រូវបានបំពាក់នៅលើសំណងបង្ហៀរដើម្បី ការពារការបាត់បង់ទឹក។ |
| (ឃ) អនុវត្តការបង្កើតអនុក្រុម **ស.ក.ប.ទ** | អនុក្រុម **ស.ក.ប.ទ** ត្រូវបានរៀបចំនៅក្នុងចំនួន ៥ ហើយ ថ្នាក់ដឹកនាំ **ស.ក.ប.ទ** ក៏ត្រូវបានជ្រើសរើស។ |
| (ង) អនុវត្តការអប់រំការប្រើប្រាស់ទឹកឱ្យបានត្រឹមត្រូវ | សារៈសំខាន់នៃសកម្មភាពរបស់ **ស.ក.ប.ទ** ត្រូវបានពន្យល់នៅ ក្នុងអង្គប្រជុំភូមិ និងទស្សនាវត្តី **ស.ក.ប.ទ** ត្រូវបានបោះពុម្ព ដើម្បីផ្សព្វផ្សាយសកម្មភាពរបស់ **ស.ក.ប.ទ** ហើយការងារនេះត្រូវបានអនុវត្តដោយក្រុមអនុវត្តគម្រោងសាកល្បង។ |
| (ច) អនុវត្តការកែលំអរដ្ឋបាល **ស.ក.ប.ទ** | វគ្គបណ្ដុះបណ្ដាលជាច្រើនវគ្គ ត្រូវបានរៀបចំសម្រាប់ថ្នាក់ដឹកនាំ **ស.ក.ប.ទ** ដោយមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម។ |
| (ឆ) អនុវត្តការរៀបចំផែនការសេវាស្រោចស្រព | អាត្រាជ្រាបនៅក្នុងតំបន់គម្រោងត្រូវបានវាស់ដោយមន្ទីរធនធានទឹក និងឧតុនិយម សម្រាប់រៀបចំផែនការបែងចែកទឹក។ |
| (ជ) អនុវត្តការសាងសង់សំណង់ស្រោចស្រពខ្នាតតូច | បន្ទាប់ពីទទួលបានការឯកភាពពី **ស.ក.ប.ទ** សំណង់បែងចែកទឹក ចំនួន ០៦ កន្លែង, សំណង់ស្ទាក់ទឹក ចំនួន ០២ កន្លែង និងសំណងដោះទឹក ចំនួន ០១ កន្លែង ត្រូវបានសាងសង់។ |

## ជំពូក ១១.៣៖ សកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

## (៥) គោលបំណង (១១.៣.១) និងផ្ទៃដី (១១.៣.៣.១)

គោលបំណងនៃសកម្មភាពផ្សព្វផ្សាយកសិកម្ម ដោយមានការចូលរួមគឺដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ដែលមានតម្លៃទាបដែលទទួលនូវលទ្ធផលគួរជាទីពេញចិត្ត នៅក្នុងតំបន់ស្រោចស្រពដោយប្រព័ន្ធធារាសាស្រ្ត និងតំបន់រំពឹងទឹកភ្លៀងក្នុងប្រទេសកម្ពុជា។ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ដែលចំណាយ ទុនតិចមានប្រមាណ ០៣ ចំណុចដែលទទួលការពេញចិត្តក្នុងចំណោម ១២ ចំណុច។ ភូមិរំលៀង ស្ថិតនៅខ្សែទឹកខាងក្រោមនៃប្រឡាយថ្នាក់ទី ៣ (RT-2) ត្រូវបានជ្រើសរើសជាតំបន់សកម្មភាព នៃគម្រោង។

<u>គោលការណ៍ ១២ ចំណុចរបស់ ប.វ.ស ដែលប្រើប្រាស់កត្តាផលិតកម្មទាប</u>

1- ពង្រាបដីស្រែ និងរៀបចំប្រឡាយដោះទឹក
2- ជ្រើសរើសពូជសុទ្ធ និងណែនល្អសម្រាប់សាប
3- លើកថ្នាលសំណាប និងប្រើថ្នាលស្ងួត
4- រើសដើមធំ និងស្ទូងភ្លាម
5- ស្ទូងសំណាបក្មេង (សំណាបតិចជាង 15 ថ្ងៃ)
6- ស្ទូង ១ដើម ក្នុងមួយកន្លែង
7- ស្ទូងសំណាបកន្លែងរាក់ និងរក្សាឬសឱ្យផ្តេក
8- ស្ទូងសំណាបជាជួរ
9- ស្ទូងសំណាបឃ្លាតពីគ្នា 25-40 ស.ម
10- ដកស្មៅយ៉ាងហោចណាស់ 2-4 ដងក្នុងរដូវ
11- រក្សាទឹកក្នុងស្រែឱ្យរាក់ល្មម
12- ប្រើជីធម្មជាតិឱ្យបានច្រើន

## (៦) ស្ថានភាពមុនពេលចាប់ផ្តើមគម្រោងសាកល្បង (១១.៣.៣)

ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) មិនទាន់អនុវត្តនៅក្នុងភូមិរំលៀង ហើយក៏មិនទាន់មានក្រុម កសិករទ្រទ្រង់ខ្លួនឯងផងដែរ។

## (៧) សកម្មភាពអនុវត្តសម្រាប់ការកែលំអ (១១.៣.៥)

### (ក) ផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មស្រូវដែលទុនចូលទាបពីកសិករទៅកសិករ

នៅក្នុងការដឹកនាំដំបូង កសិករត្រូវបានជំរុញឱ្យអនុវត្តប្រព័ន្ធប្រពលវប្បកម្មស្រូវដែលទុនចូលទាប ដោយមានការណែនាំដូចជា ១) ចែកដីស្រែជាពីរ ផ្នែក ដើម្បីប្រៀបធៀបការដាំបែបប្រព័ន្ធប្រពល វប្បកម្មស្រូវ និងការដាំដុះបែបបូរាណ, ២) ទុកដីស្រែមួយផ្នែកសម្រាប់ការដាំបែបប្រព័ន្ធប្រពលវប្បកម្ម ស្រូវ និង ៣) ចាប់ផ្តើមការដាំបែបប្រព័ន្ធប្រពលវប្បកម្មស្រូវដែលទុនចូលទាប ដោយពុំចាំបាច់ប្រើប្រាស់ជី និងពូជថ្មី។ បន្ថែមលើនេះ ការប្រើប្រាស់ជីធម្មជាតិជំនួសឱ្យជីគីមីត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យប្រើប្រាស់។

លទ្ធផលទទួលបាន គឺកសិករចំនួន ០៤ រូប ស្ម័គ្រចិត្តធ្វើជាកសិករពិសោធន៍ និងចូលរួមការត្រួត ពិនិត្យសកម្មភាព។ ការងារផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មស្រូវដែលបានបញ្ចប់មានដូចខាងក្រោម:

- ទស្សនៈកិច្ចសិក្សានៅខេត្តកំពង់ចាមដើម្បីសិក្សាអំពីការដាំបែបប្រព័ន្ធប្រពលវប្បកម្មស្រូវ
- ការបណ្តុះបណ្តាលតាមភូមិ
- ការបណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយកសិករ ដែល ស្ម័គ្រចិត្តធ្វើពិសោធន៍នៅក្នុង ០៣ តំបន់ (តំបន់ ១, តំបន់ ២ និងតំបន់ ៤)
- ទិវាវាលស្រែកសិករដើម្បីបង្ហាញការដាំបែបប្រព័ន្ធប្រពលវប្បកម្មស្រូវដល់អ្នកភូមិ

### (ខ) ផ្សព្វផ្សាយការចិញ្ចឹមមាន់ពីកសិករមួយទៅកសិករ

ដោយពិនិត្យលើចំណាប់អារម្មណ៍របស់កសិករ ការចិញ្ចឹមមាន់បែបបរិស្ថាន ត្រូវបានជ្រើសរើស ជាសកម្មភាពនៅក្នុងរដូវប្រាំង ហើយវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ត្រូវបានបង្ហាញ។

- ទស្សនៈកិច្ចសិក្សានៅខេត្តកំពង់ចាមដើមីសិក្សាអំពីការចិញ្ចឹមមាន់
- បណ្តុះបណ្តាលតាមភូមិ

### (គ) ពង្រឹងក្រុមកសិករ

ក្រុមកសិករសកម្ម មានសារៈសំខាន់ណាស់សម្រាប់ការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ ទៀត។ ដូចនេះ ក្រុមកសិករត្រូវបានបង្កើតឡើង និងពង្រឹងតាមរបៀបដូចខាងក្រោមៈ

- ទស្សនៈកិច្ចសិក្សា (សិក្ខាកាមបានពិភាក្សាផងដែរអំពីក្រុមកសិករក្នុងដំណើរទស្សនៈកិច្ចសិក្សា សម្រាប់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ និងការចិញ្ចឹមមាន។)
- ការបណ្តុះបណ្តាលតាមភូមិ

## ជំពូក ២១.៤: សកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍

### (៨) គោលបំណង (២១.៤.១)

គោលបំណងនៃសកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍ គឺដើម្បីផ្ទៀងផ្ទាត់ទិន្នផល គ្រោងដែលបានប៉ាន់ស្មាននៅក្នុងផែនការមេ ត្រូវបានសម្រេចដោយការអនុវត្ត SRI ផ្អែកលើការអនុវត្ត ការ ដាំដុះដោយមានការកែលំអ និងសាកល្បងកែតម្រូវការអនុវត្តសម្រាប់ការកែលំអបន្ថែម។

### (៩) សកម្មភាពមុនពេលចាប់ផ្តើមសកម្មភាពគម្រោងសាកល្បង (២១.៤.៣)

លក្ខខ័ណ្ឌកសិកម្មមុនពេលចាប់ផ្តើមគម្រោងសាកល្បងមានដូចខាងក្រោមៈ

| | |
|---|---|
| សំណាប | ពូជក្នុងស្រុកត្រូវបានប្រើប្រាស់ និងពុំសូវមានការផ្លាស់ប្តូរពូជដែលមានគុណ ភាពល្អ |
| ការស្ទូង | ការស្ទូងចម្រុះត្រូវបានអនុវត្ត |
| ការប្រើជីគី | ជី Manure (១.៧ តោន/ហិកតា) និងជី DAP(៥៨ គក្រ) និងជីអ៊ុយរ៉េ (៧០ គក្រ) |
| ទិន្នផលស្រូវ | ស្រូវបង្កើនរដូវ: ២.៤ តោន/ហិកតា និងស្រូវវស្សា : ២.៣០ តោន/ហិកតា |

### (១០) សាកល្បងផ្ទៀងផ្ទាត់ (២១.៤.៨)

ទិន្នផលស្រែសាកល្បងផ្ទៀងផ្ទាត់ចំនួន ០៦ កន្លែង ត្រូវបានប្រៀបធៀបជាមួយនិងទិន្នផលគ្រោងនៅ ក្នុងផែនការមេៈ

**ការប្រៀបធៀបទិន្នផលជាមួយទិន្នផលគ្រោងក្នុងផែនការមេ**

| ចំណាត់ថ្នាក់ពូជ | ពូជ | លេខស្រែ | ទិន្នផលគ្រោងក្នុងផែនការមេ (ត/ហត) | ទិន្នផលមធ្យម ក្នុងឆ្នាំ 2006 (ត/ហត) | ភាពខុសគ្នា (ត/ហត) |
|---|---|---|---|---|---|
| ពូជមធ្យម | រាំងជ័យ | លេខ 1 | 3.0 | 3.9 | +0.9 |
| | រាំងជ័យ | លេខ 2 | 3.0 | 4.8 | +1.8 |
| | រាំងជ័យ | លេខ 3 | 3.0 | 3.9 | +0.9 |
| | នាងមិញ | លេខ 4 | 3.0 | 3.2 | +0.2 |
| | មធ្យម | | 3.0 | 4.0 | +1.0 |
| ពូជស្រាល | សែនពិដោរ | លេខ 5 | 3.0 | 4.01 | +1.0 |
| | សែនពិដោរ | លេខ 6 | 3.0 | 4.01 | +1.0 |
| | មធ្យម | | 3.0 | 4.0 | +1.0 |

*1/: ការវាយតម្លៃដោយអ្នកបង្ហាញ, ទិន្នផលប៉ាន់ស្មាន*

លទ្ធផលបង្ហាញថា ទិន្នផលស្រែផ្ទៀងផ្ទាត់មានទិន្នផលខ្ពស់ជាងទិន្នផលគ្រោងនៅក្នុងផែនការមេ ក្នុងឆ្នាំនេះ។

### (១១) សាកល្បងភាពបន្សាំខ្នាតតូច (២១.៤.៩)

#### (ក) សាកល្បងបន្សាំពូជស្រូវមធ្យម (២១.៤.៧.៣)

ការសាកល្បងបន្សាំពូជស្រូវមធ្យមរួមមាន ១) ការសាកល្បងពូជ, ២) ការគ្រប់គ្រងទឹកក្នុងស្រែ, ៣) របៀបដាំដុះ និងអាត្រាពូជ។ លទ្ធផលនៃការធ្វើពិសោធន៍ទាំងនេះមានដូចខាងក្រោមៈ

**លទ្ធផលនៃការសាកល្បងសាមញ្ញសម្រាប់ពូជស្រូវមធ្យមក្នុងតំបន់ ១**

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលដំណាំ ១/ | ទិន្នផលស្រូវក្នុង ស្រែទាំងមូល |
|---|---|---|---|
| ការសាកល្បងពូជ | ផ្ការំចង់ | 3.6 t/ha | - |
| | ផ្ការំដួល | 3.9 t/ha | 3.8 t/ha |
| | រាំងជ័យ | 5.9 t/ha | 3.9 t/ha |
| ការគ្រប់គ្រងទឹកក្នុងស្រែ (រាំងជ័យ) | បន្តជាប់គ្នាភាពមិនទៀងទាត់ | 4.7 t/ha | 3.7 t/ha |
| | ភាពមិនទៀងទាត់នៅក្នុងដំណាក់កាលនៃរុក្ខជាតិនានា | 5.9 t/ha | 4.4 t/ha |
| | ការលិចលង់ជាបន្តបន្ទាប់ | 5.1 t/ha | 3.2 t/ha |
| របៀបដាំដុះ និងអាត្រាពូជ (រាំងជ័យ) | 40 ក្រ/ម² និង2-3 ដើម/ទូល | 5.5 t/ha | 5.4 t/ha |
| | 60 ក្រ/ម² និង2-3 ដើម/ទូល | 5.8 t/ha | 5.7 t/ha |

*1/: សំណាកយកចេញពីចំណុចដែលបង្ហាញពីការលូតលាស់ធម្មតា*

### (១១) សាកល្បងបន្សាំពូជស្រូវដើមរដូវ (២១.៤.៩.៤)

ការសាកល្បងបន្សាំពូជស្រូវដើមរដូវរួមមាន: ១) ការសាកល្បងពូជ, ២) ការគ្រប់គ្រងទឹកក្នុង ស្រែ, ៣) របៀបដាំដុះ និងអាត្រាពូជ។ លទ្ធផលនៃការធ្វើពិសោធន៍ទាំងនេះ មានដូចខាងក្រោម:

**លទ្ធផលនៃការសាកល្បងសាមញ្ញសម្រាប់ពូជស្រូវដើមរដូវក្នុងតំបន់ ១**

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលដំណាំ ១/ | ទិន្នផលស្រូវក្នុង ស្រែទាំងមូល |
|---|---|---|---|
| ការសាកល្បងពូជ | IR 66 | 5.4 t/ha | 5.9 t/ha |
| | សែនពិដោរ | 5.9 t/ha | 4.5 t/ha |
| | IR កេសរ | 5.2 t/ha | 4.5 t/ha |
| ការគ្រប់គ្រងទឹកក្នុងស្រែ (សែនពិដោរ) | បន្តជាប់គ្នាភាពមិនទៀងទាត់ | 5.2 t/ha | 4.1 t/ha |
| | ភាពមិនទៀងទាត់នៅក្នុងដំណាក់កាលនៃរុក្ខជាតិនានា | 6.1 t/ha | 4.4 t/ha |
| | ការលិចលង់ជាបន្តបន្ទាប់ | 5.6 t/ha | 4.9t/ha |
| របៀបដាំដុះ និងអាត្រា ពូជ (សែនពិដោរ) | 40 ក្រ/ម² និង 1 ដើម/ទូល | 6.1 t/ha | 5.1 t/ha |
| | 40ក្រ/ម² និង 2-3 ដើម/ទូល | 5.7 t/ha | 4.6 t/ha |

1/: សំណាកយកចេញពីចំណុចដែលបង្ហាញពីការលូតលាស់ធម្មតា

### (១២) អង្កេតលើភាពទទួលបានរបស់កសិករ (២១.៤.១០)

អង្កេតលើភាពទទួលបានរបស់កសិករ ត្រូវបានអនុវត្តជាមួយនិងគោលបំណងនៃការវាយតំលៃដំបូងនៃភាពទទួលបានក្នុងការកែលំអការអនុវត្តការដាំដុះដំណាំ ដែលបានអនុវត្តក្នុងស្រែផ្ទៀងផ្ទាត់ដោយកសិករតាមរយៈការធ្វើអង្កេតសំភាសន៍សាមញ្ញជាមួយអ្នកធ្វើបទបង្ហាញ។ ការធ្វើអង្កេតនៃភាពទទួលយកបានត្រូវ បានអនុវត្តក្នុងតំបន់កែលំអការអនុវត្តការដាំដុះស្រូវតាមមធ្យោបាយនៃការធ្វើអង្កេតសំភាសន៍សាមញ្ញ ជាមួយអ្នកធ្វើបទបង្ហាញ។ គ្រប់អ្នកធ្វើបទបង្ហាញ (ចំនួនសរុប ៨ រូប) បានវាយតម្លៃថា " ល្អ " ឬ " អាត្រា សមរម្យ " ចំពោះការកំណត់យកការកែលំអការអនុវត្តការដាំដុះដំណាំ។

## គម្រោងទី ២: គម្រោងសាកល្បងកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្មលើការដាំដុះស្រូវ(តំបន់៣)

## ជំពូក ១២.១: គ្រប់ខ័ណ្ឌនៃគម្រោង

### (១៣) គោលបំណង (១២.១.១) និងសកម្មភាព (១២.១.២.១)

គោលបំណងនៃគម្រោងសាកល្បង គឺការបង្កើត ឡើងនូវគំរូដ៏ល្អមួយនៃការកែលំអធារាសាស្ត្រកសិកម្ម លើការដាំដុះស្រូវក្នុងតំបន់ ៣ (ការស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ) ។ សកម្មភាពបីប្រភេទត្រូវបានអនុវត្ត ក្នុងតំបន់ ៣ ដូចជា ១) ការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍, ២) ការផ្សព្វ ផ្សាយកសិកម្មដោយមានការចូលរួម, ៣) ការកែលំអការដាំដុះតាមរយះការពិសោធន៍ ។

## ជំពូក ១២.២: សកម្មភាពការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍ

### (១៤) គោលបំណង (១២.២.១) និងតំបន់សកម្មភាព (១២.២.៣.១)

គោលបំណងនៃគម្រោងសាកល្បងគឺសម្រេចឱ្យបាននូវការប្រើប្រាស់ទឹកក្នុងអាងប្រកបដោយប្រសិទ្ធ ភាព និងនិរន្តរភាព។ ប្រព័ន្ធធារាសាស្ត្រព្រៃបងមានផ្ទៃដីប្រមាណ ៤០ ហិកតា ស្ថិតនៅភូមិបន្ទាស្និត ត្រូវបានជ្រើសរើសសម្រាប់ពិសោធន៍ ។

### (១៥) ស្ថានភាពមុនពេលចាប់ផ្តើមគម្រោងសាកល្បង (១២.២.៣)

ប្រព័ន្ធធារាសាស្ត្រខាងលើមានលទ្ធភាពស្រោចស្រពស្រូវចុងរដូវវស្សាប៉ុណ្ណោះ ព្រោះប្រព័ន្ធនេះមានសភាពចាស់ទ្រុឌទ្រោមពុំមានលទ្ធភាពស្តុកទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រពលើផ្ទៃដីទាំងមូលឡើយ ។ ប្រព័ន្ធនេះគ្រប់គ្រងដោយក្រុមគ្រប់គ្រងទឹកត្រពាំងព្រៃបង។ ក្រុមនេះ ពុំដំណើរការល្អឡើយ ដោយកសិករពុំបានយកចិត្តទុកដាក់ចំពោះលទ្ធភាពនៃការស្តុកទឹកនៅក្នុងអាង។

### (១៦) សកម្មភាពអនុវត្តសម្រាប់ការកែលំអ (១២.២.៥)

ដោយសារភាពរាំងស្ងួតបានកើតឡើងនៅក្នុងឆ្នាំ ២០០៦/០៧ ធ្វើឱ្យប្រឡាយនៃប្រព័ន្ធធារាសាស្ត្រ ព្រៃបងពុំអាចប្រើប្រាស់បាន។ ដូចនេះ សកម្មភាពចំនួន ពីរ ត្រូវបានអនុវត្តដែលជាផ្នែកមួយនៃសកម្មភាព ការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍។

#### (ក) អនុវត្តការរៀបចំផែនទីកាន់កាប់ដីដំបូង

ការរៀបចំផែនទីកាន់កាប់ដីដំបូង មិនអាចអនុវត្តបាន ដោយកសិករមិនបានសហការការងារឱ្យបាន គ្រប់គ្រាន់ និងដោយសារតែខ្វះទំនុកចិត្តទៅលើប្រព័ន្ធធារាសាស្ត្របណ្តាលមកពីប្រភពទឹកមិនមានស្ថេរភាព។

#### (ខ) អនុវត្តការរៀបចំផែនទីប្រើប្រាស់ទឹក

ដែនរបស់ផ្ទៃអាងទឹក និងផ្លូវប្រឡាយស្រោចស្រពត្រូវបានអង្កេតតាមរបៀបសាមញ្ញ និងបានដៅ លើផែនទីសម្រាប់កែលំអការគ្រប់គ្រងទឹក។

## ជំពូក ១២.៣: សកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

### (១៧) គោលបំណង (១២.៣.១) និងផ្ទៃដី (១២.៣.៣.១)

គោលបំណងនៃសកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម គឺផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងប្រព័ន្ធ ប.វ.ស ជាមួយនឹងការចំណាយតិច និងកត្តាផលិតកម្មទាប។ ភូមិមហាលាភត្រូវបានជ្រើសរើសជាតំបន់សម្រាប់សកម្មភាព ពិសោធន៍។

### (១៨) សកម្មភាពអនុវត្តសម្រាប់កែលំអ (១១.៣.៥)

#### (ក) ផ្សព្វផ្សាយ SRI ពីកសិករមួយទៅកសិករមួយទៀត

នៅក្នុងការដឹកនាំដំបូង កសិករត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យអនុវត្តប្រព័ន្ធប្រពលវប្បកម្មស្រូវ ដូចដែលបានអនុវត្តនៅក្នុងតំបន់ ១។ កសិករ ០៤ រូប បានស្ម័គ្រចិត្តធ្វើជាកសិកពិសោធន៍ និងចូលរួមក្នុង សកម្មភាពត្រួតពិនិត្យ។ ការងារផ្សព្វផ្សាយដូចគ្នា ដែលបានអនុវត្តនៅក្នុងតំបន់ ១ ត្រូវបានយកមកអនុវត្ត នៅក្នុងតំបន់លនាពេលនេះ។

### (ខ) ការផ្សព្វផ្សាយការចិញ្ចឹមមាន់ពីកសិករមួយទៅកសិករមួយទៀត

ដោយពិនិត្យលើចំណាប់អារម្មណ៍របស់កសិករ ការចិញ្ចឹមមាន់បែបបរិស្ថាន ត្រូវបានជ្រើសរើស ជា សកម្មភាពនៅក្នុងរដូវប្រាំង ហើយវគ្គបណ្តុះបណ្តាលតាមភូមិ និងទស្សនៈកិច្ចសិក្សាស្តីពីការចិញ្ចឹមមាន់ ត្រូវបានរៀបចំ។

### (គ) ពង្រឹងក្រុមកសិករ

ក្រុមកសិករសកម្ម មានសារៈសំខាន់ណាស់សម្រាប់ការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ ទៀត។ ដូចនេះ ក្រុមកសិករត្រូវបានបង្កើតឡើង និងពង្រឹងតាមរយៈការធ្វើទស្សនៈកិច្ចសិក្សា និងការបណ្តុះ បណ្តាលតាមភូមិ។

## ជំពូក ១២.៤: សកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍

### (២០) គោលបំណង (១២.៤.១)

គោលបំណងនៃសកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍ គឺដើម្បីផ្ទៀងផ្ទាត់ទិន្នផល គ្រោងដែលបានប៉ាន់ស្មាននៅក្នុងផែនការមេ ត្រូវបានសម្រេចដោយការអនុវត្ត SRI ផ្អែកលើការអនុវត្ត ការ ដាំដុះដោយមានការកែលំអ និងសាកល្បងកែតម្រូវការអនុវត្តសម្រាប់ការកែលំអបន្ថែម។

### (២១) សកម្មភាពមុនពេលចាប់ផ្តើមសកម្មភាពគម្រោងសាកល្បង (១២.៤.៣)

លក្ខខណ្ឌកសិកម្មមុនពេលចាប់ផ្តើមគម្រោងសាកល្បងមានដូចខាងក្រោម:

| | |
|---|---|
| សំណាប | ពូជក្នុងស្រុកត្រូវបានប្រើប្រាស់ និងពុំសូវមានការផ្លាស់ប្តូរពូជដែលមានគុណ ភាពល្អ |
| ការស្ទូង | ការស្ទូងចង្រុះត្រូវបានអនុវត្ត |
| ការប្រើជីគី | ជីManure (០.៩ តោន/ហិកតា) និងជី DAP(៤៨ គក្រ) និងជីអ៊ុយរ៉េ (អាស្រ័យតាមរង្វាស់) |
| ទិន្នផលស្រូវ | ០.៩-១.៣ តោន/ហិកតា (មធ្យមភាគឆ្នាំ ២០០៣-២០០៦) |

### (២២) សាកល្បងផ្ទៀងផ្ទាត់ (១២.៤.៨ និង១២.៤.៨.៥)

ទិន្នផលស្រែសាកល្បងផ្ទៀងផ្ទាត់ចំនួន ០៥ កន្លែង ត្រូវបានប្រៀបធៀបជាមួយនិងទិន្នផលគ្រោងនៅ ក្នុងផែនការមេ:

**ការប្រៀបធៀបទិន្នផលជាមួយទិន្នផលគ្រោងក្នុងផែនការមេ**

| ចំណាត់ថ្នាក់ពូជ | ពូជ | លេខស្រែ | ទិន្នផលគ្រោងក្នុងផែនការមេ (ត/ហត) | ទិន្នផលមធ្យម ក្នុងឆ្នាំ 2006 /07 (ត/ហត) | ភាពខុសគ្នា (ត/ហត) |
|---|---|---|---|---|---|
| ពូជមធ្យម | រាំងជ័យ | លេខ 1 | 2.8 | 3.2 | +0.4 |
| | ជង្គង់មាន់ | លេខ 2 | 2.8 | 2.5 | −0.3 |
| | ស្រូវក្រហម | លេខ 3 | 2.8 | 3.2 | +0.4 |
| | រាំងជ័យ | លេខ 4 | 2.8 | 0.7 | −2.1 |
| | រាំងជ័យ | លេខ 5 | 2.8 | 1.6 | −1.2 |
| មធ្យម | | | 2.8 | 2.2 | +0.2 |

*ទិន្នផលគ្រោង: ទិន្នផលគ្រោងក្នុងផែនការមេ*

លទ្ធផលក្នុងតារាងបង្ហាញថា ទិន្នផលជាមធ្យមនៃស្រែផ្ទៀងផ្ទាត់មានកំរិតទាបជាងទិន្នផលគ្រោង នៅក្នុងផែនការមេ ទោះបីជាទិន្នផលនៃស្រែផ្ទៀងផ្ទាត់ពីរកន្លែងមានកំរិតខ្ពស់ជាងទិន្នផលគ្រោងនៅក្នុងផែន ការមេក៏ដោយ។

### (២៣) សាកល្បងភាពបន្សាំខ្នាតតូច (១២.៤.៩ និង១២.៤.៩.៤)

ការសាកល្បងបន្សាំពូជស្រូវមធ្យមរួមមាន ១) ការសាកល្បងពូជ, ២) ដង់ស៊ីតេដំណាំ, ៣) របៀប ដាំដុះ និងអាត្រាពូជ។ លទ្ធផលនៃការធ្វើពិសោធន៍ទាំងនេះមានដូចខាងក្រោម:

លទ្ធផលនៃការសាកល្បងសាមញ្ញសម្រាប់ពូជស្រូវមធ្យមក្នុងតំបន់ ៣

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលដំណាំ ១/ | ទិន្នផលស្រូវក្នុង ស្រែទាំងមូល |
|---|---|---|---|
| ការសាកល្បងពូជ | ផ្ការំចង់ | 3.9 t/ha | 2.9 t/ha |
| | ផ្ការំដួល | 2.4 t/ha | 2.3 t/ha |
| | សែនពិដោរ | 4.0 t/ha | - |
| | ចុងក្រមួន | 4.3 t/ha | 3.4 t/ha |
| | ឆ្មាព្រហ្ម | 4.1 t/ha | 3.4 t/ha |
| ដង់ស៊ីតេដំណាំ (រាំងជ័យ) | 20 * 20 cm | 2.9 t/ha | - |
| | 25 * 25 cm | 3.7 t/ha | - |
| | 30 * 30 cm | 4.0 t/ha | - |
| របៀបដាំដុះ និងអាត្រាពូជ (រាំងជ័យ) | 40 ក្រ/ម² និង 2-3 ដើម/ទូល | 3.7 t/ha | - |
| | 60 ក្រ/ម² និង 2-3 ដើម/ទូល | 4.9 t/ha | - |

*១/: សំណាកយកចេញពីចំណុចដែលបង្ហាញពីការលូតលាស់ធម្មតា*

### (២៤) អន្តេតលើភាពទទួលបានរបស់កសិករ (១២-៤.១០ និង ១២-៤.១០.៣)

គ្រប់អ្នកធ្វើបទបង្ហាញនៅក្នុងតំបន់គម្រោងបានវាយតម្លៃថា " ល្អ " ឬ " អាត្រា សមរម្យ " ចំពោះ ការកំណត់យកការអនុវត្តការដាំដុះដំណាំ។ គ្រប់អ្នកធ្វើបទបង្ហាញបានទទួលយកនូវរបៀបស្ទូងធម្មតា ដែល ជាការអនុវត្តមួយក្នុងចំណោមការអនុវត្តសំខាន់សម្រាប់យកមកផ្ទៀងផ្ទាត់។

## គម្រោងទី ៣: គម្រោងសាកល្បងស្តីពីការកែលំអសិកម្មរំពឹងទឹកភ្លៀង (តំបន់៤)

## ជំពូក ១៣-១: គ្រូបខំណ្ឌនៃគម្រោង

### (២៥) គោលបំណង (១៣-១.១)

គោលបំណងនៃគម្រោងសាកល្បង គឺការបង្កើតឡើងនូវគំរូដ៏ល្អមួយនៃការកែលំអសិកម្មរំពឹងទឹកភ្លៀង ក្នុងតំបន់ ៤។

### (២៦) សកម្មភាព (១៣-១.១)

គម្រោងគំរូបង្ហាញថា ដំណើរការអភិវឌ្ឍន៍ពីរជំហាន ផ្សារភ្ជាប់ជាមួយនិងសកម្មភាពចំនួនពីរគឺ ១) ផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម និង ២) ពិសោធន៍លើការកែលំអការអនុវត្តការដាំដុះ។ ក៏ប៉ុន្តែ សកម្មភាពស្តីពីការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍មិនត្រូវបានយកមកអនុវត្តនៅ ក្នុងតំបន់ ៤ ឡើយ។

## ជំពូក ១៣-២: សកម្មភាពផ្សព្វផ្សាយដោយមានការចូលរួម

### (២៧) គោលបំណង (១៣-២.១) និងតំបន់សកម្មភាព (១៣-២.៣.១)

គោលបំណងនៃសកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម គឺផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ដែលមានការចំណាយតិច និងប្រើប្រាស់កត្តាផលិតកម្មទាប។ ភូមិដំដែកត្រូវបានជ្រើសរើសជាតំបន់សកម្មភាពនៃគម្រោង។

### (២៨) ស្ថានភាពមុនពេលចាប់ផ្តើមគម្រោងសាកល្បង (១៣-២.៣)

ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ពុំទាន់បានអនុវត្ត និងក្រុមកសិករក៏ពុំទាន់បានបង្កើតនៅក្នុងភូមិដំ ដែក។

### (២៩) សកម្មភាពអនុវត្តសម្រាប់ការកែលំអ (១៣-២.៥)

#### (ក) ផ្សព្វផ្សាយ SRI ខុនចូលទាបពីកសិករមួយទៅកសិករមួយទៀត

នៅក្នុងការដឹកនាំដំបូង កសិករត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យអនុវត្តប្រព័ន្ធប្រពលវប្បកម្មស្រូវ ដូចដែលបានអនុវត្តនៅក្នុងតំបន់ ១។ កសិករ ០៣ រូប បានស្ម័គ្រចិត្តធ្វើជាកសិកពិសោធន៍ និងចូលរួមក្នុង សកម្មភាពត្រួតពិនិត្យ។ ការងារផ្សព្វផ្សាយដូចគ្នា ដែលបានអនុវត្តនៅក្នុងតំបន់ ១ ត្រូវបានយកមកអនុវត្ត នៅក្នុងតំបនល់នាពេលនេះ។

### (ខ) ការផ្សព្វផ្សាយការចិញ្ចឹមមាន់ពីកសិករមួយទៅកសិករមួយទៀត

ដោយពិនិត្យលើចំណាប់អារម្មណ៍របស់កសិករ ការចិញ្ចឹមមាន់បែបបរិស្ថាន ត្រូវបានជ្រើសរើស ជា សកម្មភាពនៅក្នុងរដូវប្រាំង ហើយវគ្គបណ្តុះបណ្តាលតាមភូមិ និងទស្សនៈកិច្ចសិក្សាស្តីពីការចិញ្ចឹមមាន់ ត្រូវបានរៀបចំ។

### (គ) ពង្រឹងក្រុមកសិករ

ក្រុមកសិករសកម្ម មានសារៈសំខាន់ណាស់សម្រាប់ការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ ទៀត។ ដូចនេះ ក្រុមកសិករត្រូវបានបង្កើតឡើង និងពង្រឹងតាមរយៈការធ្វើទស្សនៈកិច្ចសិក្សា និងការបណ្តុះ បណ្តាលតាមភូមិ។

## ជំពូក ១៣-៣: សកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍

### (៣០) គោលបំណង (១៣-៣.១)

គោលបំណងនៃសកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍ គឺដើម្បីផ្ទៀងផ្ទាត់ទិន្នផល គ្រោងដែលបានប៉ាន់ស្មានទៅក្នុងផែនការមេ ត្រូវបានសម្រេចដោយការអនុវត្ត SRI ផ្អែកលើការអនុវត្ត ការ ដាំដុះដោយមានការកែលំអ និងសាកល្បងកែតម្រូវការអនុវត្តសម្រាប់ការកែលំអបន្ថែម។

### (៣១) សកម្មភាពមុនពេលចាប់ផ្តើមសកម្មភាពគម្រោងសាកល្បង (១៣-៣.៣)

លក្ខខ័ណ្ឌកសិកម្មមុនពេលចាប់ផ្តើមគម្រោងសាកល្បងមានដូចខាងក្រោម:

| | |
|---|---|
| សំណាប | ពូជក្នុងស្រុកត្រូវបានប្រើប្រាស់ និងពុំសូវមានការផ្លាស់ប្តូរពូជដែលមានគុណ ភាពល្អ |
| ការស្ទូង | ការស្ទូងចម្រុះត្រូវបានអនុវត្ត |
| ការប្រើជីគី | ជីManure (៣.២ តោន/ហិកតា) និងជីDAP និងជីអ៊ុយរ៉េ និង ១៦-១៦-៨(អាស្រ័យតាមម្ចាស់) |
| ទិន្នផលស្រូវ | ១.៨-២.១ តោន/ហិកតា (មធ្យមភាគឆ្នាំ ២០០៣-២០០៥) |

### (៣២) សាកល្បងផ្ទៀងផ្ទាត់ (១៣-៣.៨ និង១៣-៤.៨.៥)

ទិន្នផលស្រែសាកល្បងផ្ទៀងផ្ទាត់ចំនួន ០៥ កន្លែង ត្រូវបានប្រៀបធៀបជាមួយនិងទិន្នផលគ្រោងនៅ ក្នុងផែនការមេ:

**ការប្រៀបធៀបទិន្នផលជាមួយទិន្នផលគ្រោងក្នុងផែនការមេ**

| ចំណាត់ថ្នាក់ពូជ | ពូជ | លេខស្រែ | ទិន្នផលគ្រោងក្នុង ផែនការមេ (ត/ហត) | ទិន្នផលមធ្យម ក្នុងឆ្នាំ 2006 /07 (ត/ហត) | ភាពខុសគ្នា (ត/ហត) |
|---|---|---|---|---|---|
| ពូជមធ្យម | ផ្កាព្រហ្ម | លេខ 1 | 2.0 | 4.4 | +2.4 |
| | រាំងជ័យ | លេខ 2 | 2.0 | 3.7 | −1.7 |
| | ផ្កាព្រហ | លេខ 3 | 2.0 | 3.9 | +1.9 |
| | ផ្កាព្រហ | លេខ 4 | 2.0 | 3.3 | −1.3 |
| | រាំងជ័យ | លេខ 5 | 2.0 | 3.2 | −1.2 |
| មធ្យម | | | 2.0 | 3.7 | −1.7 |

លទ្ធផលក្នុងតារាងបង្ហាញថា ទិន្នផលជាមធ្យមនៃស្រែផ្ទៀងផ្ទាត់មានកំរិតខ្ពស់ជាងទិន្នផលគ្រោង នៅក្នុងផែនការមេក្នុងឆ្នាំ ២០០៦/០៧។

### (៣៣) សាកល្បងភាពបន្សាំខ្នាតតូច (១៣-៣.៩ និង១៣-៣.៩.៤)

ការសាកល្បងបន្សាំពូជស្រូវមធ្យមរួមមាន ១) ការសាកល្បងពូជ, ២) សាកល្បងពូជ។ លទ្ធផលនៃ ការធ្វើពិសោធន៍ទាំងនេះមានដូចខាងក្រោម:

លទ្ធផលនៃការសាកល្បងសាមញ្ញសម្រាប់ពូជស្រូវមធ្យមក្នុងតំបន់ ៤

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលដំណាំ ១/ | ទិន្នផលស្រូវក្នុង ស្រែទាំងមូល |
|---|---|---|---|
| ការសាកល្បងពូជ (ស្ទូង) | ផ្ការំចង់ | 4.1 t/ha | - |
| | ផ្ការំដួល | 4.9 t/ha | - |
| | សែនពិដោរ | 3.0 t/ha | 2.4 t/ha |
| | ចុងក្រមួន | 3.3 t/ha | - |
| | ឆ្មាព្រហ្ម | 3.0 t/ha | 2.9 t/ha |
| | រាំងជ័យ | 2.5 t/ha | 2.2 t/ha |
| សាកល្បងពូជ (សាបផ្ទាល់) | ផ្ការំចង់ | 3.4 t/ha | - |
| | ផ្ការំដួល | 3.4 t/ha | - |
| | សែនពិដោរ | 2.8 t/ha | - |
| | ចុងក្រមួន | 2.5 t/ha | - |
| | ឆ្មាព្រហ្ម | 1.9 t/ha | 1.7 t/ha |
| | រាំងជ័យ | 1.7 t/ha | 2.1 t/ha |
| ការសាកល្បងសំណាប | 10 ប្រព្រឹត្តកម្ម | 3.7 t/ha | - |

*1/: សំណាកយកចេញពីចំណុចដែលបង្ហាញពីការលូតលាស់ធម្មតា*

## (៣៤) អន្តេតលើភាពទទួលបានរបស់កសិករ (២៣.៣.១០ និង ២៣.៣.១០.៣)

ផលិតផលស្រូវក្នុងស្រែផ្ទៀងផ្ទាត់ទាំងអស់នៅក្នុងតំបន់គម្រោងទទួលលទ្ធផលគួរជាទីពេញចិត្ត និង រាល់សំណើអនុវត្តគាំទ្រដោយអ្នកធ្វើបទបង្ហាញ។ ទិន្នផលស្រូវក្នុងស្រែផ្ទៀងផ្ទាត់ទាំងអស់មានការកើនឡើង បើប្រៀបធៀបជាមួយនិងទិន្នផលពីឆ្នាំមុន។ មូលហេតុនៃការកែលំអ គឺការកែលំអការអនុវត្តការដាំដុះ និង អំណោយផលទឹកភ្លៀង។

## គម្រោងទី ៤: ការផ្ទេរបច្ចេកវិជ្ជា និងការផ្លាស់ប្តូរបទពិសោធន៍ក្នុងគម្រោងសាកល្បង

**(៣៥)** តាមរយៈសកម្មភាពគម្រោងសាកល្បង បច្ចេកវិទ្យាផ្សេងៗ ត្រូវបានផ្ទេរទៅឱ្យមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម និងមន្ត្រីមន្ទីរកសិកម្មតាមការបណ្តុះបណ្តាលបែបរៀនផងធ្វើផង។ បទពិសោធន៍ទាំងនេះ ត្រូវបាន ផ្លាស់ជាមួយសមាជិកនៃក្រុមការងារតាមរយៈការប្រជុំរួមប្រចាំខែ។

## (៣៦) មេរៀនដែលបានសិក្សា (២៤.២.២)

មេរៀនដែលទទួលបានពីសកម្មភាពគម្រោងសាកល្បងបានអនុវត្តក្នុងឆ្នាំ ២០០៦/០៧ មានដូចខាង ក្រោម:

### ១) ការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍

<u>**យុទ្ធសាស្ត្រ -១ : សិក្សាពីការអនុវត្តរបស់កសិករល្អក្នុងប្រទេសកម្ពុជា**</u>

- ភាពចាំបាច់ក្នុងការអភិវឌ្ឍន៏ធនធានទឹកនៅតំបន់ខ្វះខាតទឹក
- សារៈសំខាន់នៃវដ្ត Quick Plan-Do-See ក្នុងការប្រតិបត្តគម្រោង
- ភាពចាំបាច់នៃការជម្រុញកសិករដោយបញ្ជាក់ពីការផ្លាស់ប្តូរអតៈចារីករបស់គេ
- ភាពចាំបាច់ក្នុងការលើកទឹកចិត្តដល់សមាជិក ស.ក.ប.ទ
- កំណត់គន្លឹះនៃការប្រមូលថ្លៃសេវាស្រោចស្រពឱ្យបានសមស្រប

**យុទ្ធសាស្ត្រ -២ : ការប្រតិបត្តគម្រោងដោយសហការជាមួយកសិករ-រដ្ឋាភិបាល-NGO**

- ស្ថាប័នពាក់ព័ន្ធដែលទាក់ទងក្នុងសកម្មភាពគម្រោង
- ភាពចាំបាច់នៃដំណើរការសមរម្យក្នុងសកម្មភាព ស.ក.ប.ទ

**យុទ្ធសាស្ត្រ -៣ : ភ្នាក់ងាររដ្ឋាភិបាលអនុវត្តសកម្មភាពពាក់ព័ន្ធនិងធារាសាស្ត្រកសិកម្ម**

- រកឃើញនូវពេលវេលាសមស្របនៃការធ្វើសមាហរណកម្មសកម្មភាពពង្រឹង ស.ក.ប.ទ និងសកម្មភាពផ្សព្វផ្សាយកសិកម្ម
- ប្រសិទ្ធភាពនៃការប្រើប្រាស់ទុនសង្គមដែលមានស្រាប់របស់សហគមន៍មូលដ្ឋាន
- សមត្ថភាពខ្ពស់នៃមន្ត្រីនៅតាមមន្ទីរខេត្តក្នុងការប្រាស្រ័យទាក់ទងនិងប្រជាជន
- ភាពចាំបាច់នៃការអនុវត្តវិធីសាស្ត្រផ្សេងៗដើម្បីជម្រុញ ស.ក.ប.ទ ឬ ក្រុមគ្រប់ គ្រងទឹកនៅក្នុងតំបន់ផ្សេងៗ។

**យុទ្ធសាស្ត្រ -៥ : ការណែនាំការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយទៀត**

- ប្រសិទ្ធភាពនៃការពិភាក្សាតាមក្រុមក្នុងអង្គប្រជុំ និងវគ្គបណ្តុះបណ្តាល

**ផ្សេងៗ**

- សារៈសំខាន់នៃការផ្តល់ការអប់រំមិនផ្ទាល់ដល់កសិករ
- លើកទឹកចិត្តកសិករ និងមន្ត្រីនៅមូលដ្ឋានឱ្យចេះគិតពិចារណា
- ការប្រើប្រាស់សមស្របនូវទិន្នន័យវិទ្យាសាស្ត្រប្រមូល និងទទួលបាន
- ភាពចាំបាច់ក្នុងការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព
- ភាពចាំបាច់នៃការយល់ដឹងសមស្របនូវលក្ខខ័ណ្ឌ និងតម្រូវការចាំបាច់សម្រាប់ ស.ក.ប.ទ ដែលសកម្ម
- ភាពចាំបាច់ក្នុងការកែលំអរដ្ឋបាលរបស់ ស.ក.ប.ទ មុនពេលអនុវត្តការគ្រប់គ្រង ទឹក
- ភាពលំបាកក្នុងការបង្កើតបណ្តាញឆ្លងភូមិសម្រាប់សកម្មភាពរបស់ ស.ក.ប.ទ
- ប្រសិទ្ធភាពក្នុងការប្រើប្រាស់ព្រឹត្តការណ៍ក្នុងភូមិនានាសម្រាប់សកម្មភាពរបស់ ស.ក.ប.ទ
- សារៈសំខាន់នៃការរៀបចំផែនទីកាន់កាប់ដីដំបូងក្នុងការពង្រឹង ស.ក.ប.ទ
- ភាពចាំបាច់ក្នុងការអភិវឌ្ឍន៍របៀបរៀបចំផែនទីកាន់កាប់ដីដំបូងដែលមានតម្លៃ ទាប
- ភាពចាំបាច់នៃការបង្កើតវិធីសាស្ត្រសាមញ្ញសម្រាប់កែលំអផែនទីកាន់កាប់ដីដំបូង
- ប្រសិទ្ធភាពក្នុងការណែនាំដល់ ស.ក.ប.ទ នូវការផ្តួចផ្តើមប្រព័ន្ធបណ្តុះបណ្តាល
- ភាពចាំបាច់ក្នុងការផ្តល់ព័ត៌មានបច្ចេកទេសដល់មន្ត្រីមន្ទីរធនធានទឹក

## ២) ការផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

**យុទ្ធសាស្ត្រ -២ : ការប្រតិបត្តគម្រោងដោយសហការជាមួយកសិករ-រដ្ឋាភិបាល-NGO**

- សារៈសំខាន់ក្នុងការបង្ហាញបែបផ្សេងគ្នានៃការអនុវត្តការដាំដុះក្នុងការផ្សព្វ ផ្សាយកសិកម្ម

**យុទ្ធសាស្ត្រ -៥: ការណែនាំការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយទៀត**

- កំណត់ចំណុចគន្លឹះសម្រាប់ការផ្សព្វផ្សាយកសិកម្មដោយមានការចូលរួមប្រកប ដោយប្រសិទ្ធភាព
- សារៈសំខាន់ក្នុងការផ្លាស់ប្តូរបទពិសោធន៍តាមរយៈបណ្តាញកសិករ
- សារៈសំខាន់របស់ក្រុមកសិករក្នុងការផ្សព្វផ្សាយកសិកម្ម និងកិច្ចអភិវឌ្ឍន៍បន្ត

**ផ្សេងៗ**

- សារៈសំខាន់នៃការទ្រទ្រង់ខ្លួនឯងរបស់កសិករក្នុងការកែលំអការអនុវត្តការដាំដុះ

- ការវាយតម្លៃលើភាពងាយស្រួល និងការលំបាក ស្តីពីគោលការណ៍នៃប្រព័ន្ធប្រពលវប្បកម្ម ស្រូវ (SRI) ដែលប្រើប្រាស់កត្តាផលិតកម្មទាប ដោយកសិករ
- លទ្ធភាពនៃការអនុវត្តដំណើរការផ្សព្វផ្សាយស្រដៀងគ្នានៅគ្រប់តំបន់
- ភាពចាំបាច់ក្នុងការដឹកនាំកសិករឱ្យទទួលយកនូវការអនុវត្តការដាំដុះថ្មី
- ភាពចាំបាច់ក្នុងបន្តសកម្មភាពនៅក្នុងរដូវប្រាំង
- សារៈសំខាន់នៃការសាកល្បងSRI ដោយមិនប្រើប្រាស់ពូជថ្មី
- ប្រសិទ្ធភាពរឹងទុកនៃសកម្មភាពសន្សំស្តីពីនិរន្តរភាព និងការទ្រទ្រង់ខ្លួនឯង របស់ក្រុមកសិករ
- ដំណើរដែលបានលើកឡើងក្នុងការបង្កើតសហករនៅពេលអនាគត

## ៣) ការពិសោធន៍លើការកែលំអការអនុវត្តការដាំដុះ

<u>**យុទ្ធសាស្ត្រ -៤ : ការប្រើប្រាស់អប្បបរមានូវសំភារៈ និងឧបករណ៍របស់កសិករ**</u>

- ការកែលំអភាពងាយស្រួលដោយកសិករស្តីពីកំណត់ជំនាញដាំដុះ
- តម្រូវការកែលំអការអនុវត្តការដាំដុះដែលកំណត់ថាជាការលំបាកចំពោះកសិករ

<u>**ផ្សេងៗ**</u>

- ភាពចាំបាច់នៃការពិចារណាឱ្យបានម៉ត់ចត់ស្តីពីលក្ខខ័ណ្ឌហិរញ្ញវត្ថុរបស់កសិករ
- សារៈសំខាន់ក្នុងការកែលំអការអនុវត្តការដាំដុះដើម្បីជៀសវាងការដុះមិនធម្មតា នៅក្នុងស្រែ
- ភាពចាំបាច់ក្នុងការបង្ហាញការសាកល្បងប្រៀបធៀបសាមញ្ញ ដែលអាចអនុវត្ត ដោយកសិករ
- ភាពចាំបាច់ក្នុងការផ្តល់សិទ្ធដល់មន្ត្រីផ្សព្វផ្សាយកសិកម្មដោយរៀនផងអនុវត្តផង
- ភាពចាំបាច់ក្នុងការបង្កើតប្រព័ន្ធផ្សព្វផ្សាយការអនុវត្ត

## <u>ផ្នែក គ: គម្រោងសាកល្បង (២០០៦/២០០៧)</u>

## គម្រោងទី ១: គម្រោងសាកល្បងកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្មលើការដាំដុះស្រូវ(តំបន់១)

## ជំពូក គ១_១: ក្របខ័ណ្ឌនៃគម្រោង

### (១) តំបន់គម្រោង (គ១_១.២)

សកម្មភាពចំនួនបីដែលបានពិពណ៌នានៅក្នុងចំណុច (១) នៃជំពូក ខ១-១, ផ្នែក ខ : គម្រោងសាកល្បង (២០០៦/២០០៧), បានអនុវត្តនៅក្នុងតំបន់ដូចខាងក្រោម:

**ការគ្រប់គ្រងតំបន់ជ្រើសរើស/ស្រែ សម្រាប់សកម្មភាពបីក្នុងតំបន់១**

| ខេត្ត | ស្រុក | ឃុំ | ភូមិ | សកម្មភាព ទី១ | សកម្មភាព ទី២ | សកម្មភាព ទី៣ |
|---|---|---|---|---|---|---|
| កំពង់ស្ពឺ | សំរោងទង | កាហែង | បូសតានៃ | ○ | | ○ |
| | | | កាហែង | ○ | ○ | |
| | | | អូរវែង | ○ | | |
| | ច្បារមន | កណ្តោលដុំ | ស្រែថ្មល់ | ○ | ○ | |
| | | | ពង្រ | ○ | | |
| | | | កណ្តោលដុំ | | ○ | |
| | | | រំលៀង | | ○ | |
| | | | ត្រពាំងព្រះ | | ○ | |

## ជំពូក គ១.២: សកម្មភាពការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍

### (២) សកម្មភាពអនុវត្តសម្រាប់កែលំអ (គ១.២.៥ និងគ១.២.៥.១)

នៅក្នុងឆ្នាំ ២០០៦/២០០៧ ការកែលំអការគ្រប់គ្រងទឹករបស់ **ស.ក.ប.ទ** អូរវែង បានពិភាក្សារវាងសមាជិក **ស.ក.ប.ទ** និងមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម ដោយមានការសម្របសម្រួលពីក្រុមសិក្សាជប៉ុន ផ្អែកលើ លទ្ធផលនៃទស្សនៈកិច្ចសិក្សានៅ **ស.ក.ប.ទ** ដែលមានភាពជឿនលឿន។ ដូចនេះ ផែនការកែលំអរួមមាន ១១ ចំណុចត្រូវបានពិពណ៌នាលំអិត។ សកម្មភាព ៣ ក្នុងចំណោមសាកម្មភាព ១១ ចំណុច បានបញ្ចប់ពីឆ្នាំ ២០០៦ ទៅ ឆ្នាំ ២០០៧។ សកម្មភាពចំនួន ៨ ចំណុចដែលនៅសល់ ត្រូវបានអនុវត្ត និងបានបញ្ចប់ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៨ ដែលមានការពន្យល់ដូចខាងក្រោម:

### (៣) ការកំណត់ការបាត់បង់ទឹក និងការកាត់បន្ថយការអនុវត្ត (គ១.២.៣)

សកម្មភាព ៣ ត្រូវបានអនុវត្តដើម្បីកាត់បន្ថយឱ្យបានអតិបរមានូវការបាត់បង់ទឹក: ការកែលំអសំណង់បង្ហៀរដែលមិនទាន់គ្រប់លក្ខណៈបច្ចេកទេស, យកចេញនូវបំពង់បង្ហូរទឹកមិនលក្ខណៈបច្ចេកទេស និងជួសជុល ប្រហោងតូច។ មុនពេលអនុវត្តការងារនេះ ការបាត់បង់ទឹកត្រូវបានវាស់ប្រមាណ ៦០% នៅក្នុងប្រឡាយ RT-2 ក៏ប៉ុន្តែបន្ទាប់ពីការជួសជុល ការបាត់បង់ទឹកថយមកត្រឹម ១៦%។

### (៤) ការបង្កើតអនុក្រុម ស.ក.ប.ទ (គ១.២.៥.៤)

អនុក្រុម **ស.ក.ប.ទ** ត្រូវបានបង្កើតឡើងដោយផ្អែកលើស្ថានភាពរបស់ប្រឡាយ និងតំរង់ឆ្ពោះទៅ សកម្មភាពសកម្មរបស់ **ស.ក.ប.ទ** ។ ប្រធាននៃក្រុមប្រើប្រាស់ទឹក ត្រូវបានជ្រើសរើសដោយការបោះឆ្នោត និងប្រធាននៃក្រុមកសិករប្រើប្រាស់ទឹក ត្រូវបានជ្រើសរើសដោយក្រុមប្រើប្រាស់ទឹក។

### (៥) អនុវត្តការកែលំអរដ្ឋបាល ស.ក.ប.ទ (គ១.២.៥.៥)

មន្ទីរធនធានទឹក និងឧតុនិយម និងអង្គការក្រៅរដ្ឋាភិបាល បានបើកវគ្គបណ្តុះបណ្តាលដល់សមាជិក គណៈកម្មាធិការ **ស.ក.ប.ទ** ហើយប្រធានក្រុមប្រើប្រាស់ទឹក និងក្រុមប្រើប្រាស់ទឹក កែលំអសមត្ថភាពចាត់ចែង របស់ពួកគេ។ ដូចនេះ អាត្រាប្រមូលថ្លៃសេវាស្រោចស្រពដែលទទួលបានមានចំនួន ៨៦% ដែលមានការកើនឡើង ខ្លាំងបើធៀបនឹងពេលមុនមានត្រឹមតែ ១០% ប៉ុណ្ណោះ។

### (៦) អនុវត្តការអប់រំការប្រើប្រាស់ទឹកសមស្រប (គ១.២.៥.៦)

ដើម្បីឱ្យសមាជិក **ស.ក.ប.ទ** កែលំអស្ថានភាព បច្ចុប្បន្ន ទស្សនាវត្តីរបស់ **ស.ក.ប.ទ** អូរវែង ត្រូវបាន បោះពុម្ព និងប្រើប្រាស់ជាឧបករណ៍សម្រាប់ព័ត៌មានសាធារណៈ។ នៅក្នុងទស្សនាវត្តី ពាក្យស្លោក បានពិពណ៌នាការលើកដំកើងការយល់ដឹងស្តីពីសកម្មភាព របស់ **ស.ក.ប.ទ**។ ក្រោយពីការផ្សព្វផ្សាយ ទស្សនាវត្តី សមាជិក **ស.ក.ប.ទ** បានចូលរួមយ៉ាងសកម្មក្នុងការជួសជុលប្រឡាយ RT-2 ហើយសមាជិក ស.ក.ប.ទ ប្រមាណ ៩៧% បានបង់ថ្លៃសេវាទឹក។

**<u>ពាក្យស្លោករបស់ ស.ក.ប.ទ</u>**

- ចូរនាំគ្នាប្រើប្រាស់ទឹកប្រឡាយឱ្យមានប្រសិទ្ធ ភាព និងស្មើភាពគ្នា
- ចូរនាំគ្នាថែរក្សាសំណង់ឱ្យបានល្អ
- ចូរនាំគ្នាជៀសវាងការប្រើប្រាស់ទឹកដោយគ្មាន ការអនុញ្ញាត
- ចូរនាំគ្នាបង់ថ្លៃសេវាទឹកសម្រាប់សកម្មភាពសមស្របរបស់ **ស.ក.ប.ទ**

### (៧) អនុវត្តការរៀបចំផែនការសេវាថ្លៃទឹក (គ១.២.៥.៧)

ផែនការសេវាថ្លៃទឹក ត្រូវបានរៀបចំដោយ ស.ក.ប.ទ ដោយមានការគាទ្រពីមន្ទីរធនធានទឹក និងឧតុនិយម និងក្រុមសិក្សាជប៉ុន។ ផ្អែកលើផែនការសេវាថ្លៃទឹក ស.ក.ប.ទ បានអនុវត្តការផ្តល់ទឹកឆ្លាស់គ្នា និង ធ្វើការជួសជុលប្រឡាយ RT-2 ។

### (៨) អនុវត្តការសាងសង់/ជួសជុលប្រឡាយនាំទឹកបញ្ចូលស្រែ (គ១.២.៥.៨)

ការសាងសង់/ការជួសជុលប្រឡាយនាំទឹកបញ្ចូលស្រែ អនុវត្តដោយសមាជិក**ស.ក.ប.ទ** ក្រោមការត្រួត ពិនិត្យដោយមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម។ ប្រឡាយប្រវែង ២,៤៧៥ ម ត្រូវបានជួសជុល ស្មើនឹង ៧០% នៃផែនការជួសជុល។ ស.ក.ប.ទ សន្យានឹងបន្តការជួសជុលប្រឡាយដែលនៅសេសសល់ឱ្យបានមុនពេលការដាំដុះ ស្រូវបន្ទាប់ចាប់ផ្តើម។

### (៩) អនុវត្តវគ្គបណ្តុះបណ្តាលការគ្រប់គ្រងទឹក (គ១-២.៥.៩)

បច្ចុប្បន្ននេះ ផ្ទៃដីស្រែស្ថិតនៅខ្សែទឹកខាងក្រោមមិនទទួលបានទឹកគ្រប់គ្រាន់ឡើយ។ ដូចនេះ ដើម្បីកែ លំអស្ថានភាពនេះ ការស្រោចស្រពឆ្លាស់ត្រូវបានយកមកអនុវត្ត។ ទាក់ទងនឹងការងារនេះ មន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម និងក្រុមសិក្សាជប៉ុន បានបណ្តុះបណ្តាលឆ្មាំទ្វារទឹកឱ្យអនុវត្តតាមប្រតិទិនផ្គត់ផ្គង់ទឹកឆ្លើយតបទៅនឹង តម្រូវការទឹកនៅតាមស្រែ។

### (១០) អនុវត្តការសាងសង់ស្នាក់ការរបស់ ស.ក.ប.ទ (គ១-២.៥.១០)

**ស.ក.ប.ទ** អូរវែង ពុំមានស្នាក់ការសម្រាប់អនុវត្តការងាររដ្ឋបាលដូចជា ផ្នែកគណនេយ្យ, ការរៀបចំផែន ការសេវាស្រោចស្រព និងការរៀបចំកិច្ចប្រជុំ។ ដូចនេះ ស្នាក់ការ **ស.ក.ប.ទ** ត្រូវបានសាងសង់ដោយមន្ទីរធនធាន ទឹក និងឧតុនិយមក្រោមការឧបត្ថម្ភថវិកាពីអង្គការ JICA។

## ជំពូក គ១-៣: សកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

### (១១) សកម្មភាពអនុវត្តសម្រាប់កែលំអ (គ១-៣.៥)

(ក) អនុវត្តផ្សព្វផ្សាយបរិស្ថានពីកសិករមួយទៅកសិករមួយទៀត (គ១-៣.៥.២)

ការងារផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវដូចខាងក្រោមនេះ បានបញ្ចប់នៅក្នុងរដូវនេះ:

- ទស្សនៈកិច្ចសិក្សានៅខេត្តកំពង់ចាមដើម្បីសិក្សាអំពីការដាំបែបប្រព័ន្ធប្រពលវប្បកម្មស្រូវ។ កសិករពីតំបន់ ១ ចំនួន ១៥ នាក់ បានចូលរួមក្នុងដំណើរទស្សនៈកិច្ចសិក្សា។
- ការបណ្តុះបណ្តាលតាមភូមិដល់ក្រុមកសិករ
- ការបណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយកសិករ ដែល ស្ម័គ្រចិត្តធ្វើពិសោធន៍នៅក្នុង ០៣ តំបន់ (តំបន់ ១ , តំបន់ ៣ និងតំបន់ ៤)
- គាំទ្រ និងតាមដានកសិករពិសោធន៍ស្តីពីដំណោះស្រាយបញ្ហាដែលបានជួបប្រទះ ការជ្រើសរើស ពូជស្រូវល្អ និងការប្រមូលទិន្នន័យ។
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន កសិករដែលបានអនុវត្ត SRI មានចំនួន ៨២ នាក់ នៅខែ មករា ឆ្នាំ ២០០៨ លើសពីផែនការគ្រោងមានត្រឹមចំនួន ៥០ នាក់។

#### (ខ) ផ្សព្វផ្សាយការចិញ្ចឹមមាន់ពីកសិករមួយទៅកសិករ (គ១-៣.៥.៣)

វគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ដែលបានអនុវត្តត្រូវបានបង្ហាញខាងក្រោមនេះ:

- ទស្សនៈកិច្ចសិក្សានៅភូមិអណ្តូងរវៀង និងភូមិស្អកក្បាស ស្ថិតក្នុងស្រុក បរិបូណ៌ និងរលាផ្អៀរ ខេត្តកំពង់ឆ្នាំងដើមីសិក្សាអំពីការចិញ្ចឹមមាន់
- បណ្តុះបណ្តាលតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទោភូមិមួយទៀត
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន កសិករដែលបានអនុវត្ត SRI មានចំនួន ១១ នាក់ នៅខែ មករា ឆ្នាំ ២០០៨ ។

#### (គ) ពង្រឹងក្រុមកសិករ (គ១-៣.៥.៤)

ក្រុមកសិករសកម្ម ត្រូវបានបង្កើតឡើង និងពង្រឹងតាមរបៀបដូចខាងក្រោម:

- ទស្សនៈកិច្ចសិក្សា (សិក្ខាកាមបានពិភាក្សាផងដែរអំពីក្រុមកសិករក្នុងដំណើរទស្សនៈកិច្ចសិក្សា សម្រាប់ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ និងការចិញ្ចឹមមាន ។)
- ការបណ្តុះបណ្តាលតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន ក្រុមកសិករ ចំនួន ១៦ ក្រុមត្រូវបានរៀបចំជាក្រុមសន្សំ ហើយថវិកាដែលប្រមូលមានចំនួន ១៩,៩៦៥,៤០០ រៀល នៅខែ មករា ឆ្នាំ ២០០៨ ។

## ជំពូក គ១-៤: សកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍

### (១២) ការសាកល្បងផ្ទៀងផ្ទាត់ (គ១-៤.៤, គ១.៤.៥, គ១.៤.៥.៥)

ការសាកល្បងផ្ទៀងផ្ទាត់ត្រូវបានអនុវត្តលើស្រែចំនួន ៥ កន្លែង ។ ទិន្នផលនៅក្នុងស្រែទាំង ៥ នោះ មានដូចខាងក្រោមនេះ:

**ការប្រៀបធៀបទិន្នផលជាមួយទិន្នផលគ្រោងក្នុងផែនការមេ (ត/ហត)**

| ចំណាត់ថ្នាក់ពូជ | ពូជ | លេខស្រែ | ទិន្នផលគ្រោងក្នុងផែនការមេ (ត/ហត) | ទិន្នផលមធ្យម ក្នុងឆ្នាំ 2006 /07 (ត/ហត) | ភាពខុសគ្នា (ត/ហត) |
|---|---|---|---|---|---|
| ពូជមធ្យម | រាំងជ័យ | លេខ 1 | 3.0 | 3.7 | +0.7 |
| | រាំងជ័យ | លេខ 4 | 3.0 | 3.1 | +0.1 |
| | រាំងជ័យ | លេខ 5 | 3.0 | 3.6 | +0.6 |
| | មធ្យម | | 3.0 | 3.5 | +0.5 |
| ពូជដើមរដូវ | សែនពិដោរ | លេខ 2 | 3.3 | 3.4 | +0.1 |
| | សែនពិដោរ | លេខ 3 | 3.3 | 4.0 | +0.7 |
| | មធ្យម | | 3.3 | 3.7 | +0.4 |
| មធ្យមរួម | | | 3.2 | 3.6 | +0.4 |
| ស្រែកសិករ 1/ | រាំងជ័យ | 2 ស្រែ | - | 2.8 | - |

*ទិន្នផលគ្រោង: ទិន្នផលគ្រោងក្នុងផែនការមេក្នុងរដូវវស្សា*

*1/: លទ្ធផលនៃការធ្វើអង្កេតលើផ្ទៃដីស្រែទំហំ ២មX ២មបានបង្ហាញពីការលូតលាស់មធ្យមដ៏វិញស្រែផ្ទៀងផ្ទាត់*

លទ្ធផលក្នុងតារាងបង្ហាញថា ទិន្នផលនៃស្រែផ្ទៀងផ្ទាត់មានកំរិតខ្ពស់ជាងទិន្នផលគ្រោងនៅក្នុង ផែនការមេ ។

### (១៣) សាកល្បងភាពបន្សាំខ្នាតតូច (គ១-៤.៦.២, គ១-៤.៦, គ១-៤.៦.៤)

#### (ក) សាកល្បងបន្សាំពូជស្រូវមធ្យម (គ១-៤.៦, គ១-៤.៦.៤)

ការសាកល្បងបន្សាំពូជស្រូវមធ្យមរួមមាន ១) វិធីសាស្ត្រដាំដុះ, ២) ការគ្រប់គ្រងទឹកក្នុងស្រែ, ៣) ការសាកល្បងប្រើប្រាស់ជី ។ លទ្ធផលនៃការធ្វើពិសោធន៍ទាំងនេះមានដូចខាងក្រោម:

**លទ្ធផលនៃការសាកល្បងសម្រាប់ពូជស្រូវមធ្យមក្នុងតំបន់ ១**

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលដំណាំ ១/ | ទិន្នផលស្រូវក្នុងស្រែទាំងមូល |
|---|---|---|---|
| វិធីសាស្ត្រដាំដុះ (រាំងជ័យ) | ១ ដើម/ទូល | 4.4 t/ha | 3.7 t/ha |
| | ២ ដើម/ទូល | 5.4 t/ha | 3.8 t/ha |
| | ៣ ដើម/ទូល | 3.9 t/ha | 4.0 t/ha |

| | | | |
|---|---|---|---|
| | ៤ ដើម/ទូល | 4.3 t/ha | 3.8 t/ha |
| | ៥ ដើម/ទូល | 4.8 t/ha | 3.9 t/ha |
| វិធីសាស្ត្រដាំដុះ | ១ ដើម/ទូល | 3.1 t/ha | - |
| (វាំងជ័យ) | ២ ដើម/ទូល | 2.7 t/ha | - |
| | ៣ ដើម/ទូល | 2.5 t/ha | - |
| | ៤ ដើម/ទូល | 2.4 t/ha | - |
| | ៥ ដើម/ទូល | 2.4 t/ha | - |
| ការគ្រប់គ្រងទឹកក្នុងស្រែ | បន្តជាប់គ្នាភាពមិនទៀងទាត់ | 5.1 t/ha | 4.3 t/ha |
| (វាំងជ័យ) | ភាពមិនទៀងទាត់នៅក្នុង ដំណាក់កាលនៃរុក្ខជាតិនានា | 4.3 t/ha | 4.0 t/ha |
| | ការលិចលង់ជាបន្តបន្ទាប់ | 4.9 t/ha | 3.9 t/ha |
| សាកល្បងប្រើប្រាស់ជី ១/ | ជី Manure ១០ ត/ហត | 4.6 t/ha | 4.2 t/ha |
| (វាំងជ័យ) | ជី Manure ០៥ ត/ហត | 4.2 t/ha | 3.8 t/ha |
| | ជី Manure ២.៥ ត/ហត | 4.5 t/ha | 4.3 t/ha |
| | ជីគីមី | 4.6 t/ha | 4.3 t/ha |

*ការអង្កេតដំណាំ: សំណាក ១/ប្រព្រឹត្តកម្ម, សំណាកចម្រុះសម្រាប់ផ្ទៃដី ១ម៉ែ² (១៦ ទូល) នៅស្រែលូតលាស់ធម្មតា*

*១/: មធ្យមភាគប្រព្រឹត្តកម្មបីដង*

### (២) សាកល្បងបន្សាំពូជស្រូវដើមរដូវ (គ១_៤.៦, គ១_៤.៦.៤)

វិធីសាស្ត្រដាំដុះត្រូវបានអនុវត្តក្នុងការសាកល្បងបន្សាំពូជស្រូវដើមរដូវ ។ លទ្ធផលនៃការធ្វើ ពិសោធន៍ទាំងនេះ មានដូចខាងក្រោម:

**លទ្ធផលនៃការសាកល្បងសម្រាប់ពូជស្រូវដើមរដូវក្នុងស្ថានីយ៍ព្រៃផ្តៅ១/**

| សាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលក្នុងស្រែទាំងមូល | |
|---|---|---|---|
| | | ចន្លោះ | មធ្យម |
| របៀបដាំដុះ (IR 66) | ដាំដុះធម្មតា | 4.7 ~ 4.8 t/ha | 4.7 t/ha |
| | ដាំដុះចម្រុះ | 4.1 ~ 4.8 t/ha | 4.5 t/ha |
| | ព្រោះពូជ | 4.1 ~ 4.4 t/ha | 4.3 t/ha |
| | សាបផ្ទាល់ | 4.1 ~ 4.9 t/ha | 4.5 t/ha |

*១/: មធ្យមភាគប្រព្រឹត្តកម្មបីដង*

លទ្ធផលបង្ហាញថា ពុំមានភាពច្បាស់លាស់រវាងប្រព្រឹត្តកម្ម ទោះជាយ៉ាងណាក៏ដោយលទ្ធភាពនៃ ការអនុវត្តតាមការព្រោះពូជ និងសាបពូជផ្ទាល់ស្ថិតក្រោមលក្ខខ័ណ្ឌមានទឹកត្រូវបានកំណត់ ។

### (១៤) អង្កេតលើភាពទទួលបានរបស់កសិករ (គ១_៤.៧ និងគ១_៤.៧.៣)

តាមលទ្ធផលគ្រប់អ្នកធ្វើបទបង្ហាញ (ចំនួនសរុប ៨ រូប) បានវាយតម្លៃថា ការកំណត់យកការ កែលំអការអនុវត្តការដាំដុះគឺជាមធ្យោបាយល្អ ឬ សមស្រប ។ កិច្ចសភាសន៍ជាមួយសមាជិកក្រុមកសិករ បង្ហាញថា ការអនុវត្តដូចជា ការបន្ថយចំនួនដើមស្រូវ/ទូល , ដាំដើមស្រូវក្មេង និងបន្ថយអាត្រាពូជ គឺជាការ ងារងាយស្រួលដែលកសិករអាចទទួលបាន ហើយការងារនេះនឹងត្រូវបានផ្សព្វផ្សាយយ៉ាងរហ័សជាមួយនិង ការបង្ហាញ និងការផ្តល់ទាន់ពេលវេលានូវការណែនាំ ។

## គម្រោងទី ២: គម្រោងសាកល្បងកែលំអបច្ចេកវិជ្ជាធារាសាស្ត្រកសិកម្មលើការដាំដុះស្រូវ(តំបន់៣)

## ជំពូក គ២-១: គ្រប់ខំណូដៃគម្រោង

### (១៥) ផ្ទៃដី (គ២-១.២ និងគ២-១.២.១)

សកម្មភាពចំនួន ៣ នៃការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍, ការផ្សព្វ ផ្សាយកសិកម្មដោយមានការចូលរួម និងការកែលំអការដាំដុះតាមរយៈការពិសោធន៍ត្រូវបានអនុវត្តក្នុងតំបន់ដូច ខាងក្រោម:

| សកម្មភាព | តំបន់ |
|---|---|
| (ក) ការគ្រប់គ្រងការស្រោចស្រពដោយ មានការចូលរួម និងកិច្ចអភិវឌ្ឍន៍ | ប្រព័ន្ធធារាសាស្ត្រព្រៃរបសងស្ថិតក្នុងភូមិបន្ទាស្អិត<br>ប្រព័ន្ធធារាសាស្ត្រអូរខ្វាយស្ថិតក្នុងភូមិមហាលាភ<br>ប្រព័ន្ធធារាសាស្ត្រតាការស្ថិតក្នុងភូមិមហាលំពែងទី១ និង ភូមិមហាលំពែងទី២ |
| (ខ) ការផ្សព្វផ្សាយកសិកម្មដោយ មាន ការចូលរួម | ភូមិមហាលាភ |
| (គ) ការកែលំអការដាំដុះតាមរយៈ ការពិសោធន៍ | ភូមិបន្ទាស្អិត |

## ជំពូក គ២-២: សកម្មភាពការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍ

### (១៦) សកម្មភាពអនុវត្តសម្រាប់កែលំអ (គ២-២.៥)

ដោយពិនិត្យលើលក្ខខ័ណ្ឌកសិកម្ម និងដោយយោងតាមសកម្មភាពកែលំអក្នុងតំបន់ ១ សកម្មភាព ដូចខាងក្រោមត្រូវបានយកមកអនុវត្តៈ

- អនុវត្តការរៀបចំផែនទីកាន់កាប់ដីជំហានដំបូង
- អនុវត្តការរៀបចំផែនទីប្រើប្រាស់ទឹក
- អនុវត្តការបង្កើត ស.ក.ប.ទ
- អនុវត្តការកំណត់សមត្ថភាពផ្ទុកទឹករបស់អាងទឹក
- អនុវត្តរៀបចំផែនការសេវាផ្គត់ផ្គង់ទឹក
- អនុវត្តវគ្គបណ្តុះបណ្តាលការគ្រប់គ្រងទឹក

### (១៧) អនុវត្តការរៀបចំផែនទីកាន់កាប់ដីជំហានដំបូង (គ២-២.៥.២.១)

ដើម្បីកំណត់កសិករម្ចាស់ស្រែ និងទំហំស្រែរបស់កសិករ ផែនទីកាន់កាប់ដីជំហានដំបូងត្រូវបាន រៀបចំសម្រាប់ ៣ ប្រព័ន្ធដោយប្រើប្រាស់ឧបករណ៍GPS និង GIS ។ ផ្ទៃដី និងចំនួនម្ចាស់ស្រែដែលបាន កំណត់មានដូចខាងក្រោម:

| ឈ្មោះប្រព័ន្ធធារាសាស្ត្រ | ផ្ទៃដីសរុប | ចំនួនកសិករ |
|---|---|---|
| ព្រៃរបង | 44.58 ha | 73 |
| ព្រៃខ្វាយ | 39.41 ha | 73 |
| តាការ | 59.73 ha | 187 |

### (១៨) សកម្មភាពរៀបចំផែនទីប្រើប្រាស់ទឹក (គ២-២.៥.២.២)

ដើម្បីបញ្ជាក់ពីស្ថានភាពប្រឡាយ និងរបៀបផ្គត់ផ្គង់ទឹក ផែនទីប្រើប្រាស់ទឹកត្រូវបានរៀបចំសម្រាប់ ប្រព័ន្ធចំនួន ០៣។ លក្ខណៈនៃប្រព័ន្ធនិមួយៗដែលបង្ហាញលើផែនទីមានដូចខាងក្រោម:

| ប្រព័ន្ធ | ប្រឡាយ | | | | សំណង់នានា | របៀបផ្គត់ផ្គង់ទឹក | | |
|---|---|---|---|---|---|---|---|---|
| | ប្រភេទ | ស្តាំ | កណ្តាល | ឆ្វេង | | ដោយ បង្ហៀរ | ម៉ាស៊ីនបូមទឹក | មធ្យោបាយ ទាំងពីរ |
| ព្រៃរបង | ដី | 1.9 km | - | 0.6 km | សំណង់នាំទឹក (1), ក្លាវវាស់ទឹក (1) | 42.93 | 1.65 | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ព្រៃខ្លាយ | ដី | 0.4 km | - | 1.1 km | សំណង់នាំទឹក (2), ក្លោងវាស់ទឹក (2) | 29.79 | 3.02 | 6.60 |
| តាការ | ដី | 0.7 km | 0.1 km | 0.7 km | សំណង់នាំទឹក (2), ក្លោងវាស់ទឹក (2) និងលូទឹក (1) | 59.73 | - | - |

**(១៩) សកម្មភាពរៀបចំបង្កើត ស.ក.ប.ទ (គ២-២.៥.២.៣)**

ក្រុមគ្រប់គ្រងទឹកដែលមានស្រាប់នៅតាមប្រព័ន្ធនិមួយៗ ធ្វើការគ្រប់គ្រងការចែកចាយទឹកពីអាង ទឹក។ ស.ក.ប.ទ ចាំបាច់ណាស់សម្រាប់ការងារនេះ ដើម្បីអនុវត្តឱ្យបានសមរម្យនូវការគ្រប់គ្រង និងប្រើប្រាស់ ប្រព័ន្ធធារាសាស្ត្រ។ សកម្មភាពដែលបានអនុវត្តកន្លងមកក្នុងការបង្កើត ស.ក.ប.ទ រួមមាន ១) ជ្រើសរើស សមាជិកគណៈកម្មាធិការ និង ២) រៀបចំបទបញ្ជាផ្ទៃក្នុង។

**(២០) សកម្មភាពបញ្ជាក់សមត្ថភាពស្តុកទឹករបស់អាងទឹក (គ២-២.៥.២.៤)**

មន្ទីរធនធានទឹក និងឧតុនិយម ក្រោមការដឹកនាំរបស់ក្រុមសិក្សាជប៉ុន បានអនុវត្តនូវការសិក្សាឋានលេខាបែបសាមញ្ញចំពោះអាងទឹកទាំងនោះ ដោយប្រើឧបករណ៍ GPS, ឧបករណ៍វាស់ស្ទង់, ប៉ូល និងខ្សែ ម៉ែត្រ។ ក្រោយពីការសិក្សាឋានលេខា លទ្ធផលបង្ហាញថា មាឌទឹកក្នុងអាងមានបរិមាណចំនួន ៥៣,០០០ ម៣ សម្រាប់អាងព្រៃរបង, ៤០,០០០ ម៣ សម្រាប់អាងព្រៃខ្លាយ, ១៧០,០០០ ម៣ សម្រាប់អាងតាការ។ ផ្តើមពីលទ្ធផលនេះ បង្ហាញថាអាងទឹកទាំងបីនេះ ពុំមានលទ្ធភាពស្តុកទឹកគ្រប់គ្រាន់សម្រាប់បម្រើការស្រោច ស្រពឡើយ។

**(២១) សកម្មភាពរៀបចំផែនការស្រោចស្រព (គ២-២.៥.២.៥)**

ស.ក.ប.ទ ត្រូវតែរៀបចំផែនការសេវាស្រោចស្រពក្រោមការគាំទ្រពី មន្ទីរធនធានទឹក និងឧតុនិយម។ ដោយសារ ស.ក.ប.ទ ទើបតែបង្កើត សហគមន៍នេះពុំមានសមត្ថភាពក្នុងការរៀបចំផែនការនេះឡើយ។ មន្ទីរ ធនធានទឹក និងឧតុនិយម ដោយមានការពិគ្រោះយោបល់ជាមួយក្រុមសិក្សាជប៉ុន បានជួយរៀបចំផែនការ សេវាស្រោចស្រពជូន **ស.ក.ប.ទ**។

**(២២) សកម្មភាពបណ្តុះបណ្តាលការគ្រប់គ្រងទឹក (គ២-២.៥.២.៦)**

ផ្អែកលើផែនការសេវាស្រោចស្រព ស.ក.ប.ទ ត្រូវតែបែងចែកទឹកពីអាងទឹក ទៅតាមប្រឡាយនានា។ មន្ទីរធនធានទឹក និងឧតុនិយម បានពន្យល់ដល់ ស.ក.ប.ទ អំពីការបិទបើកទ្វារទឹក ត្រូវពិនិត្យក្លោងវាស់ទឹក ដែលបង្ហាញពីកម្រិតទឹកនៅក្នុងអាងទឹក។

## ជំពូក គ២-៣: សកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

**(២៣) សកម្មភាពអនុវត្តសម្រាប់ការកែលំអ (គ២-៣.៥)**

**(ក) ផ្សព្វផ្សាយ SRI ពីកសិករមួយទៅកសិករមួយទៀត (គ២-៣.៥.៣)**

នៅក្នុងការដឹកនាំដំបូង កសិករត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យអនុវត្តប្រព័ន្ធប្រពលវប្បកម្មស្រូវ ដូចដែលបានអនុវត្តនៅក្នុងតំបន់ ១។ កសិករ ៥២ រូប បានចូលរួមក្នុងកិច្ចប្រជុំ។ លទ្ធផលទទួលបានរួមមាន កសិករចំនួន ០២ រូប ស្ម័គ្រចិត្តធ្វើជាកសិករពិសោធន៍ និងចូលរួមសកម្មភាពតាមដាន។ ការងារផ្សព្វផ្សាយ SRI ដែលបានបញ្ចប់មានដូចខាងក្រោម:

- ទស្សនៈកិច្ចសិក្សានៅភូមិអន្លង់រវៀង និងស្តុកក្បាស ក្នុងស្រុកបរិបូណ៌ និងស្រុករលាផ្អៀរ ខេត្ត កំពង់ឆ្នាំងដើម្បីរៀនសូត្រអំពីប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ។ កសិករ ០១ រូប មកពីតំបន់ ៣ ចូល រួមទស្សនៈកិច្ចសិក្សានេះ។
- ការបណ្តុះបណ្តាលក្រុមកសិករតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយកសិករ ពិសោធន៍ក្នុង ០៣ តំបន់ (តំបន់ ១, តំបន់ ៣ និងតំបន់ ៤)
- ទ្រទ្រង់ និងតាមដានកសិករពិសោធន៍ស្តីពីដំណោះស្រាយបញ្ហាដែលជួបប្រទះ, ការជ្រើសរើស ពូជស្រូវល្អ និងប្រមូលទិន្នន័យ។

- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន កសិករដែលបានអនុវត្ត SRI នៅខែ មករា ឆ្នាំ ២០០៨ មានចំនួន ៤១ នាក់ ស្មើនិង ៨០% នៃផែនការដែលមានចំនួន ៥០ នាក់។

### (ខ) ការផ្សព្វផ្សាយការចិញ្ចឹមមាន់ពីកសិករមួយទៅកសិករមួយទៀត (គ២-៣.៥.៤)

វគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ត្រូវបានអនុវត្តដូចខាងក្រោមៈ

- ទស្សនៈកិច្ចសិក្សានៅភូមិអន្លង់រវៀង និងស្តុកក្បាស ក្នុងស្រុកបរិបូណ៌ និងស្រុករលាផ្អៀរ ខេត្តកំពង់ឆ្នាំងដើម្បីរៀនសូត្រអំពីការចិញ្ចឹមមាន់។
- ការបណ្តុះបណ្តាលតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

សកម្មភាពទាំងនេះ ត្រូវបានអនុវត្តសម្រាប់ជួយដល់កសិករ ហើយកសិករខ្លះមានចំណាប់អារម្មណ៍ ខ្លាំងក្នុងការចិញ្ចឹមមាន់បែបបរិស្ថាននេះ ក៏ប៉ុន្តែ ពុំទាន់ចាប់ផ្តើមសកម្មភាពនៅក្នុងខែ មករា ឆ្នាំ ២០០៨ នេះ។

### (គ) ពង្រឹងក្រុមកសិករ (គ២-៣.៥.៥)

សកម្មភាពរបស់ក្រុមកសិករត្រូវបានអនុវត្តតាមវិធីដូចខាងក្រោមៈ

- ទស្សនៈកិច្ចសិក្សា (សិក្ខាកាមបានពិភាក្សាជាមួយក្រុមកសិករ នៅក្នុងទស្សនៈកិច្ចសិក្សាអំពី ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ និងការចិញ្ចឹមមាន់)។
- ការបណ្តុះបណ្តាលតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន កសិករ ០៣ ក្រុម បានរៀបចំជាក្រុមសន្សំសំចៃ ហើយបាន ប្រមូលថវិកាចំនួន ១,៨២៦,៩០០ រៀល នៅក្នុងខែ មករា ឆ្នាំ ២០០៨។

## ជំពូក គ២-៤: សកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍

### (២៤) សាកល្បងផ្សៀងផ្ទាត់ (គ២-៤.៣.១, គ២-៤.៥, គ២-៤.៥.៦)

ទិន្នផលរបស់ស្រែផ្ទៀងផ្ទាត់ត្រូវបានបង្ហាញនៅក្នុងតារាងប្រៀបធៀបដូចខាងក្រោមៈ

**ការប្រៀបធៀបទិន្នផលជាមួយទិន្នផលគ្រោងក្នុងផែនការមេ (ត/ហត)**

| ចំណាត់ថ្នាក់ពូជ | ពូជ | លេខស្រែ | ទិន្នផលគ្រោងក្នុងផែនការមេ (ត/ហត) | ទិន្នផលមធ្យម ក្នុងឆ្នាំ ២០០៦ /០៧ (ត/ហត) | ភាពខុសគ្នា (ត/ហត) |
|---|---|---|---|---|---|
| ពូជមធ្យម | រាំងជ័យ | លេខ ១ | 2.8 | 2.8 | - |
| | រាំងជ័យ | លេខ ២ | 2.8 | 3.0 | +0.2 |
| | រាំងជ័យ | លេខ ៣ | 2.8 | 3.1 | +0.3 |
| | ចុងក្រមួន | លេខ ៤ | 2.8 | 3.1 | +0.3 |
| មធ្យម | | | 2.8 | 3.0 | +0.2 |
| ស្រែកសិករ ១/ | ចុងក្រមួន | ស្រែ ២ | - | 2.1 | - |

*ទិន្នផលគ្រោង: ទិន្នផលគ្រោងក្នុងផែនការមេ*

*១/:លទ្ធផលនៃការអង្កេតដំណាំស្រូវលើផ្ទៃដី ២មX ២ម របស់ស្រែបង្ហាញថាការលូតលាស់មធ្យមប្រហាក់ប្រហែល និង ស្រែផ្ទៀងផ្ទាត់*

លទ្ធផលក្នុងតារាងបង្ហាញថា ទិន្នផលជាមធ្យមនៃស្រែផ្ទៀងផ្ទាត់មានកំរិតខ្ពស់ជាង ឬស្មើនិង ទិន្នផលគ្រោងនៅក្នុងផែនការមេ។

### (២៥) សាកល្បងភាពបន្សាំខ្នាតតូច (គ២-៤.៣.២, គ២-៤.៦, គ២-៤.៦.៤)

ការសាកល្បងបន្សាំពូជស្រូវមធ្យមរួមមាន ១) ការសាកល្បងពូជ, ២) ដង់ស៊ីតេដំណាំ, ៣) របៀប ដាំដុះ និងអាត្រាពូជ, ៤)សាបផ្ទាល់, ៥)ថ្នាលស្ងួត។ លទ្ធផលនៃការធ្វើពិសោធន៍ទាំងនេះមានដូចខាងក្រោមៈ

**លទ្ធផលនៃការសាកល្បងសម្រាប់ពូជស្រូវមធ្យមក្នុងតំបន់ ៣**

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលស្រូវ |
|---|---|---|
| ការសាកល្បងពូជ | ផ្ការំចង់ | 3.4 t/ha |
| | ផ្ការំដួល | 4.1 t/ha |
| | សែនពិដោរ | 4.5 t/ha |
| | រាំងជ័យ | 4.6 t/ha |
| | ចុងក្រមួន | 4.0 t/ha |
| | នាងអំ | 4.7 t/ha |
| ដង់ស៊ីតេដំណាំ (រាំងជ័យ) | 20 x 20 cm | 3.5 t/ha |
| | 25 x 25 cm | 3.6 t/ha |
| | 30 x 30 cm | 3.2 t/ha |
| របៀបដាំដុះ (រាំងជ័យ) | ១ ដើម/ទូល | 3.9 t/ha |
| | ២ ដើម/ទូល | 3.2 t/ha |
| | ៣ ដើម/ទូល | 3.7 t/ha |
| | ៤ ដើម/ទូល | 3.7 t/ha |
| | ៥ ដើម/ទូល | 3.6 t/ha |
| សាបផ្ទាល់ | ផ្ការំដួល | 3.9 t/ha |

*ការអង្កេតដំណាំ: សំណាកមួយសម្រាប់មួយប្រព្រឹត្តកម្ម, និងសំណាកចម្រុះសម្រាប់ផ្ទៃដី ១ម$^2$ (១៦ ទូល)*

### (២៦) អង្កេតលើភាពទទួលបានរបស់កសិករ (គ២-៤.៣.៣, គ២-៤.៧, គ២-៤.៧.៣)

គ្រប់អ្នកធ្វើបទបង្ហាញនៅក្នុងតំបន់គម្រោងបានវាយតម្លៃថា "ល្អ" ឬ "អាត្រា សមរម្យ" ចំពោះ ការកំណត់យកការអនុវត្តការដាំដុះដំណាំ។ ការសំភាសន៍ជាមួយក្រុមកសិករបានបង្ហាញថា បំណងរបស់ កសិករក្នុងការកែលំអផលិតភាពស្រូវតាមរយៈការអនុវត្តកែលំអរបៀបដាំដុះ មានកំរិតខ្ពស់នៅក្នុងតំបន់ គម្រោងដោយសារតំបន់នេះជាតំបន់ងាយជួបប្រទះនឹងភាពរាំងស្ងួត ហើយការរស់នៅរបស់ប្រជាជនមានការ លំបាក។ ការងារនេះ ក៏បានបង្ហាញផងដែរថា របៀបដាំដុះដូចជា កាត់បន្ថយចំនួនដើម/ទូល, ការដាំដើមស្រូវ ក្មេង និងអាត្រាពូជកាត់បន្ថយ មានភាពងាយស្រួលក្នុងការទទួលយកដោយកសិករ និងត្រូវបានផ្សព្វផ្សាយ យ៉ាងរហ័សដោយអនុវត្តការដឹកនាំ និងបទបង្ហាញទាន់ពេល។

## គម្រោងទី ៣: គម្រោងសាកល្បងស្តីពីការកែលំអកសិកម្មពឹងទឹកភ្លៀង (តំបន់៤)

## ជំពូក គ៣-១: សកម្មភាពផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

### (២៧) សកម្មភាពអនុវត្តសម្រាប់ការកែលំអ (គ៣-២.៥)

#### (ក) ផ្សព្វផ្សាយ ប,វ,ស ដែលប្រើប្រាស់កត្តាផលិតកម្មទាបពីកសិករមួយទៅកសិករមួយទៀត (គ៣-២.៥.២)

កសិករចំនួន ១១ រូប ស្ម័គ្រចិត្តធ្វើជាកសិករពិសោធន៍ និងចូលរួមសកម្មភាពតាមដាន។ ការងារផ្សព្វផ្សាយ SRI ដែលបានបញ្ចប់មានដូចខាងក្រោម:

- ទស្សនៈកិច្ចសិក្សាទៅខេត្តកំពង់ចាមដើម្បីរៀនសូត្រអំពីប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ។ កសិករ ០១ រូប មកពីតំបន់ ៣ ចូលរួមទស្សនៈកិច្ចសិក្សានេះ។
- ការបណ្តុះបណ្តាលក្រុមកសិករតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយកសិករ ពិសោធន៍ក្នុង ០៣ តំបន់ (តំបន់ ១, តំបន់ ៣ និងតំបន់ ៤)
- ទ្រទ្រង់ និងតាមដានកសិករពិសោធន៍ស្តីពីដំណោះស្រាយបញ្ហាដែលជួបប្រទះ, ការជ្រើសរើស ពូជស្រូវល្អ និងប្រមូលទិន្នន័យ។
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន កសិករដែលបានអនុវត្ត SRI នៅខែ មករា ឆ្នាំ ២០០៨ មានចំនួន ៤៦ នាក់ ស្មើនិង ៩០% នៃផែនការដែលមានចំនួន ៥០ នាក់។

### (ខ) ការផ្សព្វផ្សាយការចិញ្ចឹមមាន់ពីកសិករមួយទៅកសិករមួយទៀត (គ៣-២.៥.៣)

វគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ត្រូវបានអនុវត្តដូចខាងក្រោម:

- ទស្សនៈកិច្ចសិក្សានៅភូមិអន្លង់រវៀង និងស្តុកក្បាស ក្នុងស្រុកបរិបូណ៌ និងស្រុករលាផ្អៀរ ខេត្តកំពង់ឆ្នាំងដើម្បីរៀនសូត្រអំពីការចិញ្ចឹមមាន់។
- ការបណ្តុះបណ្តាលតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

កសិករចំនួន ០៩ រូប បានចាប់ផ្តើមសកម្មភាពចិញ្ចឹមមាន់នៅក្នុងខែ មករា ឆ្នាំ ២០០៨ នេះ។

### (គ) ពង្រឹងក្រុមកសិករ (គ៣-២.៥.៤)

សកម្មភាពរបស់ក្រុមកសិករត្រូវបានអនុវត្តតាមវិធីដូចខាងក្រោម:

- ទស្សនៈកិច្ចសិក្សា (សិក្ខាកាមបានពិភាក្សាជាមួយក្រុមកសិករ នៅក្នុងទស្សនៈកិច្ចសិក្សាអំពី ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ និងការចិញ្ចឹមមាន់)។
- ការបណ្តុះបណ្តាលតាមភូមិ
- បណ្តុះបណ្តាលពីភូមិមួយទៅភូមិមួយទៀត
- កិច្ចប្រជុំទូទៅរបស់ភូមិដើម្បីក្តាប់បាននូវលទ្ធផលសកម្មភាព

លទ្ធផលដែលសម្រេចបានរួមមាន កសិករ ០៥ ក្រុម បានរៀបចំជាក្រុមសន្សំសំចៃ ហើយបាន ប្រមូលថវិកាចំនួន ១,០១១,៨០០ រៀល នៅក្នុងខែ មករា ឆ្នាំ ២០០៨។

## ជំពូក គ៣-៣: សកម្មភាពកែលំអការអនុវត្តការដាំដុះដោយពិសោធន៍

### (២៨) សាកល្បងផ្ទៀងផ្ទាត់ (គ៣-៣.៣.១, គ៣-៣.៤, គ៣-៣.៥, គ៣-៣.៥.៥)

ទិន្នផលស្រូវដែលទទួលបានស្រែផ្ទៀងផ្ទាត់ ០៥ មានបង្ហាញនៅក្នុងតារាងប្រៀបធៀបខាងក្រោម:

**ការប្រៀបធៀបទិន្នផលជាមួយទិន្នផលគ្រោងក្នុងផែនការមេ**

| ចំណាត់ថ្នាក់ពូជ | ពូជ | លេខស្រែ | ទិន្នផលគ្រោង | ទិន្នផលផ្ទៀង ផ្ទាត់ | ភាពខុសគ្នា |
|---|---|---|---|---|---|
| ពូជមធ្យម | រាំងជ័យ | លេខ ១ | 2.0 | 3.3 | +1.3 |
| | ឆ្មាព្រហ្ម | លេខ ២ | 2.0 | 3.2 | +1.2 |
| | ឆ្មាព្រហ្ម | លេខ ៣ | 2.0 | 2.9 | +0.9 |
| មធ្យម | | | 2.0 | 3.1 | +1.1 |
| ស្រែកាសិករ ១/ | ចុងក្រមួន | ស្រែ ០៣ | - | 2.3 | - |
| មធ្យម | | | ២.៨ | ២.២ | +0.២ |

*១/:លទ្ធផលនៃការអង្កេតដំណាំស្រូវលើផ្ទៃដី ២មX ២ម របស់ស្រែបង្ហាញថាការលូតលាស់មធ្យមប្រហាក់ប្រហែល និង ស្រែផ្ទៀងផ្ទាត់*

លទ្ធផលក្នុងតារាងបង្ហាញថា ទិន្នផលជាមធ្យមនៃស្រែផ្ទៀងផ្ទាត់មានកំរិតខ្ពស់ជាងទិន្នផលគ្រោង នៅក្នុងផែនការមេ។

## (២៩) សាកល្បងភាពបន្សាំខ្នាតតូច (គ៣-៣.២, គ៣-៣.៦, គ៣-៣.៦.៤)

ការសាកល្បងបន្សាំពូជស្រូវមធ្យមរួមមាន ១) ការសាកល្បងពូជ, ២) ដង់ស៊ីតេដំណាំ, ៣) របៀប ដាំដុះ និង ៤)សាបព្រោះផ្ទាល់។ លទ្ធផលនៃការធ្វើពិសោធន៍ទាំងនេះមានដូចខាងក្រោម:

**លទ្ធផលនៃការសាកល្បងសម្រាប់ពូជស្រូវមធ្យមក្នុងតំបន់ ៤**

| ការសាកល្បង/ពូជ | ប្រព្រឹត្តកម្ម | ទិន្នផលដំណាំ | ទិន្នផលស្រូវក្នុង ស្រែទាំងមូល |
|---|---|---|---|
| ការសាកល្បងពូជ | ផ្ការំដួល | 4.2 t/ha | - |
| | រាំងជ័យ | 3.6 t/ha | 3.6 t/ha |
| | ឆ្មាព្រហ្ម | 3.6 t/ha | - |
| | នាងអំ | 5.3 t/ha | - |
| ដង់ស៊ីតេដំណាំ (រាំងជ័យ) | 20 x 20 cm | 3.1 t/ha | 3.2 t/ha |
| | 25 x 25 cm | 4.1 t/ha | 3.1 t/ha |
| | 30 x 30 cm | 2.6 t/ha | 3.4 t/h |
| របៀបដាំដុះ (រាំងជ័យ) | ១ ដើម/ទូល | 4.3 t/ha | 2.9 t/ha |
| | ២ ដើម/ទូល | 3.9 t/ha | 3.0 t/ha |
| | ៣ ដើម/ទូល | 3.4 t/ha | 3.6 t/ha |
| | ៤ ដើម/ទូល | 3.2 t/ha | 2.8 t/ha |
| | ៥ ដើម/ទូល | 4.0 t/ha | 4.2 t/ha |
| សាបផ្ទាល់ | រាំងជ័យ | - | 2.0 t/ha |

*ការអង្កេតដំណាំ: សំណាកមួយសម្រាប់មួយប្រព្រឹត្តកម្ម, និងសំណាកចម្រុះសម្រាប់ផ្ទៃដី ១ម² (១៦ ទូល)*

## (៣០) អង្កេតលើភាពទទួលបានរបស់កសិករ (គ៣-៣.៣.៣, គ៣-៣.៧, គ៣-៣.៧.៣)

គ្រប់អ្នកធ្វើបទបង្ហាញនៅក្នុងតំបន់គម្រោងបានវាយតម្លៃថា "ល្អ" ឬ "អាត្រា សមរម្យ" ចំពោះ ការកំណត់យកការអនុវត្តការដាំដុះដំណាំលើកលែងតែអាត្រាពូជ និងជី។ អ្នកធ្វើបទបង្ហាញបានវាយតម្លៃជា វិជ្ជមានចំពោះការស្ទូងស្រូវមួយជួរសាមញ្ញដែលបានអនុវត្តនាពេលថ្មីៗក្នុងរដូវនេះ។ ការសម្ភាសន៍ជាមួយ សមាជិកក្រុមកសិករ បានបង្ហាញថា បំណងរបស់កសិករក្នុងការកែលំអផលិតភាពស្រូវតាមរយៈការអនុវត្ត ការកែលំអការដាំដុះមានចំនួនច្រើននៅក្នុងតំបន់គម្រោង។ នៅក្នុងតំបន់ ៤ ក៏ជានៅក្នុងតំបន់ ១ និងតំបន់ ៣ ក៏បានបង្ហាញផងដែរថា សកម្មភាពដូចជាការបន្ថយចំនួនដើមស្រូវ/ទូល, ការស្ទូងសំណាបក្មេង, ការ កាត់បន្ថយអាត្រាពូជ គឺជាការងារស្រួលទទួលយកដោយកសិករ ហើយត្រូវបានផ្សព្វផ្សាយយ៉ាងរហ័ស តាមរយៈផ្តល់ការបង្ហាញ និងការណែនាំទាន់ពេល។

## គម្រោងទី ៤: ការផ្ទេរបច្ចេកវិទ្យា និងការផ្លាស់ប្តូរបទពិសោធន៍ក្នុងគម្រោងសាកល្បង

### (៣១) ការផ្ទេរបច្ចេកវិទ្យាដល់មន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម (គ៤-១.២)

នៅក្នុងរយៈពេលនៃគម្រោងសាកល្បង និងនៅក្នុងរដូវទី ២ បន្តពីរដូវទី១ បច្ចេកវិទ្យាដូចខាងក្រោម ត្រូវបានផ្ទេរទៅឱ្យមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម ពីក្រុមសិក្សាជប៉ុន។

- ការប្រើប្រាស់ឧបករណ៍ GPS និងការរៀបចំផែនទីដោយ GIS
- អនុវត្តវិធីសាស្ត្រស្រោចស្រពឆ្លាស់
- រៀបចំអនុគមន៍ H-Q សម្រាប់សំណង់ទ្វារទឹកនៅប្រឡាយ RT-2
- ការកំណត់ទំហំប្រឡាយបញ្ចូលស្រែ
- អង្កេតសាមញ្ញសម្រាប់រៀបចំអនុគមន៍ H-V សម្រាប់អាងទឹក
- ចេងក្រងក្រុមប្រើប្រាស់ទឹក និងអនុក្រម ស.ក.ប.ក
- ផ្តល់សិទ្ធដល់ប្រធានក្រុមប្រើប្រាស់ទឹក
- វិធីសាស្ត្រក្នុងការប្រមូលថ្លៃសេវាផ្តល់ទឹក

### (៣២) ការផ្ទេរបច្ចេកវិទ្យាដល់មន្ត្រីមន្ទីរកសិកម្ម (គ៤-១.៣)

នៅក្នុងរយៈពេលនៃគម្រោងសាកល្បង និងនៅក្នុងរដូវទី ២ បន្តពីរដូវទី១ បច្ចេកវិទ្យាដូចខាងក្រោម ត្រូវបានផ្ទេរទៅឱ្យមន្ត្រីមន្ទីរកសិកម្ម ពីក្រុមសិក្សាជប៉ុន។

- សកម្មភាពកែលំអការដាំដុះ: សិក្សាចាប់ពីការរៀបចំថ្នាលសំណាបរហូតដល់ការស្ទូង និងប្រើប្រាស់ជី
- ការគ្រប់គ្រងទឹកក្នុងស្រែ
- ការដាំដុះដំណាំដីទួលនៅចុងរដូវវស្សា
- ការជ្រើសរើសពូជជាមួយទឹកអំបិល
- អាត្រាពូជ និងការសាបព្រោះ
- ការសាកល្បងពូជ
- ការច្រូតកាត់ និងការអង្កេតទិន្នផល
- អង្កេតភាពទទួលបានរបស់កសិករ

### (៣៣) មេរៀនដែលបានសិក្សា (គ៤-២.២)

មេរៀនដែលទទួលបានពីសកម្មភាពគម្រោងសាកល្បងបានអនុវត្ត មានដូចខាងក្រោម:

#### ១) ការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍

**<u>យុទ្ធសាស្ត្រ -១ : សិក្សាពីការអនុវត្តរបស់កសិករល្អក្នុងប្រទេសកម្ពុជា</u>**

- អនុវត្តនីតិវិធីដែលទទួលបានជោគជ័យក្នុងការប្រមូលថ្លៃទឹកទៅក្នុងគម្រោង ផ្សេងទៀត

**<u>យុទ្ធសាស្ត្រ -២ : ការប្រតិបត្តិគម្រោងដោយសហការជាមួយកសិករ-រដ្ឋាភិបាល-NGO</u>**

- ចងក្រងកសិករ-រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដើម្បីប្រមូលថ្លៃទឹក

**<u>យុទ្ធសាស្ត្រ -៣ : ភ្នាក់ងាររដ្ឋាភិបាលអនុវត្តសកម្មភាពពាក់ព័ន្ធនិងធារាសាស្ត្រកសិកម្ម</u>**

- តម្រូវការនូវកិច្ចសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីរកសិកម្ម ក្នុងការផ្សព្វផ្សាយការគ្រប់គ្រងទឹកឱ្យបានសមស្រប
- តម្រូវឱ្យមានកិច្ចប្រជុំរួមដើម្បីបង្កើតឱ្យមានកិច្ចសម្របសម្រួលជាមួយមន្ទីរធន ធានទឹក និងឧតុនិយម និងមន្ទីរកសិកម្ម

<u>ផ្សេងៗ</u>

- ខ្វះចំណេះដឹងជាមូលដ្ឋាន និងបទពិសោធន៍ក្នុងការងារស្រោចស្រពរបស់មន្ត្រី ធនធានទឹក និងឧតុនិយម
- មានចំណង់ចំណូលចិត្តខ្លាំងរបស់មន្ត្រីធនធានទឹក និងឧតុនិយម ក្នុងការបង្កើន ចំណេះដឹង
- ក្តីសង្ឃឹមខ្ពស់ចំពោះកសិករនៅខ្សែទឹកផ្នែកខាងក្រោមចំពោះការគ្រប់គ្រងទឹកឱ្យ បានសមស្រប
- តម្រូវឱ្យមានការចងក្រងក្រុមប្រើប្រាស់ទឹកនៅតាមប្រឡាយ
- តម្រូវឱ្យលប់បំបាត់ចោលនូវសារាចរមិនល្អនៅក្នុសកម្មភាព ស.ក.ប.ទ
- អនុវត្តការប្រមូលថ្លៃទឹកនៅតាមភូមិ
- ប្រសិទ្ធភាពនៃការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន
- តម្រូវការឧបករណ៍វាស់វែងសាមញ្ញ
- តម្រូវឱ្យមានការពិភាក្សាផ្តោតលើអ្វីដែលកសិករអាចធ្វើដោយខ្លួនឯង
- តម្រូវឱ្យមានការពង្រឹងកិច្ចសម្របសម្រួលរវាងថ្នាក់ដឹកនាំក្រុមប្រើប្រាស់ទឹក និង ស.ក.ប.ក
- បង្កើនការយល់ដឹងរបស់ ស.ក.ប.ទ
- ទទួលស្គាល់សារៈសំខាន់នៃតួនាទីរបស់មន្ទីរធនធានទឹក និងឧតុនិយមក្នុងការទ្រ ទ្រង់ដល់ ស.ក.ប.ទ

## ២) ការផ្សព្វផ្សាយកសិកម្មដោយមានការចូលរួម

**<u>យុទ្ធសាស្ត្រ -១ : សិក្សាពីកសិករដែលមានបទពិសោធន៍ល្អនៅក្នុងកម្ពុជា</u>**

- ចូលរួមរបស់មន្ត្រីរដ្ឋាភិបាលក្នុងដំណើរទស្សនៈកិច្ចសិក្សានៅក្នុងគម្រោងដែល ទទួលបានជោគជ័យ
- ការលំបាកក្នុងការផ្សព្វផ្សាយនូវសណើរវិធីប្រឆាំងជាមួយការរងគ្រោះដោយសត្វល្អិត និងកណ្តុរ

**<u>យុទ្ធសាស្ត្រ -២ : ការប្រតិបត្តគម្រោងដោយសហការជាមួយកសិករ-រដ្ឋាភិបាល-NGO</u>**

- ក្តីសង្ឃឹមលើការងារតាមដានរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល

**<u>យុទ្ធសាស្ត្រ -៤ : ការប្រើប្រាស់អប្បបរមានូវសំភារៈ និងឧបករណ៍របស់កសិករ</u>**

- ប្រសិទ្ធភាពនៃការប្រើប្រាស់អប្បបរមានូវសំភារៈ និងឧបករណ៍របស់កសិករ

**<u>យុទ្ធសាស្ត្រ -៥ : ការណែនាំការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ</u>**

- ការជះឥទ្ធិពលខ្ពស់ដោយការបង្ហាញរបស់កសិករដែលមានបទពិសោធន៍ល្អ

<u>ផ្សេងៗ</u>

- ការចាប់អារម្មណ៍ខ្ពស់ចំពោះការដាំដុះស្រូវដោយប្រព័ន្ធប្រពលវប្បកម្ម និងប្រព័ន្ធ ប្រពៃណីនៅក្នុងស្រែដូចគ្នា
- ប្រសិទ្ធភាពនៃការតាមដាន និងទ្រទ្រង់ទាន់ពេលវេលារបស់សហករ

## ៣) ការពិសោធន៍លើការកែលំអការអនុវត្តការដាំដុះ

**<u>យុទ្ធសាស្ត្រ -៣ : ភ្នាក់ងាររដ្ឋាភិបាលអនុវត្តសកម្មភាពពាក់ព័ន្ធនិងធារាសាស្ត្រកសិកម្ម</u>**

- តម្រូវការនូវកិច្ចសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីរកសិកម្ម ក្នុងការផ្សព្វផ្សាយការគ្រប់គ្រងទឹកឱ្យបានសមស្រប

**<u>យុទ្ធសាស្ត្រ -៥ : ការណែនាំការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ</u>**

- ការលំបាកក្នុងការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ

<u>ផ្សេងៗ</u>

- កែលំអសកម្មភាពដែលងាយស្រួលអនុវត្ត
- ផ្សព្វផ្សាយការកែលំអការដាំដុះក្នុងតំបន់ ៣

- ចំណេះដឹងកសិករលើការប្រើប្រាស់ជីសរីរាង្គ
- ប្រសិទ្ធភាពនៃការផ្តល់ពូជចំពោះការផ្លាស់ប្តូរពូជ
- សាកល្បងការប្រតិបត្តិរបស់កសិករ
- កំរិតជំណាញនៅមានកំរិតរបស់មន្ត្រីមន្ទីរកសិកម្ម
- សកម្មភាពផ្សព្វផ្សាយនៅតាមមូលដ្ឋាននៅមានកំរិតទាប

## ផ្នែក ឃៈ ការវាយតម្លៃគម្រោងសាកល្បង

### (១) គោលបំណងនៃការវាយតម្លៃ (ឃ.១)

នៅចំណុចចុងក្រោយនៃគម្រោងសាកល្បង គម្រោងសាកល្បងត្រូវការវាយតម្លៃយ៉ាងទូលំទូលាយថាតើគោលបំណងនៃគម្រោងសាកល្បងនិមួយៗទទួលបានគោលដៅគ្រោង ឬក៏មិនទទួលបាន។ លទ្ធផលនៃការវាយតម្លៃត្រូវបានប្រើប្រាស់ជាប្រភពព័ត៌មានសម្រាប់កាត់ក្តីថាតើគម្រោងសាកល្បងមាននិរន្តរភាព ឬឆ្លើយតបនិង គោលដៅឬទេ។

### (២) ក្រុមខំណ្ឌនៃការវាយតម្លៃ (ឃ.២)

ការវាយតម្លៃត្រូវបានអនុវត្ត ដោយយោងតាមតាមសូចាករដែលអាចវាស់វែងបានចែងនៅក្នុងម៉ាទ្រិក គ្រោងរបស់គម្រោង។ សំណើទិន្នន័យត្រូវបានប្រមូលដោយ ១) ទស្សនាវត្តីអក្សរសាស្ត្រ, ២) ការសម្ភាសន៍ជាមួយ ក្រុមសិក្សាជប៉ុន, ៣) សិក្ខាសាលាវាយតម្លៃដោយមានការចូលរួម និង ៤) កម្រងសំណួរអង្កេត

### (៣) លទ្ធផលនៃការវាយតម្លៃ (ឃ.៥)

ការវាយតម្លៃត្រូវបានអនុវត្តផ្អែកលើលក្ខណៈវិនិច្ឆ័យ ៥ យ៉ាង ដូចជា : ភាពទាក់ទង, ប្រសិទ្ធភាព, ផលជាទីគាប់ចិត្ត, ផលប៉ះពាល់ និងនិរន្តរភាព។ លទ្ធផលនៃការវាយតម្លៃសម្រាប់គម្រោងនិមួយៗ មានដូចខាង ក្រោមៈ

| លក្ខណៈវិនិច្ឆ័យ | គម្រោងសាកល្បងកែលំអ បច្ចេកវិជ្ជាធារាសាស្ត្រកសិកម្ម | | គម្រោងសាកល្បង កែលំអកសិកម្មពឹងទឹកភ្លៀង |
|---|---|---|---|
| | តំបន់ ១ | តំបន់ ៣ | តំបន់ ៤ |
| ១) ភាពទាក់ទង | ខ្ពស់ណាស់ | ខ្ពស់ណាស់ | ខ្ពស់ |
| ២) ប្រសិទ្ធភាព | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| ៣) ផលជាទីគាប់ចិត្ត | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| ៤) ផលប៉ះពាល់ | វិជ្ជមាន | វិជ្ជមាន/អវិជ្ជមានតិចតួច | វិជ្ជមាន |
| ៥) និរន្តរភាព | ខ្ពស់ | ខ្ពស់ | ខ្ពស់ |
| ៦) សន្និដ្ឋាន | និរន្តរភាព និងការឆ្លើយតបនៃគម្រោងត្រូវបានពិនិត្យ | និរន្តរភាព និងការឆ្លើយតបនៃគម្រោងជិតបានពិនិត្យ | និរន្តរភាព និងការឆ្លើយតបនៃគម្រោងត្រូវបាន ពិនិត្យ |
| ៧) អនុសាសន៍ | - ផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ដល់មន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម<br>- ផ្តល់សិទ្ធរៀបចំនីតិវិធីក្នុងការប្រមូលសេវាថ្លៃទឹក | -ផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ដល់មន្ទីរកសិកម្ម និង មន្ទីរធនធានទឹក និងឧតុនិយម<br>- ផ្តល់សិទ្ធវាស់វែងទំហំស្រែ | យល់អំពីវិធីសាស្ត្រ, លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍នៃការអនុវត្តប្រព័ន្ធប្រពលវប្បកម្មស្រូវដែលប្រើប្រាស់កត្តាផលិតកម្មទាប |

## (៣) អនុសាសន៍ (ឃ.៦)

### (ក) តម្រូវឱ្យមានការពង្រឹងការរៀបចំថវិកាសម្រាប់មន្ទីរខេត្ត

សកម្មភាពជាបន្តបន្ទាប់របស់កសិករឆ្ពោះទៅរកការបង្កើនផលិតភាពកសិកម្ម គឺទាមទារឱ្យមានការ គាំទ្រពីមន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម ។ ទិន្នផលដំណាំខ្ពស់ដែលទទួលបានក្នុងគម្រោង សាកល្បងអាចធានាបានដោយមានការផ្តល់គោលការណ៍នាំសមស្របនៃការគ្រប់គ្រងទឹក និងវិធីសាស្ត្រដាំដុះ ពីមន្ត្រីមកពីមន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីរកសិកម្ម។ ក៏ប៉ុន្តែ មន្ត្រីមកពីមន្ទីរទាំងពីរ ពុំមានថវិកាគ្រប់គ្រាន់សម្រាប់ផ្តល់គោលការណ៍សមស្របដល់កសិករ។ ដោយយោងតាម ទស្សនៈនយោបាយវិមជ្ឈការ រដ្ឋាភិបាល ត្រូវតែពិចារណាចំពោះបញ្ហានេះធ្វើយ៉ាងណាដើម្បីសម្រេច និងថែរក្សាឱ្យបាននូវផលិតផល កសិកម្មខ្ពស់ ដោយប្រើប្រាស់ឱ្យមានប្រសិទ្ធភាពបទពិសោធន៍ក្នុងការគ្រប់គ្រងទឹក និងវិធីសាស្ត្រដាំដុះដោយ កសិករក្រោមការគាំទ្រដោយមន្ត្រីមកពីមន្ទីរទាំងពីរ។

### (ខ) តម្រូវឱ្យមានការតាមដាន និងបន្តពង្រឹងសមត្ថភាព ស.ក.ប.ទ ពីមន្ទីរធនធានទឹក និងឧតុនិយម

តាមរយៈសកម្មភាពការគ្រប់គ្រងទឹកដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ក្នុងគម្រោងសាកល្បង ស.ក.ប.ទ អូរវែង អាចប្រមូលថ្លៃទឹកបាន ៨៦% គឺមានន័យថាកសិករដែលបានបង់ថ្លៃទឹកនេះ ជឿជាក់លើ ការសកម្មភាពគ្រប់គ្រងរបស់ **ស.ក.ប.ទ** អូរវែង។ ប្រសិនបើ **ស.ក.ប.ទ** អូរវែង មិនអាចផ្តល់ទឹកឱ្យបានស្មើ ភាព និងទាន់ពេលវេលាតាមរយៈការថែទាំសំណង់ធារាសាស្ត្រឱ្យបានសមស្របទេនោះ កសិករនឹងមិនបង់ថ្លៃ ទឹកឡើយ។ ក្នុងន័យនេះ រដូវដាំដុះបន្ទាប់នេះ មានសារៈសំខាន់ណាស់សម្រាប់ **ស.ក.ប.ទ** អូរវែង ក៏ដូចជា មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ហើយតម្លាភាពក្នុងគណនេយ្យមានសារៈសំខាន់ដែរក្នុងការ ប្រមូលសេវាថ្លៃទឹក។ តាមទស្សនៈនេះ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺត្រូវតាមដានឱ្យបាន ម៉ត់ចត់សកម្មភាពរបស់ **ស.ក.ប.ទ** អូរវែង និងទាមទារឱ្យមានការពង្រឹងសមត្ថភាពបន្ថែម។

# ក្បាលទី ៥ សិក្សាផ្នែកជលសាស្ត្រ និងការពង្រឹងសមត្ថភាពមូលដ្ឋានគ្រប់គ្រងបរិស្ថាន

## ផ្នែក ក:ព័ត៌មានទូទៅ

### (១) សិក្សាផ្នែកជលសាស្ត្រ (ក.១.៣.២)

តំបន់គោលដៅធ្លាប់បានទទួលរងនូវទឹកជំនន់ស្ទើតែរាល់ឆ្នាំ។ ទឹកជំនន់បានគំរាមកំហែងដល់ការបង្កបង្កើនផលដំណាំ ក៏ដូចជាភូមិដ្ឋាននានា។ ជាពិសេស ជំនន់ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលិតកម្មដំណាំ។ នៅក្នុងផែនការមេ គំរោងមួយ និងការសិក្សាមួយដែលពាក់ព័ន្ធនិងទិដ្ឋភាពជលសាស្ត្រត្រូវបានស្នើឡើង ជាគំរោងកែលំអសេវាទ្រទ្រង់, គំរោងពង្រឹងការ អង្កេតជលសាស្ត្រ, ការព្យាករណ៍ជំនន់ និងការសិក្សាលើភាពអាសន្ន។ សំរាប់គំរោងពង្រឹងការអង្កេតជលសាស្ត្រ ស្ថានីយ៍ វាស់ទឹកភ្លៀងចំនួន ១០ និងឧបករណ៍វាស់កំពស់ទឹកចំនួន ៥ ត្រូវបានតំឡើងថ្មីនៅក្នុងអាងទឹកស្ទឹងព្រែកត្នោត ក្នុងឆ្នាំ ២០០៥ ហើយបន្ទាប់មកបានធ្វើការអង្កេតរយៈពេលពីរឆ្នាំ (២០០៥ និង២០០៦) ដោយផ្អែកលើមូលដ្ឋានកិច្ចសន្យា។ នៅក្នុងរយៈ ពេលនៃរបាយការណ៍នេះ ការព្យាករណ៍ជំនន់ និងការសិក្សាលើភាពអាសន្ន ត្រូវបានប្រតិបត្តិ។ ការងារប្រតិបត្តិលើការ ព្យាករណ៍ជំនន់ និងការសិក្សាលើភាពអាសន្នរួមមាន: (១)សិក្សាលក្ខណះស្ទឹងព្រែកត្នោត (២)សិក្សាពីគំរូនៃការហូរចេញ (៣)ការរៀបចំច្បាប់គ្រប់គ្រងលើការប្រើប្រាស់នៃសំណង់ទ្វារទឹកតាមដងស្ទឹងព្រែកត្នោត (៤)ការរៀបចំផែនទីផ្ទៃដីលិចទឹក ដែលគួរទុកចិត្តបាន (៥)ការរៀបចំផែទីគ្រោះទឹកជំនន់ និង(៦)ការសិក្សាលើការព្យាករណ៍ជំនន់ និងប្រព័ន្ធប្រកាសភាព អាសន្ន។

### (២) ការពង្រឹងសមត្ថភាពមូលដ្ឋានលើការគ្រប់គ្រងបរិស្ថាន (ក.១.៣.៣)

បរិស្ថាន ជាបញ្ហាសំខាន់ចំពោះការអភិវឌ្ឍន៍កសិកម្មផងដែរ។ ដូចេះ នៅក្នុងផែការមេបានស្នើឡើងនូវគំរោង អភិវឌ្ឍន៍សមត្ថភាពមូលដ្ឋាននៃការគ្រប់គ្រងបរិស្ថាន និងគំរោងអភិវឌ្ឍន៍សមត្ថភាពលើការគប់គ្រងបរិស្ថាន។ នៅក្នុងអំឡុង ពេលនេះ ផ្នែកមួយនៃគំរោងអភិវឌ្ឍន៍សមត្ថភាពលើការគ្រប់គ្រងបរិស្ថានត្រូវបានអនុវត្ត។ ការងារដែលបានប្រតិបត្តិមានដូច ខាងក្រោម:

- អនុសាសន៍ចំពោះផ្នែកនានានៃការសិក្សា សំរាប់តំបន់ជុំវិញគំរោងក្នុងការអភិវឌ្ឍន៍ប្រភពទឹកថ្មី និងចំណុច សំខាន់ៗឯទៀតដែលពាក់ព័ន្ធ។
- វិធីសាស្ត្រនានាសំរាប់ការគ្រប់គ្រងបរិស្ថាន និងការពិនិត្យតាមដានលើតំបន់ដែលទទួលប្រយោជន៍ បន្ទាប់ពីការ បញ្ចប់នៃការអភិវឌ្ឍន៍ប្រភពទឹក។

## ផ្នែក ខ: ការសិក្សាផ្នែកជលសាស្ត្រ

### (១) ការសិក្សាលក្ខណៈនៃស្ទឹងព្រែកត្នោត(ខ.១.១ ទៅ ខ.១.១០)

លក្ខណៈនៃស្ទឹងព្រែកត្នោត ត្រូវបានសិក្សាដោយផ្អែកលើលទ្ធផលនៃការធ្វើឋានលេខា, ការអង្កេតលើធារទឹក និង ការពិនិត្យអង្កេតទីតាំងជាក់ស្តែង ក្នុងគោលបំណង ទទួលបានព័ត៌មាន និងទិន្នន័យមូលដ្ឋានចាំបាច់ សំរាប់រៀបចំផែនទី ផ្ទៃដីទឹកលិចដែលគួរទុកចិត្តបាន, ផែនទីគ្រោះទឹកជំនន់, គ្រប់គ្រងការប្រើប្រាស់ទ្វារទឹក, ការព្យាករណ៍ជំនន់, ប្រព័ន្ធប្រកាស អាសន្ន និងគំរូលំហូរពីទីចំណោត។ លក្ខណៈពិសេសៗរបស់ស្ទឹងព្រែកត្នោតមានដូចខាងក្រោម:

**១) ជំរាលបណ្តោយ**

| | |
|---|---|
| - ពីមាត់ស្ទឹងទៅចំណុចលេខ ៣៥.០០០ | ១/៥,១០០ |
| - ពីចំណុចលេខ ៣៥.០០០ ទៅចំណុចលេខ ៦៥.០០០ | ១/៤,១៧០ |
| - ពីចំណុចលេខ ៦៥.០០០ ទៅទ្វារទឹករលាំងជ្រៃ | ១/២,៧២០ |
| - ពីទ្វារទឹករលាំងជ្រៃ ទៅស្ពានពាមឃ្លៃ | ១/២,៧២០ |

**២) មេគុណគ្រើម** ០,០៣៥

**៣) សមត្ថភាពនាំធារទឹក**

- ពីសំណង់ស្ទាក់ទឹកមេកណ្តាលស្ទឹងទៅផ្លូវរថភ្លើង ៨០០-១,០០០ម៣/វិនាទី
- ពីផ្លូវរថភ្លើងទៅប្រលាយមេ ៦៤ ៣០០-៨០០ ម៣/វិនាទី
- ពីប្រលាយមេ ៦៤ ទៅទ្វារទឹករលាំងជ្រៃ ៨០០-១,២០០ ម៣/វិនាទី
- ពីទ្វារទឹករលាំងជ្រៃទៅស្ពានពាមឃ្លៃ ១០០-១,៦០០ ម៣/វិនាទី

## (២) ការសិក្សាលើគំរូលំហូរពីទីចោត (ខ.២.១ ទៅ ខ.២.៥)

គំរូលំហូរពីទីចោតនៃស្ទឹងព្រែកត្នោតត្រូវបានសិក្សាដោយប្រើប្រាស់វិធីសាស្ត្រតួនាទីស្តុកទឹក។ មេគុណស្មេរ ចាំបាច់ ណាស់សំរាប់គំរូ ត្រូវបានកំណត់ដោយផ្អែកលើការអង្កេតជាក់ស្តែងនៃទិន្នន័យទឹកភ្លៀង និងចារ ទឹកស្ទឹង ក្នុងខែ សីហា និង កញ្ញា ឆ្នាំ ២០០៦។ តាំងពីការអង្កេតទិន្នន័យជាក់ស្តែងនៅមានកំរិត គំរូលំហូរពីទីចោតជាបណ្តោះអាសន្នមួយត្រូវបានបង្កើត។ ហើយគំរូនេះ អាចធ្វើការកែតម្រូវបន្តដោយផ្អែកទៅលើទិន្នន័យអង្កេតថ្មីៗបន្ថែមទៀត។

## (៣) ការរៀបចំច្បាប់គ្រប់គ្រងការប្រើប្រាស់សំណង់ទ្វារទឹកសំខាន់ៗ (ខ.៣.១ ទៅ ខ.៣.៥)

មានសំណង់ទ្វារទឹកសំខាន់ៗបីនៅតាមដងស្ទឹងព្រែកត្នោត។ សំណង់ទាំងនោះរួមមាន ទ្វារទឹករលាំងជ្រៃ, សំណង់ ស្ទាក់ទឹកវត្តទឹកថ្លា និងសំណង់ទ្វារទឹកមេកណ្តាលស្ទឹង។ ដើម្បីទប់ទល់នឹងចារទឹកជំនន់នៃស្ទឹងព្រែកត្នោត ការប្រើប្រាស់ សមស្របនូវទ្វារទឹកទាំងនោះ និងការទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធជាការចាំបាច់បំផុត។ បច្ចុប្បន្នការបើក និងបិទទ្វារទឹក ទាំងនេះ គឺបានដំណើរការជាជំហ៊ានៗ ពីថ្នាក់កណ្តាលឆ្ពោះទៅក្រៅ ដោយគ្រាន់តែអង្កេតកំរិតកំពស់ទឹកនៅផ្នែកខ្សែទឹកខាង លើ។ ពុំមានបញ្ហាអ្វីធ្ងន់ធ្ងរក្នុងកិច្ចដំណើរការទាំងនេះទេ។ ទោះយ៉ាងណាក៏ដោយ ការបើកទ្វារទឹក ដើម្បីបញ្ជូនទឹកទៅផ្នែក ខ្សែទឹកខាងក្រោម គួរធ្វើឱ្យបានសមស្របបំផុត ជៀសវាងបង្កើតលំហូរមិនធម្មតាដែលអាចប៉ះពាល់ដល់អ្នករស់នៅខ្សែទឹក ខាងក្រោម។ ជាងនេះទៀត ការបើក និងបិទទ្វារទឹកមេកណ្តាលស្ទឹង គួរមានអាទិភាពជាងទ្វារទឹកវត្តទឹកថ្លា ដោយសារ ទ្វារទឹកមេកណ្តាលស្ទឹងអាចប្រើប្រាស់ស្រួល។

រយះពេលធ្វើដំណើរនៃជំនន់ពីទ្វារទឹករលាំងជ្រៃ មកទ្វារទឹកមេកណ្តាលស្ទឹង ប្រហែល ១៣ ម៉ោង គឺមានពេល វេលាគ្រប់គ្រាន់សំរាប់ការទាក់ទងគ្នាលើការបើកបិទទ្វារទឹកវត្តទឹកថ្លា និងទ្វារទឹកមេកណ្តាលស្ទឹង និងទ្វារទឹករលាំងជ្រៃឱ្យបាន ប្រសើរ។ ដូចនេះ ចំណុចសំខាន់ គឺត្រូវបង្កើត និងរក្សាបរិយាកាសបែបនេះ ដើម្បីធានាការទាក់ទងឱ្យបានទាន់ពេលវេលា រវាង ឆ្មាំទ្វារទឹកទាំងបី។

## (៤) ការរៀបចំផែនទីផ្ទៃដីលិចទឹកដែលគួរទុកចិត្តបាន (ខ.៤.១ ទៅ ខ.៤.៥)

ផែនទីផ្ទៃដីលិចទឹកដែលគួរទុកចិត្តបានត្រូវបានរៀបចំដោយប្រើប្រាស់សមីការលំហូរមិនឯកសណ្ឋាន និងលទ្ធផល ការធ្វើឋានលេខាមុខកាត់ទទឹង និងមុខកាត់បណ្តោយរបស់ស្ទឹងព្រែកត្នោត ក្នុងគោលបំណងក្តាប់ឱ្យបានព័ត៌មានទូទៅស្តីពី លក្ខខ័ណ្ឌជំនន់ស្ទឹងព្រែកត្នោត។ ផែទីបង្ហាញថា ទឹកជំនន់កើតមាន ២ ឆ្នាំ ម្តង ធ្វើឱ្យជន់លិចតំបន់នៅជាប់មាត់ស្ទឹងទោះបី ពុំមានទំហំធំធេងក៏ដោយ។ ផែនទី ក៏បានបង្ហាញផងដែរថា ជំនន់អតិបរមាអាចត្រូវបានសម្រាលសំរាប់តំបន់នៅផ្នែកខ្សែទឹក ខាងក្រោមដោយសារមានទំនប់បើកចំហរជាច្រើននៅភាគកណ្តាលនៃដងស្ទឹង។

## (៥) ការរៀបចំផែនទីគ្រោះទឹកជំនន់ (ខ.៥.១ ទៅ ខ.៥.៦)

ផែនទីគ្រោះទឹកជនន់ត្រូវបានរៀបចំសំរាប់តំបន់ជ្រើសរើសគំរូ ដែលងាយប្រឈមនិងទឹកជំនន់ដូចជា ទីរួមខេត្តកំពង់ ស្ពឺ។ ទិន្នន័យ និងព័ត៌មាន ត្រូវការសំរាប់រៀបចំផែនទីគ្រោះទឹកជនន់ដែលបានទទួល ដោយប្រើ 2-dimensional flooding calculation (software: FLO-2D)។ ដោយផ្អែកលើទិន្នន័យដែលមានស្រាប់ និងលទ្ធផលនៃការចុះពិនិត្យទីតាំងផ្ទាល់ ផែនទីគ្រោះទឹកជនន់សំរាប់តំបន់គំរូត្រូវបានរៀបចំ ដោយបង្ហាញពីទីតាំងបណ្តោះអាសន្ននៃមជ្ឈមណ្ឌលជន្លៀសប្រជាជនចេញ និងផ្លូវជន្លៀសប្រជាជនចេញ។ ការងារនេះទាមទារនិតិវិធីវែង ដូចជាការពិភាក្សាជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ មុនពេលបញ្ចប់ការងាររៀបចំខាងលើនេះ។

## (៦) សិក្សាលើការព្យាករណ៍ជំនន់ និងភាពអាសន្ន (ខ.៦.២ ទៅ ខ.៦.៤)

ការសិក្សាលើព្យាករណ៏ជំនន់ និងភាពអាសន្នសំរាប់តំបន់គំរូ បានបង្ហាញប្រព័ន្ធពីរដូចខាងក្រោម:

**១) ការព្យាករណ៍ជំនន់ជាមួយកំរិតកំពស់ទឹក**

ការអង្កេតលើកំរិតកំពស់ទឹកជំនន់នៅចំណុចពាំឃ្លៃ ត្រូវបានប្រើនៅពេលដែលរយៈពេលធ្វើដំណើរនៃជំនន់អាចមានរយៈពេល ២ម៉ោង ពីពាមឃ្លៃ ទៅទ្វារទឹករលាំងជ្រៃ និងរយះពេល ១៣ ម៉ោង ពីទ្វារទឹករលាំងជ្រៃទៅទ្វារទឹកកណ្តាលស្ទឹង។ ដូចនេះគឺមានពេលគ្រប់គ្រាន់សំរាប់ប្រកាសអាសន្នដល់អ្នកស្រុក។

**២) ការព្យាករណ៍ជំនន់ជាមួយទឹកភ្លៀង**

មានស្ថានីយ៍អង្កេតទឹកភ្លៀងមួយកន្លែងនៅគីរីរម្យ។ យោងតាមការសិក្សា ផលបូកទឹកភ្លៀងបន្តគ្នា រយៈពេល ៤៨ ម៉ោង នៅគីរីរម្យ គឺមានទំណាក់ទំនងគ្នាល្អជាមួយកំរិតកំពស់ទឹកនៅស្ថានីយ៍ពាមឃ្លៃ ២៤ ម៉ោងក្រោយ។ ប្រសិនបើទំនាក់ទំនងនេះត្រូវបានប្រើប្រាស់ នោះពេលវេលាបន្ថែម អាចគ្រប់គ្រាន់សម្រាប់ការប្រុងប្រយ័ត្នការជាមួយនិងការព្យាករណ៍ជំនន់ជាមួយកំរិតកំពស់ទឹក។ ទោះយ៉ាងណាក៏ដោយត្រូវ បន្ថែមឧបករណ៍ និងសំភារៈមួយចំនួនទៀត ដូចជា តំរូវឱ្យមានការបំពាក់ឧបករណ៍ Telemeter system សំរាប់បញ្ជូនទិន្នន័យទៅមជ្ឈមណ្ឌលទឹកជំនន់។

## <u>ផ្នែក គ: ការពង្រឹងសមត្ថភាពមូលដ្ឋានលើការគ្រប់គ្រងបរិស្ថាន</u>

### (១) ការគិតគូរនៅលើបរិស្ថានដើម្បីអភិវឌ្ឍន៍ធនធានទឹក (គ-១.២)

អាងទឹកស្ទឹងព្រែកត្នោតមានបញ្ហាផ្សេងៗជាច្រើនដូចជា ទឹកជំនន់ជាប្រចាំ, ខ្វះខាតទឹកក្នុងរដូវប្រាំងសំរាប់កសិកម្ម និងការកើននូវតំរូវការទឹកដោយការកើនឡើងយ៉ាងឆាប់រហ័សលើវិស័យឧស្សាហកម្ម និងប្រជាជន។ បញ្ហាទាំងនេះ បង្ហាញពីតម្រូវការនៃការរៀបចំផែនការសំរាប់អភិវឌ្ឍន៍ធនធានទឹកនៅអនាគតដ៏ខ្លីខាងមុខ។ ការអភិវឌ្ឍន៍ធនធានទឹក មានការប៉ះពាល់យ៉ាងខ្លាំងទៅលើបរិស្ថានសង្គម និងធម្មជាតិ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ដែលជាភ្នាក់ងារប្រតិបត្តិ ត្រូវយកចិត្តទុកដាក់ និងគិតគូរឱ្យបានហ្មតចត់ទៅលើបរិស្ថាន។ បញ្ហាដូចខាងក្រោម នេះ ត្រូវបានបញ្ជាក់ និងស្នើឡើង:

- ការចូលរួម /ពិគ្រោះជាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មានដោយរួមទាំងកិច្ចប្រតិបត្តិការនៃការ វិភាគចំពោះអ្នកពាក់ព័ន្ធ, ការរៀបចំផែនការ និងថវិកា, ការពិចារណាលើវិធីសាស្ត្រនៃការចូលរួម និងកំរិតនៃការអញ្ជើញចំពោះអង្គការបរិស្ថានក្រៅរដ្ឋាភិបាល។
- ពិចារណាលើវិធានការបន្ធូរបន្ថយ
- ការបរិច្ចាគដីដោយស្ម័គ្រចិត្ត ការដោះស្រាយជំរកថ្មី ដោយរួមបញ្ចូលទាំងផែនការឱ្យមានការបរិច្ចាគដី ដោះស្រាយជំរកថ្មីដោយសហការជាមួយគណៈកម្មាការដោះស្រាយដីធ្លីអន្តរក្រសួង និងភ្នាក់ងារ ដទៃទៀត, កាលវិភាគពេលវេលា និងថវិកាសំរាប់ការតាំងជំរកថ្មី និងពិចារណាលើកិច្ចប្រតិបត្តការ កម្មវិធី និងការពិនិត្យតាមដាន។

### (២) ការគ្រប់គ្រងបរិស្ថាន និងផែនការតាមដានសំរាប់អភិវឌ្ឍន៍ធនធានទឹក

បន្ទាប់ពីកិច្ចប្រតិបត្តិការនៃគំរោងអភិវឌ្ឍន៍ធនធានទឹក, ការគ្រប់គ្រង និងតាមដានបរិស្ថាន (EMM) ត្រូវអនុវត្ត ឱ្យបានត្រឹមត្រូវ និងទៀងទាត់។ សំណើដូចខាងក្រោម ត្រូវបានស្នើឡើង សំរាប់កិច្ចប្រតិបត្តិការសកម្មភាពការគ្រប់គ្រង និង តាមដានបរិស្ថាន :

- រៀបចំបញ្ជីត្រួតពិនិត្យសំរាប់រៀបចំផែនការគ្រប់គ្រង និងតាមដានបរិស្ថាន(EMM)
- យកចិត្តទុកដាក់ចំពោះការតាមដានគុណភាពទឹក, ការគ្រប់គ្រងសកម្មភាពកសិកម្ម ពិនិត្យតាមដានការ រស់នៅរបស់ប្រជាជន និងការគ្រប់គ្រងទីជំរាល។

### (៣) អនុសាស៍ចំពោះការអភិវឌ្ឍន៍សមត្ថភាព (គ-១.៤)

**ក្រសួងធនធានទឹក និងឧតុនិយម**

- បង្កើតអង្គភាពទទួលខុសត្រូវសំរាប់គ្រប់គ្រងផលប៉ះពាល់បរិស្ថាន និងសង្គម
- ធានាចំណេះដឹង និងជំនាញដើម្បីពិចារណា, ត្រួតពិនិត្យ និងតាមដានលើការសិក្សា EIA

**ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ**

- ពង្រឹងការិយាល័យ EIA ដែលមានស្រាប់ដោយបញ្ជាក់ពីបេសកកម្ម និងការងារទទួលខុសត្រូវ, រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងពាក់កណ្តាលអាណត្តិ, បង្កើតចំណងប្រតិបត្តិការ ជាមួយនាយក ដ្ឋានបច្ចេកទេសនានា ។
- ពង្រឹងសមត្ថភាពនៃការរៀបចំ TOR សំរាប់សិក្សា EIA, ត្រួតពិនិត្យ និងតាមដានលើការសិក្សា និងពិនិត្យឡើងវិញនូវរបាយការណ៍ EIA ។